សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរលត់កាតព្វកិច្ច

ស្រាវជ្រាវពីថ្ងៃទី ១ ខែឧសភា ឆ្នាំ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហេង វិមានរិទ្ធិ**

**សុត ឧត្តម**

សាស្ត្រាចារ្យណែនាំ

លោក **ហេង ម៉ូរ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**ឆ្នាំសិក្សា ២០២០ - ២០២១**

## អារម្ភកថា

យើងខ្ញុំទាំងពីររូប សូមគោរពចំពោះលោកឯកឧត្តម លោក លោកស្រីសាស្ត្រាចារ្យ មិត្តអ្នក អាន និងនិស្សិតគ្រប់រូបដោយសេចក្តីគោរព និងសេចក្តីស្រឡាញ់។

យើងខ្ញុំទាំងពីររូប គឺជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២០-២០២១ ដែលត្រូវបានប្រធានការិយាល័យ ស្រាវជ្រាវ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានអនុញ្ញាតឲ្យយើងខ្ញុំសិក្សាស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សា លើប្រធានបទដែល យើងខ្ញុំបានស្នើសុំ " ការរលត់កាតព្វកិច្ច " ដោយមានការណែនាំ ផ្តល់យោបល់នៃកិច្ចការសារណានេះពីលោកសាស្ត្រាចារ្យ ហេង បូរ៉ា ដើម្បីចងក្រងជាឯកសារ និងសម្រាប់តម្កល់ទុកជាវត្ថុអនុស្សាវរីយ៍នៅក្នុងបណ្ណាល័យ សម្រាប់មិត្តអ្នកអាន និងប្អូនៗនិស្សិតជំនាន់ក្រោយសិក្សាស្វែងយល់ស្រាវជ្រាវទៅលើការរលត់កាតព្វកិច្ចនេះ។

សៀវភៅស្រាវជ្រាវនេះ គឺជាផ្នែកមួយដែលអាចជួយឲ្យមិត្តអ្នកអានទទួលបានចំណេះដឹងបន្ថែមខាងផ្នែកច្បាប់ជាពិសេស គឺជួយឲ្យអ្នកទាំងអស់គ្នាទទួលបាននូវពុទ្ធិបន្ថែមដែលទាក់ទងនឹងការរលត់កាតព្វកិច្ច ដែលជាផ្នែកមួយដែលកំពុងមានត្រូវបានគេលើកមកសិក្សា ដើម្បីអនុវត្តន៍នៅក្នុងសង្គមបច្ចុប្បន្ននេះហើយចំណេះដឹងទាំងនេះក៏អាចជួយឲ្យអ្នកទាំងអស់គ្នាមានគំនិតក្នុងការដោះស្រាយរាល់បញ្ហាដែលកើតមានមកលើខ្លួន គ្រួសារ ជួយអ្នកដទៃ និងសង្គមជាតិ ជាអាទិ៍។

ចំពោះប្រធានបទខាងលើនេះ គឺមានឯកសារមួយចំនួនទាក់ទង់ជាច្រើនដែលពួកខ្ញុំទាំងពីរបានរកបាន ប៉ុន្តែទោះបីជាយ៉ាងក៏ដោយ យើងខ្ញុំគិតថាឯកសារទាំងនោះ គឺពុំទាន់គ្រប់គ្រាន់ចំពោះខ្លឹមសារនៃប្រធានបទខាងលើនៅឡើយទេ ហេតុដូច្នេះយើងខ្ញុំសូមធ្វើការអធ្យាស្រ័យទុកជាមុនចំពោះកង្វះខាតនៃខ្លឹមសារក៏ដូចជាកំហុសឆ្គងអក្ខរាវិរុទ្ធដោយចេតនាណាមួយ។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរអរគុណចំពោះ ឯកឧត្តម លោក-លោកស្រីសាស្ត្រាចារ្យ សិស្សនិស្សិតមិត្តអ្នកអានទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងយកចិត្ត ទុកដាក់ក្នុងការអានសៀវភៅរបស់យើងខ្ញុំ។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសារណានេះនឹងក្លាយជាវិភាគទានដ៏មានតម្លៃមួយសម្រាប់ជាចំនេះដឹងដល់បងប្អូនជនរួមជាតិទាំងអស់ ហើយសូមជូនពរប្រជាជនទូទាំងប្រទេសកម្ពុជា សូមជួបប្រទះតែសេចក្តីសុខ សេចក្តី ចម្រើន និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី ១. សញ្ញាណនៃកាតព្វកិច្ច** ........................................ ៣

**ផ្នែកទី ១ ប្រភពនៃកាតព្វកិច្ច និង និយមន័យនៃទស្សនៈផ្សេងៗ** ........................................ ៣

**កថាខ័ណ្ឌទី ១. កាតព្វកិច្ច** ........................................ ៣

១.១ និយមន័យ........................................ ៤

១.២ ភាពខុសគ្នារវាងសិទ្ធិលើបំណុល និង សិទ្ធិប្រត្យក្ស........................................ ៤

**កថាខ័ណ្ឌទី ២. ប្រភពនៃកាតព្វកិច្ច** ........................................ ៥

**កថាខ័ណ្ឌទី ៣. និយមន័យនៃការបង្ហាញឆន្ទៈ កិច្ចសន្យា សកម្មភាពឯកតោភាគី**........................................ ៥

**ផ្នែកទី២ ប្រភេទ និងបែបយ៉ាងនៃកាតព្វកិច្ច**

**កថាខ័ណ្ឌទី ១. ប្រភេទនៃកាតព្វកិច្ច**........................................ ៧

១.១ កាតព្វកិច្ចមានគោលបំណងឲ្យធ្វើសកម្មភាព និង កាតព្វកិច្ចមានគោលបំណងមិនឲ្យធ្វើសកម្មភាព ........................................ ៧

ក. កាតព្វកិច្ចមានគោលបំណងឲ្យធ្វើសកម្មភាព........................................ ៨

ខ. កាតព្វកិច្ចមានគោលបំណងមិនឲ្យធ្វើសកម្មភាព........................................ ៨

១.២ កាតព្វកិច្ចប្រគល់ និង កាតព្វកិច្ចធ្វើសកម្មភាព ........................................ ៨

ក. កាតព្វកិច្ចប្រគល់........................................ ៨

ខ. កាតព្វកិច្ចធ្វើសកម្មភាព ........................................ ៨

**កថាខ័ណ្ឌទី ២ កាតព្វកិច្ចប្រគល់វត្ថុ ដែលបានកំណត់ជាក់លាក់ និង កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ** ........................................ ៨

២.១ កាតព្វកិច្ចប្រគល់វត្ថុ ដែលបានកំណត់ជាក់លាក់........................................ ៩

២.២ កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ........................................ ៩

២.៣ កាតព្វកិច្ចជាប្រាក់ និង កាតព្វកិច្ចមិនមែនជាប្រាក់ ........................................ ១០

ក. កាតព្វកិច្ចជាប្រាក់........................................ ១០

ខ. កាតព្វកិច្ចមិនមែនជាប្រាក់ ........ ១១
២.៤ កាតព្វកិច្ចអនិយ័ត និង កាតព្វកិច្ចដែលមិនអាចជ្រើសរើសបាន ........ ១១
ក. កាតព្វកិច្ចអនិយ័ត ........ ១១
ខ. កាតព្វកិច្ចដែលមិនអាចជ្រើសរើសបាន ........ ១២
**កថាខ័ណ្ឌទី ៣ អត្រាការប្រាក់ដែលច្បាប់បានកំណត់ និង ការប្រាក់សមាស** ........ ១២
ក. អត្រាការប្រាក់ដែលច្បាប់បានកំណត់ ........ ១២
ខ. ការប្រាក់សមាស ........ ១៣
**ជំពូកទី ២. ការរលត់កាតព្វកិច្ច**
**ផ្នែកទី១. ការសង** ........ ១៤
**កថាខ័ណ្ឌទី ១. គោលការណ៍ទូទៅស្តីពីការសង** ........ ១៤
១.១. អ្នកសង ........ ១៤
១.២ សមត្ថភាពចាត់ចែងរបស់អ្នកសង ........ ១៥
១.៣. សិទ្ធទទួលការសង និងការកម្រិតសិទ្ធទទួលការសងដោយការរឹបអូស ........ ១៦
ក. សិទ្ធទទួលការសង ........ ១៦
ខ. ការកម្រិតសិទ្ធទទួលការសងដោយការរឹបអូស ........ ១៦
១.៤ វិធីសង ........ ១៨
ក. ការសងមួយភាគ ........ ១៩
ខ. ការសងដោយយកវត្ថុជំនួស ........ ១៩
**កថាខ័ណ្ឌទី ២. ការកាត់បំណុល** ........ ២០
២.១ ការកាត់បំណុលដោយការជ្រើសរើស និង ការកាត់បំណុលតាមច្បាប់កំណត់ ........ ២០
២.២.១ ការកាត់បំណុលដោយការជ្រើសរើស ........ ២០
២.២.២ ការកាត់បំណុលតាមច្បាប់កំណត់ ........ ២១
២.២.៣ លំដាប់នៃការកាត់បំណុល ........ ២១
**កថាខណ្ឌទី ៣. សំណើរការផ្តល់ការសង និងការតម្កល់** ........ ២២
៣.១. អត្ថន័យ និងអានុភាពជាមូលដ្ឋាននៃសំណើផ្តល់ការសង ........ ២២
ក. អត្ថន័យសំណើរផ្តល់ការសង ........ ២២
ខ. អានុភាពមូលដ្ឋានសំណើផ្តល់ការសង ........ ២៣

៣.២. ការតម្កល់ និងសិទ្ធលក់ដោយខ្លួនឯង ...................................................... ២៤
ក. ការតម្កល់............................................................................................ ២៤
ខ. សិទ្ធលក់ដោយខ្លួនឯង............................................................................ ២៤
**ផ្នែកទី ២. ការទូទាត់** ..................................................................................... ២៥
**កថាខណ្ឌទី ១. ការទូទាត់**............................................................................. ២៥
១.១. ល័ក្ខខ័ណ្ឌនៃការទូទាត់ដែលច្បាប់បានកំណត់ និងកិច្ចសន្យាទូទាត់ ........................... ២៥
ក. ល័ក្ខខ័ណ្ឌនៃការទូទាត់ដែលច្បាប់បានកំណត់..................................................... ២៥
ខ. កិច្ចសន្យាទូទាត់ ..................................................................................... ២៥
២.២. វិធីទូទាត់............................................................................................... ២៦
ក. ការកម្រិតចំពោះការទូទាត់ ......................................................................... ២៧
ខ.ការទូទាត់ជាមួយនឹងសិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀតដែលកើតឡើង
ដោយអំពើអនីត្យានុកូល ............................................................................. ២៧
**កថាខណ្ឌទី២. ការលើកលែង**......................................................................... ២៨
២.១. ការលើកលែងតែមួយផ្នែក ......................................................................... ២៨
២.២. ករណីដែលកម្រិតការលើកលែង.................................................................. ២៨
**កថាខ័ណ្ឌទី ៣. នវកម្ម និងព្យាកុលភាព** ........................................................... ២៩
៣.១. នវកម្ម ................................................................................................. ២៩
៣.២. ការមិនរលត់កាតព្វកិច្ច ការផ្ទេរប្រាតិភោគ .......................................................... ៣០
ក. ការមិនរលត់កាតព្វកិច្ច............................................................................. ៣០
ខ. ការផ្ទេរប្រាតិភោគ ................................................................................... ៣១
**កថាខ័ណ្ឌទី៤. ព្យាកុលភាព** .......................................................................... ៣១
**ផ្នែកទី ៣. អាជ្ញាយុកាលនៃការរំលត់សិទ្ធលើបំណុល** ............................................... ៣៣
**កថាខ័ណ្ឌ ១. និយមន័យ និង អាជ្ញាយុកាលនៃសិទ្ធលើបំណុល**................................... ៣៣
១. និយមន័យ ................................................................................................ ៣៣
១.១. ល័ក្ខនៃអាជ្ញាយុកាលនៃសិទ្ធលើបំណុល ......................................................... ៣៣
ក. ពេលចាប់ផ្តើមគិតអាជ្ញាយុកាលនៃសិទ្ធលើបំណុល ............................................. ៣៣
ខ. រយៈពេលនៃអាជ្ញាយុកាលនៃសិទ្ធលើបំណុលទូទៅ និង ខ្លី ..................................... ៣៤

គ. អំឡុងពេលអាជ្ញាយុកាលនៃអាជ្ញាយុកាលនៃសិទ្ធលើបំណុលដែលចូលជាស្ថាពរ..... ៣៤

**កថាខ័ណ្ឌ ២. ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធលើបំណុល ........................................ ៣៤**

២.១. ហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធលើបំណុល ........................................ ៣៥

ក. ការទាមតារតាមផ្លូវតុលាការ ........................................ ៣៥

ខ.សកម្មភាពអនុវត្តបង្ខំ ឬការចាត់ចែងរក្សាការពារ ........................................ ៣៥

គ. ការលុបចោលនូវការចាត់ចែងអនុវត្តដោយបង្ខំ ឬការចាត់ចែងរក្សាការពារ........................ ៣៦

**កថាខ័ណ្ឌទី ៣. ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធលើបំណុល ...................... ៣៦**

៣.១ ការបង្អង់ការសម្រេចអាជ្ញាយុកាលដោយការដាស់តឿន និងដោយការ

ដាស់តឿនតាមផ្លូវតុលាការ ........................................ ៣៧

ក-ការដាស់តឿន ........................................ ៣៧

ខ-ការដាស់តឿនតាមផ្លូវតុលាការ ........................................ ៣៧

៣.២ ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធលើបំណុលចំពោះអនីតិ

ជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ ........................................ ៣៨

ក.សិទ្ធិលើបំណុលចំពោះអនីតិជន ឬ អាណាព្យាបាលទូទៅ........................................ ៣៨

ខ.សិទ្ធិលើបំណុលរវាងប្តីប្រពន្ធ ........................................ ៣៨

គ.សិទ្ធិលើបំណុលដោយសារករណីមហន្តរាយធម្មជាតិ (ប្រធានសក្តិ).................. ៣៨

**កថាខ័ណ្ឌទី៣. អាជ្ញាយុកាលនៃការរំលត់សិទ្ធលើបំណុលលើទ្រព្យ ក្រៅពីសិទ្ធលើ**

**បំណុល ឬកម្មសិទ្ធ ........................................ ៣៨**

## ជំពូកទី ៣. បញ្ហាប្រឈម និងដំណោះស្រាយ

### ផ្នែកទី ១. បញ្ហាប្រឈម ........................................ ៤០

**កថាខ័ណ្ឌទី ១. បញ្ហាប្រឈមពាក់ព័ន្ធ ការខ្វះបទដ្ឋានគតិយុត្តិ** ........................................ ៤០

**កថាខ័ណ្ឌទី ២. បញ្ហាប្រឈមពាក់ព័ន្ធ អាជ្ញាយុកាលនៃការរំលត់សិទ្ធលើបំណុល** ........................ ៤០

**កថាខ័ណ្ឌទី ៣. បញ្ហាប្រឈមពាក់ព័ន្ធនិង ការមិនអនុវត្តកាតព្វកិច្ច ការសង** ........................ ៤១

### ផ្នែកទី ២ ដំណោះស្រាយ ........................................ ៤១

**កថាខ័ណ្ឌទី ១. ដំណោះស្រាយពាក់ព័ន្ធ ការខ្វះបទដ្ឋានគតិយុត្តិ**........................................ ៤២

**កថាខ័ណ្ឌទី ២. ដំណោះស្រាយ តាមប្រព័ន្ធតុលាការ** ........................................ ៤៣

**កថាខ័ណ្ឌទី ៣. ដំណោះស្រាយ ក្រៅប្រព័ន្ធតុលាការ** ........................................ ៥៥

**សេចក្តីសន្និដ្ឋាន**

**អនុសាសន៍**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងជីវភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋគ្រប់ៗរូប តែងតែមានការប្រាស្រ័យទំនាក់ទំនងនឹងគ្នាទៅវិញទៅមកដែរចងជាកាតព្វកិច្ចរវាងគ្នានិងគ្នា។យ៉ាងដូច្នេះហើយ កាតព្វកិច្ចតែងតែកើតមានរាល់ពេលដែលភាគីមានទំនាក់ទំនងជាមួយគ្នា ដូចជាការធ្វើកិច្ចសន្យា ដែលមានកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាផ្សេងៗជាដើម ដែលតម្រូវឲ្យភាគីទាំងសងខាងនៃកិច្ចសន្យាមានកាតព្វកិច្ចត្រូវអនុវត្តជាដាច់ខាត។យ៉ាងណាក៏ដោយកាតព្វកិច្ចនឹងត្រូវរលត់ទៅវិញ លុះភាគីដែលមានករណីកិច្ចអនុវត្តនោះបានបំពេញទៅតាមកិច្ចសន្យាស្របដោយច្បាប់កំណត់ ហើយក៏មាននីតិវិធីជាច្រើនដែលកំណត់ដើម្បីធ្វើឲ្យកាតព្វកិច្ចរលត់បាន ។ហេតុយ៉ាងដូច្នេះហើយ ទើបនៅក្នុងប្រទេសកម្ពុជាបានកំណត់យ៉ាងច្បាស់នៅក្នុងក្រមរដ្ឋប្បវេណីអំពីការរលត់កាតព្វកិច្ចដែលមានចែងជាជំពូក ផ្នែកនីមួយៗ ដូចជា ការសង អលទ្ធភាពក្នុងការសង ការផុតអាជ្ញាយុកាល ជាដើម។ល។ ប៉ុន្តែនៅក្នុង កិច្ចការស្រាវជ្រាវសារណានេះ គឺផ្តោតតែលើការសង ការទូទាត់ ការលើកលែង នវកម្ម ឬព្យាកុលភាពមកសិក្សាតែប៉ុណ្ណោះ។ កាតព្វកិច្ចគឺជាចំណងតាមផ្លូវច្បាប់ ដែលចងបុគ្គលពីរនាក់ ដោយឲ្យបុគ្គលម្នាក់ដែលបានកំណត់ហៅថា "កូនបំណុល"មានករណីកិច្ចមួយចំនួនចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀតដែលកំណត់ហៅថា "ម្ចាស់បំណុល" ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

តើមានមូលហេតុអ្វីខ្លះដែលឈានទៅដល់ការរលត់កាតព្វកិច្ច ហើយដើម្បីរលត់កាតព្វកិច្ចបានតើគូភាគីទាំងសងខាងនៃកាតព្វកិច្ចត្រូវធ្វើនីតិវិធីដូចម្តេចខ្លះ ហើយនៅពេលរលត់កាតព្វកិច្ចហើយ តើមានអនុភាពដូចម្តេច?

## ៣.គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងកិច្ចការសិក្សាស្រាវជ្រាវ និងរៀបចំតាក់តែជាឯកសារ នៃកិច្ចការស្រាវជ្រាវនេះឡើងក្នុងគោលបំណងដើម្បីពង្រឹងសមត្ថភាពចំណេះដឹងផ្ទាល់ខ្លួន ក៏ដូចជាធ្វើជាទុនមួយសម្រាប់ទុកជាឯកសារស្រាវជ្រាវ និងក៏ជាចំណេះដឹងមួយដ៏សំខាន់បន្ថែមមួយផ្នែកទៀតក្នុងការស្រាវជ្រាវដើម្បីមានចំណេះដឹងបន្ថែមទៀតទៅលើប្រព័ន្ធនៃការរលត់កាតព្វកិច្ចទាំងអស់ និងបង្ហាច់បង្ហាញយល់ឲ្យកាន់តែច្បាស់ថាតើការរលត់កាតព្វកិច្ច មានសារៈសំខាន់ ក៏ដូចជាអនុភាពតាមផ្នែកផ្លូវច្បាប់ មានការទទួលស្គាល់ ក៏ដូចជាការពារដោយច្បាប់យ៉ាងដូចម្តេចខ្លះ។

## ៤.ដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីជាយានក្នុងការឆ្លើយតបទៅកាន់ចំណោទបញ្ហាគតិយុទ្ធខាងលើយើងខ្ញុំបាទ បានខិតខំធ្វើការសិក្សាស្រាវជ្រាវទៅលើឯកសារដែរពាក់ព័ន្ធជាមូលដ្ឋាន ដូចជា ក្រមរដ្ឋប្បវេណី សេចក្តីពន្យល់នៃក្រមរដ្ឋប្បវេណី និងឯកសាររួមផ្សំផ្សេងៗដែលពាក់ព័ន្ធទាំងឡាយដូចដែលបានលើកនៅក្នុងឯកសារយោងមកជាមួយស្រាប់។

នៅក្នុងកិច្ចការសរសេរសារណាបញ្ចប់ការសិក្សានេះ គឺខ្ញុំទាំងពីរបានសរសេរដោយផ្តោតទៅលើការរលត់កាតព្វកិច្ច(ដែលមានការ ការសង ការទូទាត់ ការលើកលែង នវកម្ម និងព្យាកុលភាព)តែប៉ុណ្ណោះ ដោយមិនបានសិក្សាទៅការរលត់កាតព្វកិច្ចទាំងមូលនោះទេ។ ក្រៅពីនេះយើងក៏បានធ្វើការដកស្រង់នូវខ្លឹមសារដែលមានអត្ថន័យសាំញ៉ាំយកមកបកស្រាយពន្យល់ដើម្បីងាយស្រួលក្នុងការសិក្សាស្វែងយល់ ដោយស្រាវជ្រាវអត្ថន័យចេញពី សៀវភៅសទ្ទានុក្រម ក៏ដូចជា ការបង្ហាញប្រាប់ពី លោកគ្រូ អ្នកគ្រូសាស្ត្រចារ្យ និង លោកអ្នកកំពុងអនុវត្តច្បាប់នៅតាមស្ថាប័ននានាដើម្បីជាជំនួយបន្ថែម។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការសរសេរនៃកិច្ចការនេះ រូបខ្ញុំបាទទាំងពីរបានធ្វើការសិក្សាបែបពន្យល់

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

សមិទ្ធផលនៃការសិក្សាស្រាវជ្រាវនេះអាចនឹងនាំឲ្យ បងប្អូនមិត្តអ្នកសិក្សា ក៏ដូចជាសិស្សនិស្សិតទាំងអស់ទទួលបាននូវទុនមួយដ៏សំខាន់ សម្រាប់ជាជំនួយស្មារតីដល់ការសិក្សាស្រាវជ្រាវរបស់បងប្អូន មានចំណេះបានយល់ដឹង អំពីដំណើរការនិតិវិធីនៃការរលត់កាតព្វកិច្ចឲ្យមានភាពល្អប្រសើរ ច្បាស់លាស់ត្រឹមត្រូវ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

**ជំពូកទី ១ សញ្ញាណនៃកាតព្វកិច្ច**

**ជំពូកទី ២. សញ្ញាណនៃ ការរលត់កាតព្វកិច្ច**

**ជំពូកទី ៣. អាជ្ញាយុកាលនៃការរំលត់សិទ្ធលើបំណុល**

# ជំពូកទី ១

# សញ្ញាណនៃកាតព្វកិច្ច

# ជំពូកទី ១ សញ្ញាណនៃកាតព្វកិច្ច

## ផ្នែកទី ១ ប្រភពនៃកាតព្វកិច្ច និង និយមន័យនៃពាក្យផ្សេងៗ

### កថាខ័ណ្ឌទី ១. កាតព្វកិច្ច

#### ១.១ និយមន័យ

**កាតព្វកិច្ច** គឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ ដោយឲ្យបុគ្គលម្នាក់ដែលបានកំណត់មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត (មាត្រា ៣០៨ នៃក្រមរដ្ឋប្បវេណី)។

**+ កាតព្វកិច្ច និង ករណីយកិច្ច**

កាតព្វកិច្ច គឺជាប្រភេទមួយនៃករណីយកិច្ច ប៉ុន្តែករណីយកិច្ចទាំងអស់មិនមែនសុទ្ធតែជាកាតព្វកិច្ច ទេ។ ពាក្យកាតព្វកិច្ច ត្រូវបានប្រើក្នុងករណីដែលឆ្លើយតបទៅនឹងសិទ្ធិលើបំណុល ដូចជា អ្នកទិញ មានកាតព្វកិច្ច បង់ប្រាក់ គឺ ឆ្លើយតបនឹងសិទ្ធិទាមទារឲ្យបង់ប្រាក់របស់អ្នកលក់។

ពាក្យករណីយកិច្ច ជួនកាលត្រូវបានប្រើក្នុងករណីមិនឆ្លើយតបចំពោះសិទ្ធិលើបំណុល (សិទ្ធិ ទាមទារ) ទេ។

**ឧទាហរណ៍៖** អ្នកបើកបរឡាន ម៉ូតូ មានករណីយកិច្ចប្រុងប្រយ័ត្ន នៅពេលបើកបរតាមផ្លូវ មិនឲ្យមានគ្រោះថ្នាក់ដល់បុគ្គលផ្សេងទៀត។

**+ កាតព្វកិច្ច និង សិទ្ធិលើបំណុល**

ពុំមានមាត្រាណាចែងអំពីនិយមន័យនៃសិទ្ធិលើបំណុលទេ តែមានមាត្រាចែងអំពីនិយមន័យនៃ កាតព្វកិច្ច តែតាមពិតទៅការឲ្យនិយមន័យកាតព្វកិច្ច ក៏ដូចជាការកំណត់ពីសិទ្ធិលើបំណុលដែរ ព្រោះកាតព្វកិច្ច និង សិទ្ធិលើបំណុល គឺមានទំនាក់ទំនងមុខពីរ (កាតព្វកិច្ចរបស់ភាគីម្ខាង ត្រូវគ្នានឹងសិទ្ធិរបស់ភាគីម្ខាងទៀត)។ បុគ្គល ម្ខាងដែលទទួលផលប្រយោជន៍ ហៅថា ម្ចាស់បំណុល ឯបុគ្គលម្ខាងទៀត ដែលទទួលបន្ទុក ហៅថា កូនបំណុល ។

ម្ចាស់បំណុលមានសិទ្ធិទាមទារឲ្យកូនបំណុលធ្វើ ឬ មិនធ្វើ សកម្មភាពអ្វីមួយមកឲ្យខ្លួន។ យើងលើកឧទាហរណ៍ពីកិច្ចសន្យាលក់ទិញដែលជាកិច្ចសន្យាអញ្ញមញ្ញមួយមក។

**អ្នកលក់** ◻ ←——————→ ◻ **អ្នកទិញ**

បើយើងជាភាគី A ឃើញថា យើងមានសិទ្ធិលើបំណុល ដោយឲ្យភាគី B បង់ប្រាក់ថ្លៃលក់ទិញមកឲ្យខ្លួន។ សិទ្ធិទាមទារនេះ ត្រូវគ្នានឹងករណីយកិច្ចបង់ប្រាក់របស់ភាគី B។ ក្នុងករណីនេះ A ជាម្ចាស់បំណុល រីឯ B វិញ គឺជាកូនបំណុល។

បើយើងជាភាគី B វិញ ឃើញថា យើងមានសិទ្ធិលើបំណុល ដោយឲ្យភាគី A ផ្ទេរកម្មសិទ្ធិ និង ផ្ទេរ ការកាន់កាប់វត្ថុមកឲ្យខ្លួន។ សិទ្ធិទាមទារនេះ ត្រូវគ្នានឹងករណីយកិច្ចផ្ទេរកម្មសិទ្ធិ និងផ្ទេរការកាន់កាប់របស់ភាគី A។ ក្នុងករណីនេះ B ជាម្ចាស់បំណុល រីឯ A វិញជាកូនបំណុល។

នៅក្នុងកិច្ចសន្យាលក់ទិញ អ្នកលក់ជាម្ចាស់បំណុលផង ជាកូនបំណុលផង ហើយអ្នកទិញក៏ជា ម្ចាស់បំណុលផង និង ជាកូនបំណុលផងដែរ។

**១.២ ភាពខុសគ្នារវាងសិទ្ធិលើបំណុល និង សិទ្ធិប្រត្យក្ស**

| <u>**សិទ្ធិលើបំណុល**</u> | <u>**សិទ្ធិប្រត្យក្ស**</u> |
|---|---|
| • សិទ្ធិលើបំណុល ជាសិទ្ធិលើបុគ្គលជាសិទ្ធិដែលអាចទាមទារឲ្យបុគ្គលណាមួយធ្វើសកម្មភាពអ្វី មួយ ឬ មិនធ្វើសកម្មភាពអ្វីមួយ។ អ្នកដែលមានសិទ្ធិ លើបំណុល ហៅថាម្ចាស់បំណុល។<br>• សិទ្ធិលើបំណុលពុំមានភាពដាច់ខាត មិនផ្តាច់ មុខ។<br>• ភាព<u>មិនដាច់ខាតរបស់សិទ្ធិលើបំណុលកម្មសិ</u>ទ្ធិករលើវត្ថុណាមួយ អាចម្ចាស់បំណុល អះអាងសិទ្ធិទាមទាររបស់ខ្លួនបានតែ ចំពោះបុគ្គលជាក់លាក់ (កូនបំណុល) តែប៉ុណ្ណោះ មិនអាចអះអាងដល់ជនដទៃឡើយ ។ ចំណងចងភ្ជាប់រវាងតែម្ចាស់បំណុល និង កូនបំណុលតែប៉ុណ្ណោះ ។<br>ឧទាហរណ៍៖ **ក** អោយ **ខ** ខ្ចីប្រាក់ (ខ្ចីបរិភោគ) **ក** ពុំអាចទាមទារអោយបប្អូន **ខ** សងជំនួសបានទេ ។ ហើយនៅក្នុងក្រមរដ្ឋប្បវេណី ក៏អនុញ្ញាតអោយមាន ការធ្វើ អនុប្បទានសិទ្ធលើបំណុល (មាត្រា ៥០១) និង ការទទូលកាតព្វកិច្ច (មាត្រា ៥០៧) | • សិទ្ធប្រត្យក្ស គឺសំដៅលើសិទ្ធគ្រប់គ្រងវត្ថុដោយចំពោះ ។ កម្មសិទ្ធករណាមួយអាចគ្រប់គ្រងវត្ថុដោយសេរីដែលជារបស់ខ្លួន ដោយមិនមានការជ្រៀតជ្រៀកពីអ្នកដទៃ ។ កម្មសិទ្ធករអោយចាត់ចែងប្រើប្រាស់និងអាស្រ័យផល ដែលជាកម្មសិទ្ធរបស់ខ្លួនដោយសេរី ក្នុងទំហំដែលច្បាប់បានកំណត់។<br>• សិទ្ធប្រត្យក្សមានភាពដាច់ខាត និងផ្តាច់មុខ ។<br>• ភាពដាច់ខាតរបស់សិទ្ធប្រត្យក្ស៖ កម្មសិទ្ធករលើវត្ថុមួយ អាចអះអាចអះអាងពីសិទ្ធរបស់ខ្លួនចំពោះបុគ្គលគ្រប់រូប ដូចអាទាមទារឲ្យប្រគល់វិញ តាមមាត្រា ១៥៥ សិទ្ធទាមទារឲ្យបញ្ឈប់ និងបង្ការរាំងសិទ្ធលើកម្មសិទ្ធ តាមមាត្រា ១៥៩ ក្រមរដ្ឋប្បវេណី តាមការណ៍កំណត់សិទ្ធប្រត្យក្សដោយច្បាប់ តាមមាត្រា ១៣១ ក្នុងរដ្ឋប្បវេណី |

| | |
|---|---|
| • សិទ្ធលើបំណុលអាចបង្កើតឡើងបានដោយសេរី អោយតែមិនផ្ទុយនិងវិធានច្បាប់ តាមគោលការណ៍នៃបុគ្គលឯកជន (មាត្រា ៣ ក្នុងក្រមរដ្ឋប្បវេណី) | |

## កថាខ័ណ្ឌទី ២. ប្រភពនៃកាតព្វកិច្ច

កាតព្វកិច្ចកើតឡើងដោយកិច្ចសន្យា, ដោយសកម្មភាពឯកតោភាគី ដោយការគ្រប់គ្រងដោយឈឺឆ្អាល (មាត្រា ៧២៩ នៃក្រមរដ្ឋប្បវេណី) ដោយ សេចក្តីចម្រើនដោយឥតហេតុ (មាត្រា ៧៣៦ នៃក្រមរដ្ឋប្បវេណី) ដោយអំពើអនីត្យានុកូល និងដោយបញ្ញត្តិច្បាប់។

• កាតព្វកិច្ចកើតឡើងពីកិច្ចសន្យា និងសកម្មភាពឯកតោភាគី គឺ កាតព្វកិច្ចកើតឡើងដោយឆន្ទៈរបស់ភាគី។

• កាតព្វកិច្ចដែលកើតឡើងដោយការគ្រប់គ្រងដោយឈឺឆ្អាលដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង ដោយបញ្ញត្តិច្បាប់ គឺជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ដែលកើតឡើងដោយ គ្មានការបង្ហាញឆន្ទៈរបស់ភាគី ។

## កថាខ័ណ្ឌទី ៣. និយមន័យនៃការបង្ហាញឆន្ទៈ កិច្ចសន្យា សកម្មភាពឯកតោភាគី

+ **ការបង្ហាញឆន្ទៈ** ការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្ត ហៅថា ការបង្ហាញឆន្ទៈ ។

**ឧទាហរណ៍៖** សំណើ និង ស្នីការដើម្បីបង្កើតកិច្ច សន្យា ឬ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា គឺជាការបង្ហាញឆន្ទៈ។ ផ្ទុយមកវិញ ការពោលពាក្យពេចន៍ស្នេហាប្រាប់គូ សង្សារ មិនមែនជាការបង្ហាញចុះទេ ព្រោះវាមិនមានបំណងចង់បង្កើតឲ្យមានចំណងគតិយុត្តទេ។

ការបង្ហាញឆន្ទៈ ត្រូវមានអានុភាពចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈនោះបានទៅដល់ ភាគីម្ខាងទៀត ។ ប៉ុន្តែ មានការបង្ហាញឆន្ទៈខ្លះមិនអាចធ្វើឡើង ចំពោះភាគីម្ខាងទៀតទេ ដូចជា អច្ច័យទាន។

- បើគូភាគីអង្គុយនិយាយតទល់មុខគ្នា ការបង្ហាញឆន្ទៈនេះមានអានុភាពភ្លាម ហើយការផ្ញើសារអេឡិចត្រូនិកទៅភាគីម្ខាងទៀត ក៏មានអានុភាពភ្លាមដែរ ព្រោះសារនៃការបង្ហាញឆន្ទៈ បានទៅដល់ភាគីនោះភ្លាមៗ។
- បើការបង្ហាញឆន្ទៈតាមរយៈសំបុត្រប្រៃសណីយ៍ អានុភាពនៃការបង្ហាញឆន្ទៈនោះកើតឡើងពេលសំបុត្រ បានដាក់ក្នុងប្រអប់សំបុត្ររបស់ភាគីម្ខាងទៀត ឬ នៅពេលដែលសមាជិកគ្រួសារដែលរស់នៅជាមួយភាគី ម្ខាងទៀតនោះបានទទួលសំបុត្រ ទោះបីជាភាគីម្ខាងទៀតនោះដឹង ឬ មិនដឹងអំពីការទៅដល់នៃសំបុត្រក៏ ដោយ។
- ការបង្ហាញឆន្ទៈតាមរយៈទូរស័ព្ទ ក៏មានអានុភាពភ្លាមដែរ។
- ការបង្ហាញឆន្ទៈចំពោះអនីតិជន ឬ ជនស្ថិតនៅក្រោមរបបអ្នកអាណាព្យាបាល ត្រូវធ្វើឡើងចំពោះអ្នកមាន អំណាចមេបា ឬ អ្នកអាណាព្យាបាល។
- ក៏ប៉ុន្តែ បើមានវិវាទរហូតប្តឹងទៅតុលាការ ភាគីម្ខាងអះអាងថា ខ្លួនបានទទួលសំបុត្រមែន ឬ បានទទួល ទូរស័ព្ទមែន តែពុំបាននិយាយពីការរំលាយកិច្ចសន្យាទេនោះមាត្រា ៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋ ប្បវេណីដែលចែងអំពីការជូនដំណឹងអំពីការបង្ហាញឆន្ទៈទៅអ្នកឆ្ងាយបានកំណត់អំពីវិធីបញ្ជាក់អំពីការ បង្ហាញឆន្ទៈទៅអ្នកឆ្ងាយ។

\+ **កិច្ចសន្យា៖** កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់ មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច។




- បង្កើតកាតព្វកិច្ចតាមកិច្ចសន្យា ៖ A មានដី B ចង់ជួល ហើយ A និង B ព្រមព្រៀងបង្កើតកិច្ចសន្យាជួល ដោយ A មានកាតព្វកិច្ចប្រគល់ដី ហើយ B មានកាតព្វកិច្ចបង់ប្រាក់ដែលជាថ្លៃឈ្នួល។
- កែប្រែកាតព្វកិច្ចតាមកិច្ចសន្យា ៖ កែប្រែ សំដៅទៅលើការផ្លាស់ប្តូរ ដូចជាផ្លាស់ប្តូរអំឡុងពេលជួល ថ្លៃឈ្នួល ពេលវេលាបង់ថ្លៃឈ្នួល ជាដើម។
- រំលត់កាតព្វកិច្ចតាមកិច្ចសន្យា ៖ ពេលបង្កើត បានកំណត់អំឡុងពេលជួលរយៈពេល ១០ឆ្នាំ តែក្រោយមក ភាគី A និង B បានព្រមព្រៀងរំលាយកិច្ចសន្យាមុនអាណត្តិ។

+ **សកម្មភាពឯកតោភាគី** ៖ សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយអនុវត្តសិទ្ធដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់ ។

- កិច្ចសន្យា តម្រូវឲ្យមានការព្រមព្រៀងរវាងគូភាគី តែសកម្មភាពឯកតោភាគី មិនតម្រូវឲ្យមានការព្រមព្រៀងពីភាគីម្ខាងទៀតទេ។
- បង្កើតកាតព្វកិច្ចតាមសកម្មភាពឯកតោភាគី ៖ អច្ច័យទាន ជាសកម្មភាពឯកតោភាគីក្នុងការបង្កើតកាតព្វកិច្ច ប៉ុន្តែ កាតព្វកិច្ចត្រូវធ្លាក់ទៅលើសន្តតិជន។ ការទទួលស្គាល់កូន ក៏ជាសកម្មភាពឯកតោភាគីដែរ ពីព្រោះឪពុកមានកាតព្វកិច្ចចិញ្ចឹម និងថែរក្សាកូនដែលជាអនីតិជន ជាដើម។
- ការកែប្រែកាតព្វកិច្ចតាមសកម្មភាពឯកតោភាគី ៖ ការកែប្រែ សំដៅទៅលើការផ្លាស់ប្តូរ។ ឧទាហរណ៍ នៅ ក្នុងកិច្ចសន្យាលក់ទិញរថយន្ត អ្នកលក់បានសន្យាថានឹងយករថយន្តទៅឲ្យអ្នកទិញដល់ផ្ទះ។ នៅក្នុងកិច្ច សន្យាបានផ្តល់សិទ្ធិឲ្យអ្នកទិញអាចផ្លាស់ប្តូរទីកន្លែងនៃការប្រគល់ក្រៅពីក្រុងភ្នំពេញបាន ប្រសិនបើអ្នក ទិញទាក់ទងមកអ្នកលក់នៅមុន៣ថ្ងៃ។ ប្រសិនបើអ្នកទិញទាក់ទងទៅអ្នកលក់ ដោយសុំឲ្យផ្លាស់ប្តូរទី កន្លែងនៃការដឹកជញ្ជូនមកកន្លែងធ្វើការវិញនោះ នេះគឺជាការកែប្រែកាតព្វកិច្ចតាមសកម្មភាពឯកតោភាគី។
- រំលត់កាតព្វកិច្ចតាមសកម្មភាពឯកតោភាគី ៖ ការលុបចោលកិច្ចសន្យា[៩]ការរំលាយកិច្ចសន្យា[១០]គឺជាសកម្មភាពឯកតោភាគី។ ការលើកលែង[១១] ក៏ជាសកម្មភាពឯកតោភាគី។

## ផ្នែកទី២ ប្រភេទ និងបែបយ៉ាងនៃកាតព្វកិច្ច

### កថាខ័ណ្ឌទី ១. ប្រភេទនៃកាតព្វកិច្ច

កាតព្វកិច្ច មានន័យថាជាទំនាក់ទំនងគតិយុត្ត ដែលបុគ្គលជាក់លាក់ម្នាក់ (កូនបំណុល) មានករណីយកិច្ច ចំពោះបុគ្គលជាក់លាក់ម្នាក់ទៀត (ម្ចាស់បំណុល) ។ ខ្លឹមសារនៃករណីយកិច្ចអាចមានផ្សេងៗគ្នាដូចជា ការប្រគល់ វត្ថុ ឬប្រាក់ ការបំពេញសកម្មភាពមួយចំនួន ឬការមិនបំពេញសកម្មភាពមួយចំនួន ។

**ឧទាហរណ៍៖** អ្នកទិញ នៅក្នុងកិច្ចសន្យាលក់ទំនិញ មានករណីយកិច្ចបង់ប្រាក់ឲ្យអ្នកលក់។ ចំណែកឯអ្នកលក់ មាន ករណីយកិច្ចផ្ទេរកម្មសិទ្ធិនៃវត្ថុដែលជាកម្មវត្ថុនៃការលក់ទៅឲ្យអ្នកទិញ ។

មូលហេតុនៃកាតព្វកិច្ចជាច្រើនផ្សេងទៀតកើតមាន ដូចមានចែងនៅក្នុងមាត្រា ៣០៩ នៃក្រមរដ្ឋប្បវេណី។

## ១.១ កាតព្វកិច្ចមានគោលបំណងឲ្យធ្វើសកម្មភាព និង កាតព្វកិច្ចមានគោលបំណងមិនឲ្យធ្វើសកម្មភាព

### ក. កាតព្វកិច្ចមានគោលបំណងឲ្យធ្វើសកម្មភាព

កាតព្វកិច្ចមានគោលបំណងឲ្យធ្វើសកម្មភាព គឺអាចធ្វើឡើងតាមរយៈកិច្ចសន្យាអាណត្តិ កិច្ចសន្យាការងារជាដើម ។ ឧ. ការសម្អាតផ្លូវថ្នល់ ការកាប់ដើមឈើ ការសាងសង់ ឬការបំផ្លាញអាគារ ការដឹកជញ្ជូនទំនិញ ។ ល។

### ខ. កាតព្វកិច្ចមានគោលបំណងមិនឲ្យធ្វើសកម្មភាព

មិនមានឧទាហរណ៍ជាគម្រូណាមួយនៃកាតព្វកិច្ចមានគោលបំណងមិនឲ្យធ្វើសកម្មភាពអ្វីមួយ តាមរយៈកិច្ចសន្យាក្នុងទម្រង់ណាមួយទេ ហើយគេមិនអាច និយាយជាក់លាក់ថា តើកាតព្វកិច្ចដែលមានបំណងលុបចោលសកម្មភាពត្រូវបានទទួលស្គាល់ ឬអត់ទេ ។ ជាលទ្ធផលមាត្រា ៣១៣ នៃក្រមរដ្ឋប្បវេណី ចែងយ៉ាងច្បាស់ថា អាចមានកាតព្វកិច្ចមិនឲ្យធ្វើសកម្មភាពណាមួយ ។

**ឧទាហរណ៍៖** មិនឲ្យបើកអាជីវកម្មដូចគ្នា (ផ្លាកសញ្ញា, ម៉ាក), កិច្ចសន្យាធ្វើឡើងរវាងក្រុមហ៊ុន និងតួសម្តែងដែល ចែងសកម្មភាពមិនឲ្យតួកុនទៅសម្តែងនៅក្រុមហ៊ុនផ្សេងទៀត។

**ឧទាហរណ៍៖** បទបញ្ជាហាមប្រាមរបស់អាជ្ញាធរមូលដ្ឋាន, កិច្ចសន្យាហាមមិនឲ្យលេងព្យាណូនៅពេលយប់ ។

## ១.២ កាតព្វកិច្ចប្រគល់ និង កាតព្វកិច្ចធ្វើសកម្មភាព

### ក. កាតព្វកិច្ចប្រគល់

**កាតព្វកិច្ចប្រគល់** គឺអ្នកលក់មានកាតព្វកិច្ចត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញទៅឲ្យអ្នកទិញតាម កាលបរិច្ឆេទ និងតាមទីកន្លែងដែលបានកំណត់នៅក្នុងកិច្ចសន្យា ។

**ឧទាហរណ៍៖** ករណីកិច្ចសន្យាទិញលក់ឡាន កាតព្វកិច្ចប្រគល់ គឺអ្នកលក់ត្រូវប្រគល់ឡានទៅឲ្យអ្នកទិញរីឯអ្នក ទិញមានកាតព្វកិច្ចត្រូវប្រគល់លុយទៅឲ្យអ្នកលក់ ។

### ខ. កាតព្វកិច្ចធ្វើសកម្មភាព

កាតព្វកិច្ចធ្វើសកម្មភាព គឺជាប្រភេទនៃកាតព្វកិច្ចដែលមានគោលបំណងឲ្យធ្វើសកម្មភាពក្រៅពីកាតព្វកិច្ចប្រគល់។

**ឧទាហរណ៍៖** កិច្ចសន្យាដឹកជញ្ជូនទំនិញដែលអ្នកដឹកជញ្ជូនត្រូវដឹកជញ្ជូនទំនិញឲ្យអតិថិជន, កិច្ចសន្យាអាណត្តិដូច ជា មេធាវីត្រូវធ្វើសកម្មភាពការពារក្តីឲ្យកូនក្តី (គូភាគីមានឋានៈស្មើគ្នា) , កិច្ចសន្យាម៉ៅការដូចជាអ្នកម៉ៅការត្រូវ សាងសង់អាគារ (គូភាគីមានឋានៈស្មើគ្នា)។

## កថាខ័ណ្ឌទី ២ កាតព្វកិច្ចប្រគល់វត្ថុ ដែលបានកំណត់ជាក់លាក់ និង កាតព្វកិច្ច ដែលបានកំណត់ប្រភេទនៃវត្ថុ

### ២.១ កាតព្វកិច្ចប្រគល់វត្ថុ ដែលបានកំណត់ជាក់លាក់

វត្ថុដែលបានកំណត់ជាក់លាក់ គឺជាករណីដែលភាគីពាក់ព័ន្ធនៃកិច្ចសន្យាផ្តោតលើលក្ខណៈសម្គាល់ពិសេសនៃវត្ថុមួយ ហើយបើទោះបីជាមានការប្រគល់វត្ថុជំនួសក៏ដោយ ក៏មិនអាចចាត់ទុកថាជាការអនុវត្តកាតព្វកិច្ច ដែរ។ ចំពោះកាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់អ្វីមួយកូនបំណុលមានករណីយកិច្ចថែរក្សាវត្ថុនោះ ដោយប្រុងប្រយ័ត្នរហូតដល់ពេលប្រគល់នោះ ។

**ឧទាហរណ៍៖** សេះប្រណាំងឈ្មោះក, ផ្ទាំងគំនូរទូលក្អមទឹកដោយវិចិត្រករញ៉ឹក ញឹម, ដី ឬអាគារដែលមានអត្ត សញ្ញាណច្បាស់លាស់។ល។

### ២.២ កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ

វិធីសាស្ត្រដើម្បី កំណត់ប្រភេទនៃវត្ថុគឺ ៖

**ទី១**. ត្រូវកំណត់ប្រភេទនៃវត្ថុដែលត្រូវប្រគល់ឲ្យបានច្បាស់លាស់

**ទី២**. ត្រូវបំពេញ សកម្មភាពចាំបាច់ដើម្បីផ្តល់នូវកម្មវត្ថុ ដែលបានកំណត់ហើយនោះ។ (ជំហានទាំងពីរនេះចាំបាច់ត្រូវតែមាន) ។

កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ គឺជាកាតព្វកិច្ចដែលកម្មវត្ថុនោះត្រូវកំណត់ដោយផ្អែកលើប្រភេទ។

**ឧទាហរណ៍៖** អង្ករ១០គីឡូក្រាមមកពីខេត្តបាត់ដំបង / គោដោយគ្មានបញ្ជាក់ថាគោណាមួយ / ទូរទស្សន៍ ២០គ្រឿង / ស្រាបៀអង្គរ ១០កំប៉ុង។

- ប្រសិនបើកម្មវត្ថុត្រូវផ្តល់មានគុណភាពច្រើនយ៉ាង កូនបំណុលមានករណីយកិច្ចផ្តល់នូវវត្ថុដែលមានគុណ ភាពដូចដែលគូភាគីបានកំណត់។ ក្នុងករណីដែលគូភាគីមិនកំណត់គុណភាពទេ កូនបំណុលមានករណីកិច្ចផ្តល់នូវ វត្ថុដែលមានគុណភាពមធ្យម (មាត្រា ៣១៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។
- ចំពោះកាតព្វកិច្ច ដែលបានកំណត់ប្រភេទ ក្រោយពេលដែលកូនបំណុលបានកំណត់កម្មវត្ថុ ដែលត្រូវផ្តល់ ច្បាស់លាស់ និង ដែលបានបញ្ចប់សកម្មភាពចាំបាច់ដើម្បីផ្តល់នូវកម្មវត្ថុដែលបានកំណត់ហើយនោះ កូនបំណុល មានករណីយកិច្ចផ្តល់នូវវត្ថុនោះតែប៉ុណ្ណោះ (មាត្រា ៣១៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

**ឧទាហរណ៍៖** កិច្ចសន្យាទិញទូរទស្សន៍ចំនួន ២០ គ្រឿង ប្រសិនបើអ្នកលក់មានទូរទស្សន៍ចំនួន១០០ គ្រឿង ក្នុង ឃ្លាំង អ្នកលក់ត្រូវជ្រើសរើសយកចំនួន២០ គ្រឿង ។ ក្រោយពេលដែលកូនបំណុលបានជ្រើសរើស ទូរទស្សន៍ចំនួន ២០ គ្រឿង និងបញ្ចប់ការរៀបចំប្រគល់វត្ថុដល់អ្នកទិញរួចហើយ ករណីយកិច្ចរបស់អ្នកលក់ ត្រូវកំណត់នៅត្រឹម ករណីយកិច្ចផ្តល់តាវលិកនូវទូរទស្សន៍ទាំង២០គ្រឿងនោះ ។ ជាលទ្ធផលនៃការកំណត់នេះ អ្នកលក់មាន ករណីយកិច្ចថែរក្សាទូរទស្សន៍ទាំង ២០គ្រឿងនោះ ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ ។

- សកម្មភាពដែលចាំបាច់ត្រូវបំពេញក្នុងការប្រគល់ ៖ ពេលកំណត់ជាក់លាក់ គឺខុសគ្នាទៅតាមករណី សិក្សានីមួយៗ ហើយជាទូទៅ យើងអាចធ្វើការពិចារណាបានដូចខាងក្រោម៖
- កាតព្វកិច្ចដែលកូនបំណុលត្រូវ យកទៅប្រគល់ឲ្យវត្ថុត្រូវកំណត់ជាក់លាក់នៅពេលដែលយកទៅដល់ និងបានប្រគល់ឲ្យជាក់ស្តែងនៅកំណត់ពេលអនុវត្ត ។

កាតព្វកិច្ចដែលម្ចាស់បំណុលត្រូវមកយកវត្ថុត្រូវបានកំណត់ជាក់លាក់នៅ ពេលដែលបានបែងចែករៀបចំសម្រាប់ការប្រគល់ និងបានជូនដំលឹង ទៅម្ចាស់បំណុល។ ទោះបីជាមិនបានជូនដំណឹងក៏ដោយ ប្រសិនបើបានបែងចែក និងរៀបចំសម្រាប់ការប្រគល់រួច ហើយពេលកំណត់អនុវត្តបានមកដល់ វត្ថុនោះក៏ត្រូវបានកំណត់ជាក់លាក់ដែរ ។

## ២.៣ កាតព្វកិច្ចជាប្រាក់ និង កាតព្វកិច្ចមិនមែនជាប្រាក់

### ក. កាតព្វកិច្ចជាប្រាក់

- ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ចជាប្រាក់ នោះកូនបំណុលអាចសងជារូបិយវត្ថុផ្សេងៗ តាមការ ជ្រើសរើសរបស់ខ្លួនបាន ។ ប៉ុន្តែ ម្ចាស់បំណុល និងកូនបំណុលអាចកំណត់ការសងជារូបិយវត្ថុពិសេសក៏បានដែរ។

**ឧទាហរណ៍៖** A បានខ្ចីប្រាក់ ១ លានរៀលពីBដែលមានក្រដាស ៥ ម៉ឺនរៀលចំនួន ២០ សន្លឹក។ នៅពេលសង A អាចសងជាក្រដាស ៥ ម៉ឺនរៀល ចំនួន ២០ សន្លឹក វិញក៏បាន ឬត្រូវសងជាក្រដាស ១០ ម៉ឺនរៀល ចំនួន ១០ សន្លឹក ក៏បាន ឬក្រដាសប្រាក់ផ្សេងពីអ្វីដែលខ្លួនបានទទួលក៏បាន សំខាន់ឲ្យតែតម្លៃលុយដែលត្រូវសងគឺគ្រប់ចំនួន ដែលខ្លួនបានខ្ចី ។

- ក្នុងករណីដែលរូបិយវត្ថុពិសេសដែលកំណត់ជាកម្មវត្ថុនៃកាតព្វកិច្ច លែងជារូបិយវត្ថុស្របច្បាប់ នៅពេលអនុវត្តកាតព្វកិច្ច កូនបំណុលអាចសងជារូបិយវត្ថុណាមួយផ្សេងទៀតបាន ។

**ឧទាហរណ៍៖** ពេលខ្ចីលុយក្រដាស ៥ ដុល្លារ សេរីចាស់ តែយូរទៅដោយគេលែងប្រើ គេក៏ដូរលុយសេរីថ្មីនោះ ពេលសង ត្រូវសងលុយសេរីថ្មី មិនមែនលុយសេរីចាស់ទេ ។

- ចំពោះករណីដែលការ ផ្តល់នូវរូបិយវត្ថុបរទេស ត្រូវបានកំណត់ជាកម្មវត្ថុនៃកាតព្វកិច្ច

**ឧទាហរណ៍៖** បើ A មានកាតព្វកិច្ចត្រូវសងប្រាក់ចំនួន ១០០ ដុល្លារ នោះកូនបំណុលអាចសងជារូបិយវត្ថុបរទេសផ្សេងបានដូចជា ក្រដាសប្រាក់ ១ដុល្លារ , ១០ដុល្លារ, ២០ដុល្លារ, ៥០ដុល្លារ ឬ ១០០ដុល្លារ ជាដើម ។

- ក្នុងករណីដែលបានកំណត់ចំនួននៃកាតព្វកិច្ចជារូបិយវត្ថុបរទេស កូនបំណុលអាចសងជារូបិយវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ដោយគិតទៅតាមអត្រាប្តូររូបិយប័ណ្ណបរទេស នៅកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ចនោះ នៅពេលកំណត់អនុវត្ត ។

**ឧទាហរណ៍៖** A ខ្ចីលុយ B ចំនួន ១០០ ដុល្លារ។ លុះដល់ថ្ងៃសង A យកលុយរៀលចំនួន ៤០ ម៉ឺនរៀលឲ្យទៅ B ប៉ុន្តែ B មិនព្រមទទួល ដោយអះអាងថាអត្រាប្តូរប្រាក់នៅភ្នំពេញគឺ ៤១០០ រៀលក្នុងមួយដុល្លារ ដូច្នេះ A ត្រូវសង ៤១ ម៉ឺនរៀល។

- ករណីពិសេសអំពីកាតព្វកិច្ចជាប្រាក់

នៅពេលដែលកម្មវត្ថុនៃកាតព្វកិច្ច គឺជាការបង់ប្រាក់ នោះកូនបំណុលមិនអាចរួចផុតពីកាតព្វកិច្ចបង់ការប្រាក់ចំពោះការយឺតយ៉ាវឡើយ ទោះបីជាកូនបំណុលអាចបញ្ជាក់ថា ការយឺតយ៉ាវក្នុងការបង់នោះកើតឡើងដោយសារប្រធានសក្តិក៏ដោយ។

ក្នុងករណីដែលកូនបំណុលបានបញ្ជាក់ថាមិនមានកំហុស ចំពោះការមិនអនុវត្តកាតព្វកិច្ច នោះកូនបំណុល អាចរួចផុតពីករណីយកិច្ចបង់ថ្លៃការខូចខាតដែលលើសពីការប្រាក់ដែលយឺតយ៉ាវ ប៉ុន្តែមិនអាចរួចផុតពីករណីយកិច្ច បង់ការប្រាក់ដែលយឺតយ៉ាវនោះទេ ។

**ឧទាហរណ៍៖** A បានខ្ចីប្រាក់ពី B ចំនួន ១០០០ ដុល្លារ ប៉ុន្តែនៅថ្ងៃសងប្រាក់ ដោយសារទឹកជំនន់ ធ្វើឲ្យ A មិនអាច សងប្រាក់ទាន់ពេលកំណត់ លុះមួយខែក្រោយមកទើប A អាចសងប្រាក់បាន។ ដូច្នេះ A ត្រូវសងប្រាក់ដើម និងការ ប្រាក់យឺតយ៉ាវផងដែរ ។

### ខ. កាតព្វកិច្ចមិនមែនជាប្រាក់

**កាតព្វកិច្ចមិនមែនជាប្រាក់** គឺជាកាតព្វកិច្ចដែលឆ្លើយតបទៅនឹងសិទ្ធិទាមទារដែលគ្មានគោលបំណងឲ្យសងជាប្រាក់ដូចជាប្រគល់ អចលនវត្ថុ ឬ ចលនវត្ថុ។

## ២.៤ កាតព្វកិច្ចអនិយ័ត និង កាតព្វកិច្ចដែលមិនអាចជ្រើសរើសបាន

### ក. កាតព្វកិច្ចអនិយ័ត

**កាតព្វកិច្ចអនិយ័ត** សំដៅលើករណីដែលកម្មវត្ថុនៃកាតព្វកិច្ចត្រូវបានកំណត់ដោយការជ្រើសរើសក្នុងចំណោមកម្មវត្ថុច្រើនប្រភេទដែលអាចអនុវត្តបាន ។

**ឧទាហរណ៍៖** នៃកាតព្វកិច្ចអនិយ័តដែលកើតឡើងតាមរយៈកិច្ចសន្យា មានដូចជាករណី A បានធ្វើឲ្យខូចរថយន្តម៉ាក Camry របស់ B ក្រោយមក A និង B បានបង្កើតកិច្ចសន្យាសះជា ដោយព្រមព្រៀងគ្នាថា A ត្រូវប្រគល់រថយន្តម៉ាក Camry ថ្មីឲ្យទៅ B ក្នុងរយៈពេល ១ ខែ ឬ បង់ប្រាក់ចំនួន ១០.០០០ដុល្លារ ជាដើម។

**ឧទាហរណ៍មួយទៀត៖** នៃកាតព្វកិច្ចអនិយ័តដែលកើតឡើងតាមរយៈកិច្ចសន្យា គឺករណីកិច្ចសន្យាសងដោយយកវត្ថុជំនួស។ កិច្ចសន្យាសងដោយយកវត្ថុជំនួស គឺជាការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និង កូនបំណុល ដូចជាករណីជំនួសឲ្យការបង់ប្រាក់ គឺត្រូវប្រគល់ដីវិញ ជាដើម ។ នៅពេលបង្កើត កិច្ចសន្យាសងដោយវត្ថុជំនួស កូនបំណុលអាចជ្រើសរើស សងប្រាក់ ឬ ប្រគល់ដី ។ ។ នេះគឺជាកាតព្វកិច្ចអនិយ័ត ហើយជាឧទាហរណ៍នៃករណីកាតព្វកិច្ចអនិយ័តកើត ចេញពីកិច្ចសន្យាសងដោយយកវត្ថុជំនួស។ មានករណីខ្លះកិច្ចសន្យាសងដោយយកវត្ថុជំនួសត្រូវបានបង្កើតស្រប ពេលជាមួយគ្នានឹងពេលខ្ចីប្រាក់ ករណីខ្លះត្រូវបានបង្កើតនៅក្រោយពេលខ្ចីប្រាក់ តែនៅមុនពេលកំណត់សង ហើយ ករណីខ្លះទៀតត្រូវបានបង្កើតនៅក្រោយពេលកំណត់សងផងដែរ។

ក្នុងករណីដែលមានការសងដោយវត្ថុជំនួស ហើយ តម្លៃនៃតាវកាលិកដើម និងតម្លៃនៃតាវកាលិកវត្ថុជំនួសនោះ ខុសគ្នាខ្លាំង តើចាំបាច់ត្រូវការពារកូនបំណុលដែរ ឬទេ? នៅប្រទេសជប៉ុន មានមធ្យោបាយពីរយ៉ាងដូចខាងក្រោម ដើម្បីការពារកូនបំណុល ៖

**ទី១. កូនបំណុល** អះអាងអំពីមោឃភាពកិច្ចសន្យាសងដោយយកវត្ថុជំនួសដោយយកមូលហេតុផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ហើយបដិសេធនឹងការប្រគល់វត្ថុជំនួស។ នៅក្នុងច្បាប់កម្ពុជា ប្រសិនបើបំពេញលក្ខខណ្ឌ ច្បាប់ អាចធ្វើការអះអាងអំពីមោឃភាពដោយផ្អែកលើភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ (មាត្រា ៣៥៤ កថា ខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) ឬ លុបចោលដោយផ្អែកលើអំពើកេងយកចំណេញហួសហេតុ (មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណី) ហើយបដិសេធក្នុងការប្រគល់វត្ថុជំនួសបាន។

**ទី២. កូនបំណុល** ទាមទារទៅម្ចាស់បំណុលឲ្យសងទឹកប្រាក់ដែលនៅសល់ពីការគណនាតម្លៃនៃតាវកាលិក ដើមនិងតម្លៃនៃតាវកាលិកជំនួស (ទាមទារការបង់ប្រាក់ជម្រះ)។ នៅប្រទេសជប៉ុន កាតព្វកិច្ចនៃការបង់ប្រាក់។ជម្រះ ត្រូវបានបញ្ញត្តនៅក្នុងច្បាប់ពិសេស។ នៅកម្ពុជា ពុំមានច្បាប់នោះទេ ប៉ុន្តែផ្អែកលើការបកស្រាយ អាចធ្វើការ។ ពិចារណាមានលទ្ធភាពធ្វើបាន ឬមិនបាន។

### ខ. កាតព្វកិច្ចដែលមិនអាចជ្រើសរើសបាន

**កាតព្វកិច្ចដែលមិនអាចជ្រើសរើសបាន** គឺសំដៅលើករណីដែលកម្មវត្ថុនៃកាតព្វកិច្ច ដែលបានចុះកិច្ចសន្យា មិនបានកំណត់អំពីជម្រើសច្រើនប្រភេទដែលអាចអនុវត្តបាន ។

**ឧទាហរណ៍៖** ភាគី A មានកាតព្វកិច្ចត្រូវផ្តល់តាវកាលិកជាឡានម៉ាក Camry ឆ្លាម ផលិតនៅឆ្នាំ១៩៩៧ មួយគ្រឿង ឲ្យភាគី B ។

## កថាខ័ណ្ឌទី ៣ អត្រាការប្រាក់ដែលច្បាប់បានកំណត់ និង ការប្រាក់សមាស.

### ក. អត្រាការប្រាក់ដែលច្បាប់បានកំណត់

ប្រសិនបើគូភាគីនៃកិច្ចសន្យា បានយល់ព្រមលើអត្រាការប្រាក់នៅក្នុងកិច្ចសន្យាក្នុងទំហំនៃអត្រាការប្រាក់ ដែលត្រូវបានកម្រិត (១៨%) (មាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី និងមាត្រា ១៧ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីការ អនុវត្តក្រមរដ្ឋប្បវេណី និងប្រការ ១ នៃប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតរបស់ក្រសួងយុត្តិធម៌) អត្រា ការប្រាក់ដែលត្រូវអនុវត្ត គឺជាអត្រាការប្រាក់នៅក្នុងកិច្ចសន្យា។ ចំពោះការខ្ចីបរិភោគធម្មតា អត្រាការប្រាក់គឺត្រូវ បានព្រមព្រៀងដោយគូភាគី ។ ក្នុងករណីដែលភាគីនៃកិច្ចសន្យាបានព្រមព្រៀងថា អត្រាការប្រាក់នឹងត្រូវបង្កើត ឡើង ប៉ុន្តែមិនបានសម្រេចអំពីអត្រាការប្រាក់ទេនោះ អត្រាការប្រាក់ត្រូវគិតចំនួន ៥ ភាគរយ ក្នុងមួយឆ្នាំ ។

### ខ. ការប្រាក់សមាស

**ការប្រាក់សមាស** សំដៅលើការបន្ថែមការប្រាក់លើការប្រាក់ដែលបានបង្កើតរួចហើយ ក្នុងករណីកូនបំណុល មិនព្រមសងការប្រាក់នោះ ។ ដោយសារតែការប្រាក់សមាសបានបន្ថែមបន្ទុក ចំពោះកូនបំណុល ការប្រាក់សមាសនេះអាចធ្វើបានលុះត្រាតែបំពេញលក្ខខណ្ឌកំណត់ ។ ការប្រាក់សមាសនេះ អាចធ្វើទៅបានតែក្នុងករណីដែលលក្ខខណ្ឌទាំង ២ ខាងក្រោមត្រូវបានបំពេញ។

**ទី ១** មានការយឺតយ៉ាវ មិនបានបង់ការប្រាក់សម្រាប់រយៈពេលចាប់ ពី ១ ឆ្នាំឡើងទៅ។

**ទី២** ម្ចាស់បំណុលបានដាស់តឿនឲ្យសង តែកូនបំណុលមិនព្រមសង ។

ប្រសិនបើលក្ខខណ្ឌទាំង២ខាងលើនេះត្រូវបានបំពេញ ម្ចាស់បំណុលអាចបញ្ចូលការប្រាក់ទៅក្នុងប្រាក់ដើម ដោយធ្វើការបង្ហាញឆន្ទៈទៅកូនបំណុល។ ការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុលក្នុងការ បញ្ចូលការប្រាក់ទៅក្នុងប្រាក់ដើមលើសពីបញ្ញត្តិក្នុងមាត្រានេះ (ដូចជា ការព្រមព្រៀងក្នុងការបញ្ចូលការ ប្រាក់ទៅក្នុងប្រាក់ដើមជារៀងរាល់ខែជាដើម) ត្រូវទុកជាមោឃៈ។

**ឧទាហរណ៍៖** A បានខ្ចីប្រាក់ពី B ចំនួន ១000 ដុល្លារ ដោយយកការប្រាក់ ៨% ក្នុងមួយឆ្នាំ ប៉ុន្តែ A មិនបាន បង់ការ ប្រាក់អស់រយៈពេល ១ឆ្នាំ។ ប្រសិនបើ A ខកខានមិនបានបង់ការប្រាក់បន្ទាប់ពីបានទទួលការដាស់តឿនពី B នោះ B អាចបូកការប្រាក់បញ្ចូលទៅក្នុងប្រាក់ដើមបាន។

# ជំពូកទី ២
# ការលត់កាតព្វកិច្ច

# ជំពូកទី ២ . ការរលត់កាតព្វកិច្ច

## ផ្នែកទី១. ការសង

### កថាខ័ណ្ឌទី ១. គោលការណ៍ទូទៅស្តីពីការសង

ជាគោលការណ៍ការសងត្រូវធ្វើឡើង ដោយកូនបំណុលក្នុងករណីដែលបានធ្វើកិច្ចសន្យាជាមួយនិងម្ចាស់បំណុល ហើយកូនបំណុលជាអ្នកអនុវត្តកាតព្វកិច្ចដោយខ្លួនស្រមតាមកិច្ចសន្យាដែលបានចែង ជាពិសេសនោះការសងនេះដែល ធ្វើឡើងដោយកូនបំណុលក៏ក្លាយជាការសងមួយដែលមានអានុភាពតាមផ្លូវច្បាប់។ ក៏ប៉ុន្តែនៅមានបញ្ហាមួយចំនួនដែលកើតឡើង និងចោទជាបញ្ហាថាអំពីការសង តើបុគ្គលណាខ្លះដែលក្លាយអាចជាការសងបាន និងម្យ៉ាងវិញទៀតចំពោះការសងដែលធ្វើឡើងដោយ តតិយជនអាចសងជំនួសកូនបំណុលបាន ឬមិនបានក៏អាស្រ័យ? ក៏ប៉ុន្តែជាគោលការណ៍តតិយជនក៏អាចសងជំនួសកូនបំណុលក៏បានដែរ ដោយធ្វើតាមការព្រមព្រៀងដែលធ្វើឡើងដោយម្ចាស់បំណុល និង កូនបំណុល ដែលមានចែងនៅក្នុហកិច្ចសន្យា និងកករណីពិសេសមួយចំនួនទៀត។

#### ១.១ អ្នកសង

ជាធម្មតា អ្នកសងត្រូវធ្វើឡើងដោយកូនបំណុល តែប្រសិនបើអ្នកសង មិនមែនជាកម្មសិទ្ធ ឬ មិនមានសមត្ថភាពចាត់ចែងចំពោះវត្ថុដែលជាកម្មវត្ថុនៃកាសងនោះទេ ការសងរបស់អ្នកសងនោះគឺមិនមានសុពលភាពទេ ។

ក្នុងករណីដែលមានចែងនៅក្នុងមាត្រា ២៣៤ ក្នុងក្រមរដ្ឋប្បវេណីបានចែង អំពីអ្នកសង ដែលជាកូនបំណុល ដែលតតិយជនមិនអាចសងជំនួសកូនបំណុលបានទេ ។ ហើយប្រសិនបើកូនបំណុលខ្លួនជាអ្នកអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាដោយខ្លួនឯង ដែលគ្មានភាពសមរម្យ ក្នុងការទទួលស្គាល់សកម្មភាពដែលតតិយជនធ្វើជំនួសកូនបំណុលថាជាការសងទេ ។

**ឧទាហរណ៍៖** កិច្ចសន្យាដែលផ្តល់ជាសេវាការងារ ឬ កិច្ចសន្យាគូររូបជាដើម ។

ម្យ៉ាងវិញទៀតក្នុងករណីដែលកិច្ចព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល មិនអនុញ្ញាតអោយ តតិយជនសងជំនួសកូនបំណុល ។ តតិយជនអាចសងជំនួសកូនបំណុលបានទោះបីជាការសងនោះផ្ទុយនឹងឆន្ទះរបស់ភាគីម្ខាងនៃកិច្ចសន្យាក៏ដោយ លើងលែងមានកិច្ចព្រមព្រៀងរវាងភាគី ដែលពាក់ព័ន្ធកំណត់ថា តតិយជនមិនអាចសងជំនួសកូនបំណុលទេ ។ ប្រសិនបើតតិយជនសង តតិយជននោះត្រូវធ្វើលទ្ធកម្មនូវសិទ្ធរបស់ម្ចាស់បំណុល តាមប្រព័ន្ធឧបាទេសកម្មដោយការសង ហើយក្នុងករណីជាក់ស្តែងខ្លះ តតិយជនដែលបានសងធ្វើការប្រមូលបំណុលក្នុងនាមម្ចាស់បំណុលយ៉ាងតឹងរឹងជាងម្ចាស់ដើម ដូចច្នេះការអនុញ្ញាតអោយតតិយជនសង ឬ មិន

អោយនោះ នឹងមានឥទ្ធិពលខ្លាំងទៅលើផងប្រយោជន៍របស់កូនបំណុល ។ ប្រសិនបើតតិយជនសងបានធ្វើការសងជំនួសកូនបំណុលដោយមានសុពលភាព កាតព្វកិច្ចត្រូវរលត់ដោយការសងនោះ ហើយកូនបំណុលត្រូវរួចផុតពីបន្ទុកនៃកាតព្វកិច្ច ប៉ុន្តែតតិយជយដែលបានសងត្រូវទទួលបានសិទ្ធទាមទារសំណងពីកូនបំណុល ដោយផ្អែកលើសេចក្ដីចម្រើនឥតហេតុ ជាដើម ។ ហេតុដូច្នេះ ការសងដោយតតិយជន មានលក្ខណៈស្រដៀងគ្នាច្រើនទៅនឹងការផ្លាស់ប្ដូរម្ចាស់បំណុល ។ ប៉ុន្តែក្នុងករណីទំនាក់ទំនងនៃកិច្ចសន្យាអញ្ញមញ្ញ (កិច្ចសន្យា ដែលភាគីមានបន្ទុកបំពេញកាតព្វកិច្ចទៅវិញទៅមកដូចជា កិច្ចសន្យាម៉ៅការ ភតិសន្យា កិច្ចសន្យាលក់ទំនិញ...។) ប្រសិនបើតតិយជនតតិយជនសង ទំនាក់ទំនងស្មុគស្មាញនៃភាគីដែលពាក់ព័ន្ធ នឹងកើតមានឡើង ។

**ឧទាហរណ៍៖** ក្នុងករណីដែលតតិយជនបានអនុញ្ញាតពីនិយោជកឱ្យផ្ដល់នូវពលកម្មតាមកិច្ចសន្យា បញ្ហាដែលកើតមានឡើង គឺត្រង់ចំណុចថា តើនិយោជកគួរបង់ប្រាក់ឈ្នួលអោយទៅអ្នកណា ។ ទោះបីជាការសងដោយតតិយជនក៏ដោយ ក៏ទំនាក់ទំនងនៃកិច្ចសន្យាពុំមានការផ្លាស់ប្ដូរលក្ខខណ្ឌអ្វីឡើង ដូច្នេះ និយោជកត្រូវបង់ប្រាក់ឈ្នួលអោយទៅកូនបំណុលដើមនៃកិច្ចសន្យា (កូនបំណុលមានសិទ្ធទាមទារប្រាក់ឈ្នួល) ។ ប៉ុន្តែក្នុងទំនាក់ទំនងរវាងកូនបំណុល បុងតតិយជនវិញនោះ ការដែលកូនបំណុលទទួលប្រាក់ឈ្នួល ត្រូវក្លាយជាសេចក្ដីចម្រើនឥតហេតុ ។ ហេតុដូច្នេះ កូនបំណុលត្រូវប្រគល់ប្រាក់ឈ្នួលទៅអោយតតិយជននោះ ។

### ១.២ សមត្ថភាពចាត់ចែងរបស់អ្នកសង

ជាទូទៅអ្នកសងត្រូវមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការសងវត្ថុដែលជាកម្មវត្ថុនៃការសង តែប្រសិនបើ អ្នកសងមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការសងវត្ថុដែលជាកម្មវត្ថុនៃការសង នោះការសងមិនមានសុពលភាពនោះទេ ។

**ឧទាហរណ៍៖** ក្នុងករណីដែលអ្នកលក់ **ក** លក់ក្របីមួយក្បាលអោយទៅអ្នកទិញ **ខ** ប្រសិនបើអ្នកលក់ **ក** គ្មានកម្មសិទ្ធលើគោដែលត្រូវសងអោយទិញអោយអ្នកទិញ **ខ** ការសងនោះមិនមានជាការសងដែលមានសុពលភាពទេ ។ ក្នុងករណីដែល **គ** ដែលជាកម្មសិទ្ធលើក្របីនោះ អាចយកក្របីដែលជាកម្មសិទ្ធរបស់ខ្លួនពីអ្នកទិញ **ខ** វិញបាន ។ ប៉ុន្តែប្រសិនបើ **ក** មិនបានប្រគល់ក្របីទៅអោយអ្នកទិញ **ខ** នូវក្របីដែលជាកម្មសិទ្ធនោះទេ អ្នកសង **ក** នោះមិនអាចយកក្របី (របស់ម្ចាស់កម្មសិទ្ធ **គ**) ដែលខ្លួនបានប្រគល់ជាការសងអោយអ្នកទិញបានទេ ។

ចំពោះអ្នកដែលមិនមានសម្ថភាពសងក្នុងការចាត់ចែងវត្ថុដែលជាកម្មវត្ថុនៃការសងទេ មានដូចជាករណីដែលការសងត្រូវបានធ្វើដោយអនីតិជន ឬជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ជាដើម ។ ប៉ុន្តែបើទោះជាអនីតិជន ជាអាទិ៍ មានកម្មសិទ្ធលើវត្ថុនោះក៏ដោយ ក៏សកម្មភាពសងដែលខ្លួនបានធ្វើ អាចត្រូវបានលុបចោលដោយសារមូលហេតុនៃការកម្រិតសម្ថភាព ។

ក្នុងករណីពិសេសដែលការសងត្រូវបានធ្វើឡើងក្នុងរូបភាពជាប្រាក់ កម្មសិទ្ធលើប្រាក់ គឺជាបញ្ហាទាក់ទងនឹងច្បាប់ស្តីពីសិទ្ធប្រត្យក្ស ប៉ុន្តែជាទូទៅការចរាចរនៃប្រាក់ត្រូវបានការពារដោយគ្រប់គ្រាន់ ។ ម្ចាស់បំណុលដែលទទួលបានប្រាក់មិនចាំបាច់បញ្ជាក់ **កូនបំណុលមានកម្មសិទ្ធលើប្រាក់នោះទេ** ព្រោះថា ប្រសិនបើម្ចាស់បំណុលចាំបាច់ត្រូវបញ្ជាក់អំពីសិទ្ធលើប្រាក់នោះរាល់ពេល ប្រាក់នឹងមិនអាចធ្វើចរាចរបានទូលំទូលាយទេ ។ ដូច្នេះ ក្នុងករណីដែលការសងត្រូវធ្វើឡើងជាប្រាក់ ជាគោលការណ៍ ការសងនោះត្រូវមានសុពលភាព ទោះបីជាអ្នកសង ប្រើប្រាស់ដែលខ្លួនបានអំពីការលួច ហើយធ្វើជាការសងក៏ដោយ ។ ហើយចំពោះ**មាត្រា ៤៣៥ ក្នុងក្រមរដ្ឋប្បវេណីចែងអំពី សមត្ថភាពចាត់ចែងរបស់អ្នកសងជាអាទិ៍** ក៏ពុំមានការចែងពីចំណុចនេះអោយបានច្បាស់លាស់ដែរទេ ។

## ១.៣ សិទ្ធទទួលការសង និងការកម្រិតសិទ្ធទទួលការសងដោយការរឹបអូស

### ក. សិទ្ធទទួលការសង

ចំពោះការសងមានសុពលភាព លុះត្រាតែការសងនោះធ្វើឡើងចំពោះបុគ្គលដែលមានសិទ្ធទទួលការសងនោះ ។ ហើយក្នុងករណីដែលម្ចាស់បំណុលរក្សាសិទ្ធក្នុងការទាមទារ ឬមិនអាស្រ័យនោះអាស្រ័យទៅតាមកិច្ចសន្យារវាងម្ចាស់បំណុល និងបុគ្គលដែលទទួលបាននូវសិទ្ធអំណាចក្នុងការសង ដោយសារការសងនឹងគ្មានសុពលភាពប្រសិនបើការសងមិនធ្វើបំពោះបុគ្គលដែលមានសិទ្ធអំណាចក្នុងការទទួលការសង ការសងត្រូវចាំបាច់ធ្វើម្តងទៀតប្រសិនបើម្ចាស់បំណុលទាមទារការសងនោះ ។ ក្នុងករណីនេះកូនបំណុលត្រូវសងម្តងទៀត ។

ប៉ុន្តែចំពោះបុគ្គលដែលមានសិទ្ធទទួលការសងក្រៅពីម្ចាស់បំណុលរួមាន ៖

- បុគ្គលដែលទទួលសិទ្ធពីម្ចាស់បំណុលឱ្យទទួលការសងក្នុងនាមខ្លួនឯងផ្ទាល់ (ជាទូទៅបុគ្គលនេះក៏ទទួលបាននូវសុទ្ធអំណាចក្នុងការទាមទារអោយកូនបំណុលធ្វើការសងដោយសកម្មដែរ)
- អ្នកតំណាងដែលទទួលការប្រគល់សិទ្ធពីម្ចាស់បំណុលអោយទទួលការសង
- បុគ្គលដែលត្រូវបានផ្តល់សិទ្ធអំណាចក្នុងការប្រមូលដោយតុលាការដោយរឹមអូសសិទ្ធលើបំណុលរបស់ម្ចាស់បំណុល

### ខ. ការកម្រិតសិទ្ធទទួលការសងដោយការរឹបអូស

ក្នុងករណីដែលសិទ្ធលើបំណុលត្រូវបានរឹបអូស កូនបំណុលត្រូវមានករណីកិច្ច មិនអាចសង ឬសងតាមដីការសម្រេចរឹបអូសរបស់តុលាការ កម្រិតត្រឹមតែសិទ្ធអំណាចរបស់ម្ចាស់បំណុលក្នុងការទទួលសងដោយផ្ទាល់តែប៉ុណ្ណោះ ។ ដូច្នេះដីការសម្រេចរឹបអូសរបស់តុលាការ និងមិនអាចហាមឃាត់សកម្មភាពនៃការសងរបស់កូនបំណុលដោយផ្ទាល់បានទេ ។

ឧទាហរណ៍៖ ប្រសិនបើ □ រឹបអូសសិទ្ធលើបំណុលរបស់ម្ចាស់បំណុល □ ទំនាក់ទំនងដែលកើតឡើង មានដូចខាងក្រោម ៖

ម្ចាស់បំណុលនៃការអនុវត្ត → □

កូនបំណុលនៃការអនុវត្ត → □

កូនបំណុលទី ៣ → □

ក្នុងករណីនេះសិទ្ធអំណាចរបស់ម្ចាស់បំណុល □ ក្នុងការទទួលការសង ត្រូវបានកម្រិត ហើយទោះបីជាកូនបំណុលទី៣ □ សងចំពោះម្ចាស់បំណុល □ ក៏ដោយក៏ការសងនោះមិនមែនជាការសងមានសុពលភាពដែរ ។

ប៉ុន្តែក្នុងករណីដែលកូនបំណុលត្រូវសងនូវកាតព្វកិច្ចភ្លាមៗ ប្រសិនបើម្ចាស់បំណុលទាមទារការសងនោះ តែកូនបំណុលបែរជាកូនបំណុលសងទៅបុគ្គលមើលទៅហាក់ដូចជាម្ចាស់បំណុល(ឧបាភោគីនៃសិទ្ធលើបំណុល) តែក្នុងការស្រាវជ្រាវបែរជាមិនមែនម្ចាស់បំណុលទៅវិញ ហើយត្រូវបានទាមទារអោយសងទៅម្ចាស់បំណុលពិតប្រាកដ នោះយើងមើលទៅបន្ទុកកូបបំណុលហាក់ដូចជាធ្ងន់ហួសហេតុ ។ តែប្រសិនបើបុគ្គលមើលទៅហាក់ដូចជាម្ចាស់បំណុលមានកាន់នូវលិខិតបញ្ជាក់សិទ្ធលើបំណុល ឬសៀវភៅគណនីធនាគារ នោះចាំបាច់ការពារកូនបំណុលដោយចាត់ទុកថា ការសងនោះមានសុពលភាព ។ ម្ចាស់បំណុលអាចទាមទារអោយកូនបំណុលសងម្តងទៀតបាន ប្រសិនបើកូនបំណុលធ្វើការសងដោយគ្មានការប្រុងប្រយ័ត្ន ។ តែប្រសិនបើធនាគារ សងទៅបុគ្គលដែលមកជាមួយនូវសៀវភៅធនាគារ ធនាគារនោះត្រូវពិនិត្យយ៉ាងប្រុងប្រយ័ត្នបំផុត នូវហត្ថលេខាផ្សេងៗ តែក្នុងករណីដែលហត្ថលេខាបែរជាក្លែងក្លាយ បន្ទាប់ពីការពិនិត្យយ៉ាងប្រុងប្រយ័ត្ន អ្នកសងត្រូវបានចាត់ទុកថាត្រូវបានសងដោយសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរ និងការសងត្រូវចាត់ទុកថាមានសុពលភាពដែរ (ការធ្វេសប្រហែសរបស់ធនាគារដោយមិនពិនិត្យលិខិតស្នាម និងហត្ថលេខាដោយប្រុងប្រយ័ត្នហើយអាចចាត់ទុកធាជាកំហុសដ៏ធ្ងន់ធ្ងររបស់ធនាគារផងដែរ)។

ប្រសិនបើការសងទៅឧបាភោគីនៃសិទ្ធលើបំណុល □ មានសុពលភាពនោះកាតព្វកិច្ចរបស់កូនបំណុល □ ត្រូវរលត់ហើយម្ចាស់បំណុលពិតប្រាកដ □ មិនអាចទាមទារអោយ កូនបំណុល □ សងបានទេ ។ ម្ចាស់បំណុលពិតប្រាកដ □ អាចទាមតារអោយប្រគល់វិញនូវសេចក្តីចម្រើនឥតហេតុពី ឧបាភោគី □ ដែលទទួលការសងប៉ុណ្ណោះ ។

## ១.៤ ទិធីសង

កូនបំណុលត្រូវសងតាមខ្លឹមសារនៃកាតព្វកិច្ច និង គោលបំណងនៃកិច្ចសន្យា ហើយស្របតាមគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ ។ ម្យ៉ាងទៀតប្រសិនបើការសងត្រូវធ្វើឡើងជាក្រដាសប្រាក់ (រូបិយវត្ថុ) ប្រសិនបើមានភាពស្របច្បាប់ក្នុងការប្រើប្រាស់រូបិយវត្ថុ ត្រូវបានធ្វើជាការសងហើយ មិនផ្ទុយនឹងគោលការណ៍សុចរិត និងភាពស្មោះត្រង់ការសងនោះចាត់ទុកមានសុពលភាព ប៉ុន្តែប្រសិនបើការសងនោះធ្វើឡើងបង្កមានភាពលំបាកដល់ ម្ចាស់បំណុលទោះបីជាការសងនោះស្របតាមច្បាប់ក្នុងការប្រើប្រាស់រូបិយវត្ថុក៏ដោយ ក៏ការសងនោះត្រូវចាត់ថាផ្ទុយនឹងគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ ។

**ឧទាហរណ៍៖** កូនបំណុលត្រូវសងម្ចាស់បំណុល ១លានដុល្លារ តែការសងនោះបែរជាយកក្រដាស ១ដុល្លាវិញធ្វើអោយការលំបានដល់ម្ចាសបំណុលទៅវិញ ។

បញ្ហាទាក់ទងម៉ោងសង អាចកំណត់តាមទំនៀមទម្លាប់គឺនៅចន្លោះ ថ្ងៃរះ និង ថ្ងៃលិច ក៏ប៉ុន្តែបើនៅតាមតំបន់ដែលមិនមានទំនៀមទម្លាប់ត្រឹមត្រូវ ម៉ោងនៃការសងជាគោលការណ៍ត្រូវធ្វើឡើងនៅពេល **ម៉ោងពេលធ្វើការធម្មតា ។** ចំពោះបញ្ហាម្យ៉ាងវិញទៀតពាក់ព័ន្ធនិង ពេលនៃការសង ការសងមុនពេលកំណត់ ត្រូវបានធ្វើឡើងក្នុងករណីដែលមិនធ្វើអោយខូចប្រយោជន៍រវាងកូនបំណុល និង ម្ចាស់បំណុល ប៉ុន្តែក្នុងករណីខ្លះអាចធ្វើអោយខូចប្រយោជន៍ដល់ម្ចាស់បំណុល(ចំពោះកាត្តព្វកិច្ចដែលមានគោលបំណងសងជាប្រាក់) ហើយក៏មិនសមហេតុផលដែលម្ចាស់បំណុលទទួលការសងមុនពេលកំណត់។

ទីកន្លែងដែលត្រូវសងចំពោះក្នុងការលក់ទិញវត្ថុជាក់លាក់មួយចំនួន ដូចជាវត្ថុបូរាណជាដើម អ្នកលក់អាចប្រគល់វត្ថុបូរាណនោះទៅអ្នកទិញនៅកន្លែងដែលវត្ថុបូរាណនោះស្ថិតនៅ នៅពេលធ្វើកិច្ចសន្យា ។ ក្នុងករណីដែលការទិញបូរាណក្នុងហាង ហាងគឺជាទីកន្លែងដែលត្រូវប្រគល់វត្ថុបូរាណនោះ ។ ចំពោះចំណុចដែលគួរកត់សម្គាល់គឺ អត្ថន័យនៃការសន្យាដែលអ្នកលក់ និងអ្នកទិញ ព្រមព្រៀងគ្នាថាអ្នកលក់ត្រូវដឹកវត្ថុបូរាណនោះទៅលំនៅឋានរបស់អ្នកទិញវិញ ប្រសិនបើមានការព្រមព្រៀងគ្នាបែបនេះ ទីកន្លែងដែកត្រូវសងគឺលំនៅឋានរបស់អ្នកទិញវិញ ហើយការសងមិនត្រូវនបានធ្វើឡើងទេរហូតដល់វត្ថុបូរាណនោះបានដឹកដល់លំនៅឋានរបស់អ្នកទិញ ។ ប៉ុន្តែក្នុងករណីដែលមានការខូចខាតក្នុងពេលដែលដឹកជញ្ជូនតាមផ្លូវ ហើយកើតមុនពេលនៃការសងនេះជាបញ្ហានៃការមិនអនុវត្តកាត្តព្វកិច្ច ឬការទទួលបន្ទុលហានិភ័យ ។ ផ្ទុយទៅវិញក្នុងករណីដែលមានការធ្វើកិច្ចសន្យាដែលធ្វើឡើងក្នុងហាង ហើយមានការចុះកិច្ចមួយទៀតនៃការដឹកជញ្ជូន ប្រសិនបើមានការខូចខាតតាមផ្លូវ បញ្ហានេះ តើអ្នកណាជាអ្នកសងការខូចខាតដែលបង្កឡើងដែលបង្កមកពីសេវាដឹកជញ្ជូន ។

ចំពោះការសងដែលត្រូវធ្វើឡើងនៅលំនៅឋានរបស់ម្ចាស់បំណុល ក្នុងករណីដែលកាតព្វកិច្ចរបស់អ្នកលក់ទិញវត្ថុជាក់លាក់ កាតព្វកិច្ចត្រូវធ្វើសកម្មភាព ឬ មិនធ្វើសកម្មភាពអ្វីមួយ កាតព្វកិច្ចសងជាប្រាក់ ជាអាទិ៍ ។ ហើយប្រសិនបើមានការព្រមព្រៀងគ្នានូវទីកន្លែងដែលត្រូវសងជាក់លាក់មួយ ត្រូវសងនៅទីកន្លែនោះ ដោយស្របតាមឆន្ទៈភាគីនៃកិច្ចសន្យា ។ អ្នកសងអាចទាមទារអោយអ្នកទទួលការសងចេញនូវលិខិតបញ្ជាក់នូវការទទួលការសងនោះបាន ហើយកូនបំណុលក៏អាចបដិសេធ រហូតដល់ម្ចាស់បំណុលចេញលិខិតបញ្ជាក់នៃការសងនោះផងដែរ ។

## ក. ការសងមួយភាគ

ម្ចាស់បំណុលមិនមានករណីទទួលការសងមួយភាគទេ តែប្រសិនបើមានការសន្យាពិសេសបន្តិចបន្តួចដែលធ្វើឡើងដោយផ្ទាល់មាត់ ឬក្នុងកិច្ចសន្យានោះ ការសងមួយភាគអាចធ្វើទៅបាន ។ តែបើម្ចាស់បំណុលព្រមទទួលការសងមួយភាគ ការសងនោះចាត់ទុកមានសុពលភាព ហើយកាតព្វកិច្ចក្នុងកិច្ចសន្យាត្រូវកាត់បន្ថយមកត្រឹមតុល្យភាពនៃចំនួនសរុប ។

ឧទាហរណ៍៖ កូនបំណុលដែលមានកាតព្វកិច្ចសងក្នុងតម្លៃ ១០០០ដុល្លារ ប៉ុន្តែដោយសារកូនបំណុលប៉ុន្តែកូនបំណុលអាចរៀបចំតែទឹកប្រាក់ចំនួន ៦០០ដុល្លា ប៉ុណ្ណោះ កូនបំណុលស្នើផ្តល់ការសង ៦០០ដុល្លា ទៅម្ចាស់បំណុល ។ ក្នុងករណីនេះម្ចាស់បំណុលមិនមានករណីកិច្ចទទួលការសងមួយភាគទេ ។ ប្រសិនបើម្ចាស់បំណុលបដិសេធទទួលការសងមួយភាគ ការប្រាក់ត្រូវគណនាសរុប ចំនួន ១០០០ដុល្លារ ដោយសារមិនទាន់មានការសងពេញលេញចំនួលសរុបដែលត្រូវសង ។

ប្រសិនបើការថ្ងៃក្រោយមានវិវាទនិងកាតព្វកិច្ចរវាងម្ចាស់បំណុល និងកូនបំណុល មានករណីខ្លះម្ចាស់បំណុលមិនព្រមទទួលការសងមួយភាគនោះ ដោយអះអាងថាកូនបំណុលមិនបានសងតាមគ្រប់ចំនួនដែលត្រូវសង ក្នុងករណីនេះកូនបំណុលអាចទប់ស្កាត់មិនអោយមានការទាមទារអោយទទួលខុសត្រូវចំពោះកាតព្វកិច្ចគ្រប់ចំនួន ដោយធ្វើការតម្កល់ ។

## ខ. ការសងដោយយកវត្ថុជំនួស

ការសងដែលកូនបំណុលផ្តល់ការសងតាវលិកផ្សេង ពីតាវលិកដែលជាបន្ទុកដើមរបស់ខ្លួនជាជំនួសវិញ ដោយមានការយល់ព្រមពីម្ចាស់បំណុល តាវលិកនៃការសងនោះត្រូវចាត់ទុកមានអានុភាពដូចតាវលិកដើមដែរ ។ ការព្រមព្រៀងនៃការសងវត្ថុជំនួសអាចមានតាំងពីដំបូងនៃកិច្ចសន្យា ឬ មានករណីកិច្ចព្រមព្រៀងនៅពេលកំណត់នៃការសង ហើយអាចផ្តល់ការជ្រើសរើសទៅភាគីម្ខាង ឬសងខាងក៏បាន ។ ចំពោះការសង កាត្តកិច្ចដោយផ្តល់តាវលិក ឬ ការសងវត្ថុជំនួស ត្រូវសងដោយជម្រើសរបស់បុគ្គលដែលមានសសិទ្ធជ្រើសរើស ក្នុងករណី

ដែលការព្រមព្រៀងសងដោយវត្ថុជំនួសត្រូវបានធ្វើឡើងដោយភាគីដើម្បីធានាសិទ្ធលើបំណុល ជាធម្មតា ម្ចាស់បំណុលមានសិទ្ធជ្រើសរើស ។ តែប្រសិនបើមិនមានាការកណត់នៃការសងជាសាច់ប្រាក់ទេ ពេលកំណត់សងម្ចាស់បំណុល ជ្រើសរើសការសងដោយយកវត្ថុជំនួស និងការទាមទារដោយយកវត្ថុមកជំនួស ។

**ឧទាហរណ៍៖** កូនបំណុលាមានកាតព្វកិច្ចដែលមានតម្លៃ ១០០០០ដុល្លារ ដោយការសងយកដីជំនួសជាការសងជាសាច់ប្រាក់វិញ ។

## កថាខណ្ឌទី២. ការកាត់បំណុល

ជាគោលការណ៍ការកាត់បំណុលកំណត់ដោយ កូនបំណុលជ្រើសរើស និងប្រសិនបើកូនបំណុលមិនមានការជ្រើសរើសនោះទេ ការកាត់បំណុលតាមវិធីដែលច្បាប់បានកំណត់។ ការកាត់បំណុល គឺមានន័យថានៅពេលដែលកូនបំណុលដល់ពេលកំណត់មួយដែលត្រូវសង កាតព្វកិច្ច ឬ វត្ថុអ្វីមួយ ទៅម្ចាស់បំណុល តាមការកំណត់នៅក្នុងកិច្ចសន្យានៅមុនពេល ឬក្រោយពេលនៃការសង ឬត្រូវសងនូវកាតព្វកិច្ច ឬវត្ថុអ្វីមួយមុន ឬក្រោយ ។

### ២.១. ការកាត់បំណុលដោយការជ្រើសរើស និងការកាត់បំណុលតាមច្បាប់កំណត់

#### ២.១.១. ការកាត់បំណុលដោយការជ្រើសរើស

ក្នុងករណីដែលកូនបំណុលត្រូវទទួលបន្ទុកនូវ កាតព្វកិច្ចច្រើនដែលមានគោលបំណងប្រភេទដូចគ្នាចំពោះម្ចាស់បំណុលតែម្នាក់ ប្រសិនបើតាវលិកដែលត្រូវផ្តល់ជាការសង នូវមិនទាន់គ្រប់គ្រាន់ដើម្បីអោយកាតព្វកិច្ចទាំងអស់រលត់នៅឡើងទេ អ្នកសងអាចជ្រើសរើសយកកាតព្វកិច្ចដែលត្រូវកាត់ដោយការសង នៅពេលដែលខ្លួនផ្តល់តាវលិកបាន ។ ប្រសិនបើអ្នកសងមិនបានជ្រើសរើសដូចខាងលើទេ អ្នកទទូឡការសងអាចជ្រើសរើសយកកាតព្វកិច្ចដែលត្រូវកាត់ដោយការសងនោះ នៅពេលដែលខ្លួនទទូលការសង ។ហើយបើអ្នកសងតវ៉ានោះការកាត់បំណុលត្រូវធ្វើឡើងដោយច្បាប់កំណត់ ។

ការកាត់បំណុលត្រូវធ្វើឡើង ដោយការជូនដំណឹងទៅភាគីម្ខាងទៀត ។ [9]

**ឧទាហរណ៍៖** កូនបំណុល **ក** មានកាតព្វកិច្ចចំពោះម្ចាស់បំណុល **ខ** ( **១** ) ចំនួន ៥០០ដុល្លារ សម្រាប់ថ្លៃលក់ (**២**) ៣០០ដុល្លារ ជាកាតព្វកិច្ចនៃកិច្ចសន្យាខ្ចីបរិភោគ ។ ប្រសិនបើកូនបំណុល **ក** បង់ជូនម្ចាស់បំណុល ៥០០ ដុល្លារ បញ្ហាដែលកើតមានឡើងគឺ តើត្រូវកាត់ចំពោះកាតព្វកិច្ចណាមួយក្នុងចំណោមកាតព្វកិច្ចទាំង ២ ខាងលើ ។ ប្រសិនបើសងត្រឹមតែ ម្ចាស់បំណុល ៥០០ដុល្លារត្រូវមានបទដ្ឋានជាក់លាក់ណាមួយសម្រាប់កាត់បំណុល ។ ហើយបើកូនបំណុលសងទាំង ៨០០ដុល្លារ ទាំងអស់នោះមិនមានជាបញ្ហាចោទនោះទេ ។

### ២.២.២ ការកាត់បំណុលតាមច្បាប់កំណត់( ៤៥០ )

ក្នុងករណីដែលគ្មានភាគីណាមួយយណាមួយធ្វើការជ្រើសរើសកាតព្វកិច្ចដែលត្រូវកាត់ដោយការសង ការកាត់បំណុលត្រូវធ្វើឡើងតាមបញ្ញាត្តិច្បាប់បានកំណត់ នៅក្នុងក្រមរដ្ឋប្បវេណី ។

- ក្នុងចំណោមកាតព្វកិច្ចទាំងអស់ ប្រសិនបើមានកាតព្វកិច្ចមួយណាដែលត្រូវដល់ពេលសងបានមកដល់ និង កាតព្វកិច្ចផ្សេងទៀតមិនទាន់មកដល់នោះ ត្រូវកាត់កាតព្វកិច្ចដែលដល់ពេលកំណត់ជាមុនសិន ។ ( ចំណុចនេះដោយផ្អែកលើ ប្រសិនបើកាតព្វកិច្ចដល់ពេលកំណត់ ការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាងបានកើតឡើង ហេតុដូច្នេះ ការសងចំពោះកាតព្វកិច្ចដែលដល់ពេលកំណត់ជាមុន មានផលប្រយោជន៍សម្រាប់កូនបំណុល )
- ប្រសិនបើពេលកំណត់ត្រូវសងកាតព្វកិច្ចទាំងអស់បានមកដល់ហើយ ឬ មិនទាន់មកដល់នៅឡើង ត្រូវកាត់កាតព្វកិច្ចដែលមានផលប្រយោជន៍ក្នុងការសងច្រើនជាងគេ សម្រាប់កូនបំណុល ។ (ផ្អែកលើគំនិតថា ប្រសិនបើមានកាតព្វកិច្ចណាមួយ បានបង្កើតការប្រាក់ក្នុងកំឡុងពេលនៃការយឺតយ៉ាវដែលមាន ចំនួនច្រើនការសងការប្រាក់ជាមុននោះសមស្របនិងផលប្រយោជន៍នៃកូនបំណុល ។ តែមិនងាយស្រួលទេ ក្នុងការវិនិច្ឆ័យថា តើកិច្ចសន្យាមួយណាសំខាន់ជាងកិច្ចសន្យាមួយណា ប្រសិនបើការនិបសងឈានដល់ការរំលាយកិច្ចសន្យា)
- ប្រសិនបើផលប្រយោជន៍ក្នុងការសងមានភាពស្មើគ្នាចំពោះកូនបំណុលត្រូវកាត់កាតព្វកិច្ចដែលពេលកំណត់ត្រវសងបានមកដល់មុនគេ ឬនិងមកដល់មុនគេ ។ (ផ្អែកលើគំនិតថា ប្រសិនបើការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវ មានចំនួនដូចគ្នានិងផលប្រយោជន៍នៃការសង ក៏ដូចគ្នាចំពោះកូនបំណុលដែរ ប៉ន្តែជាធម្មតាកូនបំណុលនិងសងចំពោះកាតព្វកិច្ចដែលដល់ពេលកំណត់មុន ឬនឹងដល់ពេលកំណត់)
- ប្រសិនបើកាតព្វកិច្ចទាំងអស់ មានផលប្រយោជន៍ក្នុងការសងដូចគ្នាចំពោះកូនបំណុល និងពេលកំណត់ត្រូវសងដូចគ្នា ត្រូវកាត់ដោយគិតជាសមាមាត្រចំនួនទឹកប្រាក់នៃកាតព្វកិច្ចនីមួយៗ។

### ២.៣ លំដាប់នៃការកាត់បំណុល

ជាទូទៅ កូនបំណុលគ្មានការជ្រើសរើសទេក្នុងការកាត់បំណុលដោយខ្លួនឯងដោយគិតពីផលប្រយោជន៍របស់ម្ចាស់បំណុល និងប្រសិនបើការប្រាក់ចំពោះប្រាក់ដើម មិនទាន់បានសងប៉ុន្តែចំនួនប្រាក់ដើម បានថយចុះដោយសារការសង ម្ចាស់បំណុលនិងខូចប្រយោជន៍ ។ ប្រសិនបើកាតព្វកិច្ចមួយមានប្រាក់ដើម ការប្រាក់ និងសោហ៊ុយ កូនបំណុលមិនអាចជ្រើសរើសដោយការសងដោយសេរីបានទេ ហើយចំពោះការសងត្រូវធ្វើឡើងតាម

លំដាប់ **សោហ៊ុយ ការប្រាក់ និង ប្រាក់ដើម** ។ ដោយសារលំដាប់នេះ ត្រូវរៀបចំឡើងដោយគិតទៅលើផលប្រយោជន៍របស់ម្ចាស់បំណុល ប៉ុន្តែភាគីអាចប្តូរលំដាប់លំដោយបាន ប្រសិនបើមានការព្រមព្រៀង ។

ហើយម្យ៉ាងវិញទៀត ក្នុងករណីដែលអ្នកតំណាងរបស់ម្ចាស់បំណុលទាមទារអោយសង ជួនកាល អាចមានករណីដែលអ្នកតំណាងដែលតំណាងអោយម្ចាស់បំណុលច្រើន ទាមទារអោយសងចំពោះសិទ្ធលើបំណុលរបស់ម្ចាស់បំណុលទាំងអស់ ឬករណីដែលអ្នកតំណាងទាមទារអោយសងចំពោះសិទ្ធលើបំណុលខ្លួនឯង និងម្ចាស់សិទ្ធព្រមជាមួយគ្នា ។ និងបញ្ហាមួយដែលកើតឡើងបំពោះករណីដែលការសងចំពោះកាតព្វច្រើន ហើយម្ចាស់បំណុលខុសគ្នា និងមិនមានការកំណត់កាតព្វកិច្ចណាមួយឲ្យជាក់លាក់ ។

## កថាខណ្ឌទី ៣. សំណើរការផ្តល់ការសង និងការតម្កល់

### ៣.១. អត្ថន័យ និងអានុភាពជាមូលដ្ឋាននៃសំណើផ្តល់ការសង

#### ក. អត្ថន័យសំណើរផ្តល់នៃការសង

**សំណើរផ្តល់នៃការសង** មានន័យថា កូនបំណុលដែលបានរៀបចំសព្វគ្រប់នូវសកម្មភាពចាំបាច់នៃការសង និងរង់ចាំឲ្យម្ចាស់បំណុលធ្វើសកម្មភាពចាបាច់សម្រាប់ទូទូលនៃការសងនោះ ។ ហើយចំពោះសកម្មភាពនៃការធ្វើ សំណើរផ្តល់ការសង គឺមានការខុសប្លែកពីគ្នា ដោយផ្អែកលើខ្លឹមសារ និងប្រភេទនៃកាតព្វកិច្ច អត្ថិភាព និងនត្ថិភាពនៃការសន្យាពិសេសរវាងភាគី ជាដើម ។

**ឧទាហរណ៍៖** ការសងចំពោះកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគ ជាគោលការណ៍កូនបំណុលត្រូវយកប្រាក់ស្មើនិងចំនួនទឹកប្រាក់នៃកាតព្វកិច្ចទៅលំនៅឋានរបស់ម្ចាស់បំណុល ។ "សំណើរផ្តល់" កូនបំណុលត្រូវយកប្រាក់ទៅលំនៅឋានរបស់ម្ចាស់បំណុល ។ ម្យ៉ាងវិញទៀតចំពោះ ក្នុងករណីដែលអ្នកទិញ "ម្ចាស់បំណុល" ត្រូវមកលំនៅឋានរបស់អ្នកលក់ដើម្បីមកយកឡានតាមកិច្ចសន្យាទិញលក់ឡាន "សំណើរ" មានន័យថាកូនបំណុលរៀបចំឡានទៅឲ្យអ្នកទិញតាមថ្ងៃកំណត់ ។

ហើយម្យ៉ាងវិញទៀត ក្នុងករណីដែលកូនបំណុលធ្វើសំណើរផ្តល់ការសង តែម្ចាស់បំណុលមិនបានធ្វើនូវអំពើចាំបាច់ដើម្បីទទូលការសងទេ កូនបំណុលមិនទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនេះឡើយ ។ មានន័យថាបើអ្នកលក់មិនអាចប្រគល់ឡានដែលបានរៀបរាប់ខាងលើទៅអ្នកទិញតាមថ្ងៃកំណត់បាន ប្រសិនបើអ្នកទិញមិនមកតាមកាលបរិច្ឆេទកំណត់ក៏ដោយ ក៏អ្នកលក់មិនទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនេះឡើយ (ការយឺតយ៉ាវក្នុងការងនុវត្ត) ។

ចំពោះអានុភាពនៃសំណើរផ្តល់ការសង ក្នុងករណីកាតព្វកិច្ចដែលមានបំណងសងជាប្រាក់ ហើយបានផ្តល់ការសង តែម្ចាស់បំណុលមិនទទួលការសងនោះ ហើយបណ្តាលឲ្យមានការខូចខាតចំពោះការយឺតយ៉ាវក៏ដោយ

ក៏កូនបំណុលមិនចាំបាច់បង់ការប្រាក់តាមអត្រាការប្រាក់ **៦ ភាគរយ ក្នុងមួយឆ្នាំ** សម្រាប់ក្រោយពេលការយឺតយ៉ាវអំពីកាតព្វកិច្ចនៃការសងនោះទេ ។

## ខ. អានុភាពជាមូលដ្ឋាននៃសំណើផ្តល់ការសង

ចំពោះអានុភាពសំណើរផ្តល់ការសង ទោះបីជាគ្មានកំហុសរបស់ម្ចាស់បំណុលក្នុងការមិនទទួលការសងក៏ដោយ ទោះបីក្នុងកិច្ចសន្យាដែលម្ចាស់បំណុល ត្រូវមកលំនៅឋានរបស់កូនបំណុលដើម្បីមកយកវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យានេះ ហើយក្នុងករណីដែលម្ចាស់បំណុលមិនអាចមកលំនៅឋានរបស់កូនបំណុលតាមថ្ងៃកំណត់ក៏ដោយដោយមូលហេតុផ្សេងៗដែលកើតឡើង គឺមិនមែនជាការទទួលខុសត្រូវរបស់ម្ចាស់បំណុល ដោយគិតថាជាការសមរម្យ បន្ទុកដោយសារការបាត់បង់វត្ថុដែលជាកម្មវត្ថុជាដើម ត្រូវផ្ទេរទៅម្ចាស់បំណុល ។

**ឧទាហរណ៍៖** ក្នុងករណីដែលកូនបំណុលរក្សាទុកនូវវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ដោយសារម្ចាស់បំណុលមិនអាចមក លំនៅឋានរបស់ម្ចាស់បំណុលដោយសារការឈឺ ឬការឈប់ដំណើរការនៃប្រព័ន្ធធ្វើដំណើរក៏ដោយ ហើយវត្ថុនៃកិច្ចសន្យាត្រូវបាត់បងដោយសារភ្លើងឆេះដែលចាប់ផ្តើមពីផ្ទះដែលនៅជាប់នោះ ម្ចាស់បំណុលដែលមិនបានមកយកវត្ថុនោះតាមថ្ងៃកំណត់ គួរទទួលបន្ទុកហានិភ័យដោយសារការបាត់បង់នូវវត្ថុនោះ ។

ករណីម្យ៉ាងទៀត ទោះបីជាកូនបំណុលព្យាយាមអនុវត្តកាត្តព្វកិច្ចក៏ដោយ ប្រសិនបើកូនបំណុលមិនអាចអនុវត្តកាត្តកិច្ចបានដោយសារការពុំមានការសហការពីម្ចាស់បំណុល នោះកូនបំណុលអាចអះអាងនូវអានុភាពនៃ "សំណើរផ្តល់ការសង" បាន ។ ជាពិសេសកូនបំណុលអាចអះអាងថាការទទួលខុសត្រូវក្នុងការមិនអាចអនុវត្តកាត្តកិច្ចមិនត្រូវកើតឡើង ។ ប៉ុន្តែ មាករណីមួយចំនួនដែលអានុភាពការនៃសំណើរផ្តល់ការសងតែប៉ុណ្ណោះ មិនអាចការពារកូនបំណុលបានគ្រប់គ្រាន់បានទេ ។ កូនបំណុលអាចទាមទារឲ្យម្ចាស់បំណុលសងសំណងការខូចខាត ចំពោះសាហ៊ុយសម្រាប់ការរក្សាវត្ថុដែលជាកម្មវត្ថុ នៃការសងក្នុងឃ្លាំងដែលកូនបំណុលបានរក្សាទុកវត្ថុនោះក្នុងរយៈពេលវែង ដោយសារម្ចាស់បំណុលមិនទទួលការសងនោះ ឬចំពោះពន្ធលើអចលវត្ថុនៃការសងជាអាទិ៍ ។ ម្យ៉ាងវិញទៀតក្នុងករណីដែលម្ចាស់បំណុលមិនមកយកវត្ថុកូនបំណុលអាចពិចារណារំលាយកិច្ចសន្យាបាន ។ ហើយចំពោះការយឺតយ៉ាវក្នុងការទទួល ទទួលស្គាល់នូវការទទួលខុសត្រូវចំពោះសំណងនៃការខូចខាតរបស់ម្ចាស់បំណុល និងការរំលាយកិច្ចសន្យានៃកូនបំណុល គឺទាមទារឲ្យម្ចាស់បំណុលទទួលខុសត្រូវ ។ ប៉ុន្តែក្នុងករណីដែលអ្នកទិញបានបង់ថ្លៃរួចហើយ តែមិនមកទទួលយកនូវវត្ថុដែលជាកម្មវត្ថុនៃការសង អ្នកលក់មិនអាចទាមទារឲ្យអ្នកទិញទទួលខុសត្រូវចំពោះការមិនអនុវត្តកាត្តព្វកិច្ចឡើយ ។ គឺមានតែ

ក្នុងករណីដែលលើកឡើងអំពីការយឺតយ៉ាវទទួលក្នុងការទទួលការសងទេ ដែលអាចទាមទារឲ្យម្ចាស់បំណុលទទួលខុសត្រូវបាន ។

## ៣.២. ការតម្កល់ និងសិទ្ធលក់ដោយខ្លួនឯង

### ក. ការតម្កល់

ប្រព័ន្ធនៃការតម្កល់ដោយសារមានមូលហេតុផ្សេងៗដូចជា ករណីដែលកូនបំណុលមានបំណងការសង តែមិនអាចធ្វើបានដោយសារមូលហេតុខាងម្ចាស់បំណុល នោះកូនបំណុលអាចរួចផុតពីការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចដោយធ្វើសំណើរផ្តល់ការសង ហើយម្យ៉ាងវិញទៀតចំពោះការយឺតយ៉ាវក្នុងការទទួលរបស់ម្ចាស់បំណុលអាច អនុញ្ញាតឲ្យមានការការពាររបស់កូនបំណុល ។ ប៉ុន្តែប្រសិនបើកូនបំណុលគ្រាន់តែចង់ឲ្យកាតព្វកិច្ចរបស់ខ្លួនដោយការសង សំណើរផ្តល់ការសងតែមួយមិនគ្រប់គ្រាន់ទេ ។ ដូច្នេះចាំបាច់មានការតម្កល់ដើម្បីរំលត់កាតព្វកិច្ច ។

ចំពោះមូលហេតុនៃការតម្កល់ដែលមានចែងក្នុងមាត្រា ៤៥៧ នៅក្នុងក្រមរដ្ឋប្បវេណី កូនបំណុលអាចតម្កល់នូវកម្មវត្ថុនៃកាតព្វកិច្ចនៅកន្លែងតម្កល់ដើម្បីឲ្យរួចផុតពីកាតព្វកិច្ចបាន ។

ចំពោះមូលហេតុដែលមានចែងក្នុងមាត្រា ៤៥៧ ការតម្កល់មានដូចខាងក្រោមៈ

១. អ្នកស្នើបានស្នើផ្តល់នៃការសង តែម្ចាស់បំណុលបដិសេធមិនទទួល ឬមិនអាចទទួលការសងនោះបាន ។

២. កូនបំណុលមិនអាចដឹងថា អ្នកណាជាម្ចាស់បំណុល ដោយមិនមែនជាកំហុសរបស់ខ្លួន ។

៣. នៅក្នុងអំឡុងពេលដែលម្ចាស់បំណុលមិនព្រមចំពោះការតម្កល់ ឬក្នុងអំឡុងពេលដែលសាលក្រម ឬសាលដីកាដែលប្រកាសថាតម្កល់នោះមានសុពលភាពមិនទាន់ចូលជាស្ថាពរ អ្នកសងអាចយកវត្ថុតម្កល់មកវិញបាន ។ ក្នុងករណីត្រូវបានចាត់ទុកថា អ្នកសងមិនបានធ្វើការតម្កល់ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវបានអនុវត្តចំពោះករណីដែលសិទ្ធលើការបញ្ចាំ ឬសិទ្ធលើហ៊ីប៉ូតែត ត្រូវបានរំលត់ដោយការតម្កល់នោះ ។

៤. សេចក្តីលម្អិតស្តីពីការតម្កល់ ត្រូវកំណត់ក្នុងច្បាប់ស្តីពីការតម្កល់ ។

### ខ. សិទ្ធលក់ដោយខ្លួនឯង

ក្នុងប្រព័ន្ធមួយផ្សេងទៀត ប្រសិនបើវត្ថុជាកម្មវត្ថុនៃការសង គឺជាប្រាក់ ឬឧបរណ៍ដែលអាចជួញដូរបាន និងមានការងាយស្រួលក្នុងការតម្កល់វត្ថុនោះ ។ ប៉ុន្តែប្រសិនបើវត្ថុជាកម្មវត្ថុនៃការសងជាសត្វ ឬរុក្ខជាតិ ឬវត្ថុមានទំហំធំមហិមា ជាអាទិ៍និងមានផលពិបាកក្នុងការតម្កល់នៅការិយាល័យតម្កល់ ។ តែប្រសិនបើកូនបំណុល

មានបំណងអាចលក់វត្ថុនោះប្តូរជាប្រាក់ ការតម្កល់អាចធ្វើបាន គឺអនុញ្ញាតឲ្យកូនបំណុលមានសិទ្ធដាក់ពាក្យសុំឲ្យលក់ដេញថ្លៃនូវវត្ថុដែលជាកម្មវត្ថុនៃការសង ។

ជាទូទៅ ប្រសិនបើលក់វត្ថុណាមួយដោយដេញថ្លៃ វត្ថុនោះត្រូវបានលក់ថោកជាងតម្លៃក្នុងទីផ្សារច្រើន ហើយម្ចាស់បំណុលអាចបាត់បង់ផលប្រយោជន៍ ដោយសារតែខ្លួនមិនអាចទទួលតាវលិកដែលបានព្រមព្រៀងគ្នាដាក់ដេញថ្លៃ ។

## ផ្នែកទី ២. ការទូទាត់

### កថាខណ្ឌទី ១. ការទូទាត់

ការទូទាត់គឺជាការផាត់ទាត់កាត់កងឲ្យរួចលែងទាក់ទិនគ្នាទៅវិញទៅមក។

### ១.១. ល័ក្ខខ័ណ្ឌនៃការទូទាត់ដែលច្បាប់បានកំណត់ និងកិច្ចសន្យាទូទាត់

#### ក. ល័ក្ខខ័ណ្ឌនៃការទូទាត់ដែលច្បាប់បានកំណត់

ការទូទាត់ដែលច្បាប់បានកំណត់ គឺជាការទូទាត់ទូទាត់ដែលត្រូវធ្វើឡើងដោយកំណត់យោងតាមកថាខណ្ឌទី១ នៃមាត្រា ៤៦៤ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដោយក្នុងករណីដែលបុគ្គលពីរនាក់ទទួលបន្ទុកនៃកាតព្វកិច្ចដែលមានគោលបំណងប្រភេទដូចគ្នាទៅវិញទៅមកទោះបីជាគ្មានការព្រមព្រៀងគ្នាអំពីការទូទាត់ក៏ដោយអំពីការទូទាត់រវាងភាគីទាំងពីរក៏ដោយ។ ការទូទាត់អាចធ្វើបាន ដោយការបង្ហាញឆន្ទៈឯកតោភាគីអំពីការទូទាត់ របស់ភាគីម្ខាង។ ការទូទាត់អាចធ្វើបាន ក្នុងករណីដែលកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក គឺជាកាតព្វកិច្ចជាប្រាក់ ឬកាតព្វកិច្ចដែលមានកម្មវត្ថុជាវត្ថុជំនួសប្រភេទដូចគ្នា។ ក្នុងករណីដែល កាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក គឺជាកាតព្វកិច្ចជាប្រាក់ ប្រសិនបើកាតព្វកិច្ចមួយមានចំនួនទឹកប្រាក់ជារូបិយប័ណ្ណជាតិ (រូបិយប័ណ្ណប្រទេសកម្ពុជា) ហើយកាតព្វកិច្ចមួយទៀតមានចំនួនទឹកប្រាក់ជារូបិយប័ណ្ណបរទេស ប្រសិនបើគ្មានការព្រមព្រៀងគ្នាទេចំពោះរូបិយវត្ថុបរទេស កូនបំណុលអាចសងជារូបិយប័ណ្ណកម្ពុជាបាន ដោយផ្អែកលើ (មាត្រា ៣១៧) នៃក្រមនេះ មានន័យថាកូនបំណុលដែលមានកាតព្វកិច្ចជារូបិយវត្ថុបរទេសអាចធ្វើការទូទាត់ ដោយជ្រើសយករូបិយវត្ថុកម្ពុជាបាន។

#### ខ.កិច្ចសន្យាទូទាត់

កិច្ចសន្យាទូទាត់ គឺជាកិច្ចសន្យាដែលរលត់កាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក តាមការព្រមព្រៀងរវាងគូភាគី។ គូភាគីនៃកាតព្វកិច្ចអាចធ្វើកិច្ចសន្យាទូទាត់ដែលរំលត់កាតព្វកិច្ចទៅវិញទៅមកបាន ទោះបីជាកាតព្វកិច្ចទាំងពីរនោះគ្មានគោលបំណងប្រភេទដូចគ្នាទៅវិញទៅមកក៏ដោយ ប៉ុន្តែគូភាគីមិនអាចធ្វើឲ្យខូចផលប្រយោជន៍របស់តតិយជនបានឡើយ។ តាមកិច្ចសន្យាទូទាត់ ការទូទាត់អាចធ្វើបាន ទោះបីជាល័ក្ខខ័ណ្ឌតម្រូវនៃការទូទាត់ដែល

ច្បាប់បានកំណត់ មិនត្រូវបានបំពេញក៏ដោយ។ ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃកាតព្វកិច្ចខុសគ្នា ដូចជាសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ និង សិទ្ធិលើបំណុលដែលទាមទារឲ្យកាតប្រគល់វត្ថុអ្វីមួយជាអាទិ៍ក៏ដោយ ក៏ការទូទាត់អាចធ្វើបាន តាមកិច្ចសន្យាទូទាត់បានដែរ។

### ២.២. វិធីទូទាត់

ការទូទាត់ត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈទូទាត់ ពីភាគីម្ខាងទៅភាគីម្ខាងទៀត។ ការទូទាត់មិនមានអនុភាពទេ ប្រសិនបើគ្មានការបង្ហាញឆន្ទៈដោយភាគី ការបង្ហាញឆន្ទៈអំពីការទូទាត់ដោយភាគី មានភាពចាំបាច់ត្រូវដល់ភាគីម្ខាងទៀត។ ការបង្ហាញឆន្ទៈទូទាត់ មិនអាចធ្វើការដាក់ល័ក្ខខ័ណ្ឌរំលាយបានទេ ប្រសិនបើការអនុញ្ញាតឲ្យមានល័ក្ខខ័ណ្ឌរំលាយ មិនមានភាពសមរម្យ។ ចំណែកឯការបង្ហាញ ឆន្ទៈនៃការទូទាត់ អាចភ្ជាប់ដាក់ល័ក្ខខ័ណ្ឌបង្អង់បាន ប៉ុន្តែ ប្រសិនបើខ្លឹមសារនៃល័ក្ខខណ្ឌបង្អង់មិនច្បាស់លាស់ វាធ្វើឲ្យភាគីម្ខាងទៀតស្ថិតក្នុងស្ថានភាពមិនស្ថិតស្ថេរដោយភាពមិនត្រឹមត្រូវ ការបង្ហញ ឆន្ទៈបែបនេះគួរត្រូវបានចាត់ទុកជាមោឃៈ ដោយសារវាផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ។ ក៏ប៉ុន្តែការបង្ហាញឆន្ទៈមិនអាចដាក់ល័ក្ខខណ្ឌរំលាយបានទេ តែប្រសិនបើអនុញ្ញាតឲ្យមានល័ក្ខខណ្ឌ គឺមិនមានភាពសម្យម្យទេ ។

**ឧទាហរណ៍៖** សិទ្ធលើបំណុលចំពោះគ្នាទៅវិញទៅមករវាង □ និង □ ស្ថិតនៅក្នុងស្ថានភាពសមរម្យនិងការទូទាត់ ។ ប៉ុន្តែ តាមការពិត □ ចង់ធ្វើអនុប្បទាននូវសិទ្ធលើបំណុល □ ទៅតតិយជន □ ហើយមិនចង់ទូទាត់សិទ្ធលើបំណុលជាមួយ □ បើអាចសងកាតព្វកិច្ចចំពោះ □ បាន ។ ក្នុងករណីនេះ ប្រសិនបើ □ ដែលទទួលការទាមទារឲ្យសងចំពោះសិទ្ធលើបំណុលតបដោយ □ បាននិយាយថា “ ខ្ញុំនឹងធ្វើការទូទាត់សិទ្ធលើបំណុលនោះជាមួយនឹងសិទ្ធលើបំណុលនោះជាមួយសិទ្ធលើបំណុលដែលខ្ញុំមានចំពោះ □ ។ ប៉ុន្តែប្រសិនបើខ្ញុំបានខ្ចីលុយពី □ ក្នុងរយះពេលមួយខែ ខ្ញុំនិងធ្វើការទូទាត់ទេ ។ ក្នុងចំណុចនេះជាការបង្ហាញឆន្ទៈដោយមានការដាក់លក្ខខ័ណ្ឌរំលាយ ។ ចំពោះលក្ខខ័ណ្ឌបែបនេះត្រូវបដិសេធនីវការទូទាត់ដែលបង្កើតអានុភាពម្តងរួចហើយ មិនគួរអនុញ្ញាតដោយសារការដាក់ល័ក្ខខ័ណ្ឌនឹងធ្វើអោយភាគីម្ខាងទៀតស្ថិតនៅក្នុងស្ថានភាពមិនស្ថិតស្ថេរ ។ ហើយមូលហេតុដែល ការកំណត់ពេល មិនងាចអនុញ្ញាតបាន គឺដោយសារទោះបីមានការកំណត់ពេលក៏ដោយ ក៏ការទូទាត់មានអានុភាពប្រតិសកម្ម តាំងពីពេលដែលកាតព្វកិច្ចទាំងពីរមានភាពសមរម្យនៃការទូទាត់ ។

ការបង្ហញឆន្ទៈដោយមាន ល័ក្ខខ័ណ្ឌបង្អង់ និង ការសន្យាជាមុននៃការទូទាត់ គឺមានលក្ខណៈស្រដៀងគ្នា ។ ការសន្យាជាមុននៃការទូទាត់ មានន័យថាការសន្យាជាមុននៃការទូទាត់នាពេលអនាគត តាមកាតព្វកិច្ចតាមការព្រមព្រៀងរវាងភាគីទាំងពីរអំពីលក្ខខ័ណ្ឌនៃការទូទាត់ ហើយអាចចាត់ទុកបានមានសុពលភាព ដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងពីរ ។

**ឧទាហរណ៍៖** វិធីមួយសម្រាប់ការប្រមូលបំណុលមុនពេលដែលស្ថានភាពហិរញ្ញវត្ថុនៃភាគីម្ខាងទៀតកាន់តែមានស្ថានភាពកាន់តែធ្លាក់ដុនដាប មានដូចជាកិច្ចព្រមព្រៀងរវាងភាគីទាំងពីរដែលមានខ្លឹមសារថា ការទូទាត់និងមានអានុភាពនៅពេលដែល ភាគីម្ខាងទៀតដែលមានស្ថានភាពហិរញ្ញវត្ថុកាន់តែធ្លាក់ដុនដាប បានកើនឡើង ។ ចំណែកឯការបង្ហាញឆន្ទៈដែលមានល័ក្ខខ័ណ្ឌបង្អង់ អាចធ្វើបានដោយមិនមានការព្រមព្រៀងពីភាគីម្ខាងទៀតក៏បាន ។ ប៉ុន្តែមានតួនាទីដូចគ្នា និងការសន្យាជាមុននៃការទូទាត់ជាមុន ។

ប្រសិនបើនៅពេលដែលឆន្ទៈទូទាត់ត្រូវបានបង្ហាញ និង ល័ក្ខខ័ណ្ឌនៃការទូទាត់ត្រូវបានបំពេញ ការទូទាត់នោះនិងមានអានុភាព ហើយសិទ្ធលើគ្នាទាំងវិញទៅមកត្រូវរលត់ ត្រឹមកម្រិតដែលមានតម្លៃស្មើគ្នា ហើយការរលត់សិទ្ធលើបំណុលនោះត្រូវមានអានុភាពប្រតិសកម្មតាំងពី ពេលដែលសីទ្ធលើបំណុលនោះសមស្រមនិងការទូទាត់ ។

### ក. ការកម្រិតចំពោះការទូទាត់

ក្នុងករណីដែលលក្ខខណ្ឌនៃការព្វកិច្ចណាមួយ ឬទាំងពីរ មិនអនុញ្ញាតឲ្យធ្វើការទូតាត់ទេ គូភាគីមិនអាចធ្វើការទូទាត់ទេ ។ ហើយម្យ៉ាងទៀតក្នុងករណីដែលភាគីទាំងសងខាងធ្វើការសន្យាពិសេសមិនធ្វើការទូទាត់ កូនបំណុលនៃមួយៗមិនអាចទូទាត់បានទេ ។ ប៉ុន្តែការសន្យាពិសេសមិនធ្វើការទូទាត់នេះ មិនអាចអះអាងដោយតតិយជនសុចរិតបានទេ (៤៦៧) ។ ចំពោះការបែបនេះមិនសមស្របឲ្យធ្វើការទូទាត់ ដោយសារសិទ្ធលើបំណុលណាមួយ ឬ ទាំងពីរក្នុងចំណោមសិទ្ធលើបំណុលចំពោះគ្នាទៅវិញទៅមក គឺជាសិទ្ធលើបំណុលពសេសដែលចាំបាច់ឲ្យភាគីទាំងពីរត្រូវទទួលការបង់ប្រាក់ ។

**ឧទាហរណ៍៖** សិទ្ធលើបំណុលចំពោះប្រាក់ឈ្នួលជាអាទិ៍ គឺជាសិទ្ធលើបំណុលដែលកម្មករនិយោជិតត្រូវការសម្រាប់ជីវភាពរស់នៅ ហើយនិយោជកត្រូវបង់ប្រាក់ឈ្នួលទៅកម្មករនិយោជិត ។ តែបើនិយោជកមានសិទ្ធលើបំណុលចំពោះកម្ចីដល់កម្មករនិយោជិត មិនត្រឹមត្រូវចំពោះសិទ្ធលើបំណុលចំពោះប្រាក់ឈ្នួលទេ ដោតអនុញ្ញាតឲ្យកម្មករនិយោជិតធ្វើការទូទាត់បាន ។

### ខ. ការទូទាត់ជាមួយនឹងសិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀតដែលកើតឡើងដោយអំពើអនីត្យានុកូល

ក្នុងករណីដែលកូនបំណុលទទួលកាតព្វកិច្ចដែលកើតឡើងដោយអំពើអនីត្យានុកូលចំពោះភាគីម្ខាងទៀត កូនបំណុលនោះមិនអាចអះអាងនូវការរលត់កាតព្វកិច្ចនេះដោយការទូទាត់បានទេ(៤៦៩) ។

**ឧទាហរណ៍៖** ក្នុងករណីដែល សុខ មានសិទ្ធលើបំណុលចំពោះប្រាក់កម្ចី សៅ ជំពាក់ ហើយ សៅមានសិទ្ធលើបំណុលចំពោះសំណងការខូចខាតដែលកើតឡើងដោយអំពើអនីត្យានុកូលរបស់ សុខ នោះ សុខ មិនអាច

អះអាងការរលត់កាតព្វកិច្ចចំពោះសំណងការខូចខាតដែលកើតឡើងដោយអំពើអនីត្យានុកូលនោះ តាមការអះអាងអំពីការទូទាត់បានឡើង ។

ចំពោះមូលហេតុដែកមិនអណុញ្ញាតឲ្យធ្វើការទូទាត់បែបនេះ ក៏ព្រោះ ៖

- ប្រសិនបើអនុញ្ញាតឲ្យមានការទូទាត់ប្រភេទនេះ អាចនឹងមានការប្រថុយប្រថានថា សុខ ដែលមានសិទ្ធលើបំណុលចំពោះប្រាក់កម្ចី សៅ ដែលជំពាក់ អាចព្យាយាមប្រមូលកាតព្វកិចដោយកំលោលដែលអាចចាត់ទុកថាជាអំពើអនីត្យានុកូល ដោយគិតថាអាទូទាត់ពេលក្រោយបាន ។ និងដើម្បីទប់ស្កាត់កុំឲ្យាមានការប្រព្រឹត្តអំពើអនីត្យានិកូល ។
- ជនរងគ្រោះដោយអំពើអនីត្យានុកូល (សៅ) ចាំបាច់ត្រូវមានការបង់ជាក់ស្តែងនីវប្រាក់សំណងការខូចខាត ដើម្បីយកទៅធ្វើជាថ្លៃព្យាបាល ជាអាទិ៍ ហេតុដូច្នេះមិនមាមភាពត្រឹមត្រូវទេចំពោះ ការរលត់សិទ្ធលើបំណុលរបស់ សៅ ចំពោះសំណងការខូចខាត ដោយសារការទូទាត់ពី សុខ ។

## កថាខណ្ឌទី២. ការលើកលែង

ការលើកលែងកាតព្វកិច្ចត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈឯកតោភាគីរបស់ម្ចាស់បំណុល ក្នុងការលើកលែងកាតព្វកិច្ចចំពោះកូនបំណុល ហើយកាតព្វកិច្ចនោះត្រូវរលត់។ ការលើកលែងកាតព្វកិច្ចអាចបង្កើតបានកិច្ចសន្យាលើកលែង ដើម្បីឲ្យកូនបំណុលរួចពីកាតព្វកិច្ចតាមកិច្ចសន្យាព្រមព្រៀងរវាងគូភាគីនៃកិច្ចសន្យា។ កិច្ចសន្យាលើកលែង ក៏ជាកិច្ចសន្យាដែរ ការលុបចោលកិច្ចសន្យាអាចធ្វើទៅបាន ដូចកិច្ចសន្យាទូទៅដទៃទៀតដែរ ប្រសិនបើភាគីណាមួយនៃកិច្ចសន្យាមានវិការៈក្នុងការបច្ចាញឆន្ទៈ។

### ២.១. ការលើកលែងតែមួយផ្នែក

ម្ចាស់បំណុលអាចលើកលែងកាតព្វកិច្ចចំពោះកូនបំណុល តែមួយផ្នែកបានដោយមានការកំណត់នៅក្នុងកិច្ចសន្យាលើកលែង។

### ២.២. ករណីដែលកម្រិតការលើកលែង

ក្នុងករណីដែលសិទ្ធិលើបំណុលដែលម្ចាស់បំណុលមានបំណងចង់ធ្វើការ លើកលែងត្រូវបានរឹបអូស ការលើកលែងរបស់ម្ចាស់បំណុលមិនអាចធ្វើបានទេ ដោយសារម្ចាសបំណុលមិនអាចអនុវត្តសិទ្ធិលើបំណុលបានទេ។ ក្រៅពិនេះ ម្ចាស់បំណុលមិនអាចលើកលែងឲ្យកូនបំណុលរួចផុតពីកាតព្វកិច្ចដែលជាកម្មវត្ថុនៃសិទ្ធិបញ្ចាំ ឬកម្មវត្ថុនៃអនុប្បទានសិទ្ធិលើបំណុលដែលមានគោលបំណងជាប្រាតិភោគបានទេ។

ក្នុងករណីដែលគ្មានការកម្រិតលើការចាត់ចែងប៉ុន្តែ ការរំលត់សិទ្ធិលើបំណុលដោយការលើកលែង អាចប៉ះពាល់ផលប្រយោជន៍ដល់ផលប្រយោជន៍របស់តតិយជន ។ ឧទាហរណ៍ដូចជាករណីដែលម្ចាស់បំណុលលើក

លែងសិទ្ធិលើបំណុល នៅពេលដែលមានការសន្យាជាមុននូវអនុប្បទានសិទ្ធិលើបំណុលនោះ ដែលក្នុងករណីនេះ ម្ចាស់បំណុលអាចលើកលែងបាន ប៉ុន្តែប្រសិនបើលើកលែងនោះបានធ្វើឲ្យខូចខាតប្រយោជន៍របស់បុគ្គល ដែលមានសិទ្ធិតាមការសន្យាជាមុនអនុប្បទាននូវសិទ្ធិលើបំណុល ម្ចាស់បំណុលដែលលើកលែងសិទ្ធិលើបំណុលនោះ នឹងត្រូវទទួលខុសត្រូវចំពោះសំណងការ ខូចខាត ដោយការបំពានកិច្ចសន្យា ឬ អំពើអនីត្យានុកូល។

## កថាខណ្ឌទី៣. នវកម្ម និងព្យាកុលភាព

### ៣.១. នវកម្ម

នវកម្ម គឺសម្តៅទៅលើកិច្ចសន្យារវាងម្ចាស់បំណុល និង កូនបំណុលដែលរំលត់ កាតព្វកិច្ចដើមហើយ បង្កើតកាតព្វកិច្ចថ្មី ជំនួសកាតព្វកិច្ចដើមនោះ។ ដែលមានន័យថាការប្តូរគោលបំណងនៃកាតព្វកិច្ច ហើយមិនកំណត់អំពីនវកម្មដែលប្តូរម្ចាស់បំណុល ឬ នវកម្មដែលប្តូរម្ចាស់បំណុលទេ។

នវកម្មចែកចេញជា ៣ប្រភេទ គឺ៖

១. នវកម្មប្រភេទទី១ គឺសម្តៅលើករណីផ្លាស់ប្តូរគោលបំណងនៃកាតព្វកិច្ច។

២. នវកម្មប្រភេទទី២ គឺជានវកម្មដែលប្តូរម្ចាស់បំណុលដែលជាភាគីមួយក្នុងចំណោមភាគីកិច្ចសន្យា។

៣. នវកម្មប្រភេទទី៣ គឺជានវកម្មដែលប្តូរកូនបំណុល។

ដែលមានន័យដូចខាងក្រោម៖

**១. នវកម្មប្រភេទទី១** គឺសម្តៅលើករណីផ្លាស់ប្តូរគោលបំណងនៃកាតព្វកិច្ច គឺសំដៅលើករណីនៃការផ្លាស់ប្តូរគោលបំណងនៃកាតព្វកិច្ច ។

**ឧទាហរណ៍៖** កាតព្វកិច្ចដែលមាន គោលបំណងផ្តល់តាវកាលិកជាវត្ថុ ប្តូរទៅជាកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ឬកាតព្វកិច្ចចំពោះថ្លៃលក់ ប្តូរទៅជាកាតព្វកិច្ចជាការខ្ចីបរិភោគ ។ ជាពិសេស ក្នុងឧទាហរណ៍ទីពីរនេះ ត្រូវហៅថា ឧបសន្យានៃការខ្ចីបរិភោគ ។ តាមកិច្ចការជាក់ស្តែង នូវកម្មដែលប្តូរគោលបំណងនៃកាតព្វកិច្ចដូច្នេះត្រូវបានប្រើប្រាស់ក្នុងសកម្មភាពសេដ្ឋកិច្ច ហើយជា ប្រព័ន្ធដ៏មានប្រយោជន៍ ។

**២. នវកម្មប្រភេទទី២** គឺជានវកម្មដែលប្តូរម្ចាស់បំណុលដែលជាភាគីមួយក្នុងចំណោមភាគីកិច្ចសន្យា គឺជានវកម្មដែលប្តូរម្ចាស់បំណុលដែលជាភាគីមួយក្នុងចំណោមភាគីនៃកិច្ចសន្យា ។ នវកម្មដែល ប្តូរម្ចាស់បំណុល គឺស្រដៀងនឹងអនុប្បទានសិទ្ធិលើបំណុល ត្រង់ចំណុចថា ម្ចាស់បំណុលត្រូវបានប្តូរ ប៉ុន្តែ នវកម្មនេះខុសពី អនុប្បទានសិទ្ធិលើបំណុល ដោយសារកាតព្វកិច្ចដើមត្រូវរលត់ ហើយកាតព្វកិច្ចថ្មីកើតឡើង ។ ហេតុដូច្នេះ តាមកិច្ចសន្យា នវកម្មដែលប្តូរម្ចាស់បំណុល ជាគោលការណ៍ប្រាតិភោគដែលធានាកាតព្វកិច្ចដើមត្រូវរលត់ ហើយការតវ៉ាដែលកូន បំណុលធ្លាប់មានចំពោះម្ចាស់បំណុលដើម ក៏មិនអាចយកមកអះអាងតតាំងនឹងម្ចាស់បំណុលថ្មីបានដែរ ។ ដូចដែលបានរៀបរាប់ខាងលើ នវកម្មដែលប្តូរម្ចាស់បំណុល ពុំ

មានខ្លឹមសារសមហេតុផលនោះទេ ហើយប្រសិនបើមានប្រព័ន្ធនៃអនុប្បទាន សិទ្ធិបំណុល ប្រព័ន្ធនេះគួរត្រូវយកមកប្រើប្រាស់ ។

**៣. នវកម្មប្រភេទទី៣** គឺជានវកម្មដែលប្តូរកូនបំណុល គឺជានវកម្មដែលប្តូរកូនបំណុល ។

**ឧទាហរណ៍៖** ម្ចាស់បំណុល **ក** និង កូនបំណុល **ខ** រំលត់កាតព្វកិច្ចរវាង **ក** និង **ខ** ហើយបង្កើតកាតព្វកិច្ចថ្មីដែលកូនបំណុល **គ** ទទួលខុសត្រូវជំនួសវិញ ។ ក្នុងករណីនេះត្រូវចាំបាច់ត្រូវមានការយល់ព្រមពី **គ** ដើម្បីឱ្យនវកម្មនេះមានអានុភាព ។ នវកម្មនេះមានអានុភាពស្មើរតែដូចគ្នានឹងការទទួលកាតព្វកិច្ចដែលឱ្យកូនបំណុលរួចផុតពី ការទទួលខុសត្រូវ ហេតុដូច្នេះខ្លឹមសារនៃនវកម្មនេះមិនមែនមិនសមហេតុផលដូចខ្លឹមសារនៃនវកម្មដែលប្តូរម្ចាស់បំណុលទេ ប៉ុន្តែ អាចត្រូវបានលៃលកដោះស្រាយបាន តាមរយៈប្រព័ន្ធនៃការទទួលកាតព្វកិច្ច ។ ដូច្នេះមាត្រានេះមិនកំណត់ អំពីនវកម្មដែលប្តូរកូនបំណុលទេ ។

## ៣.២. ការមិនរលត់កាតព្វកិច្ចដើម ការផ្ទេរប្រាតិភោគ

### ក. ការមិនរលត់កាតព្វកិច្ចដើម

ប្រសិនបើកាតព្វកិច្ចថ្មីដែលត្រូវបានបង្កើតឡើងដោយនវកម្ម (កិច្ចសន្យារវាងម្ចាស់បំណុល និង កូនបំណុលដែលរំលត់ កាតព្វកិច្ចដើមហើយបង្កើតកាតព្វកិច្ចថ្មី ជំនួសកាតព្វកិច្ចដើម) មិនបានបង្កើត អានុភាពដោយសារមូលហេតុដែលកូនបំណុលនៃកាតព្វកិច្ចចាស់មិនអាចព្យាករបាន ឬ ប្រសិនបើកាតព្វកិច្ចថ្មីនោះជាអលទ្ធភាពក្នុងការអនុវត្តតាំងពីដើមនោះកាតព្វកិច្ចមិនត្រូវរលត់ឡើយ។

នវកម្មរំលត់កាតព្វកិច្ចដើម ហើយបង្កើតកាតព្វកិច្ចថ្មីជំនួសកាតព្វកិច្ចដើមនោះវិញ ដូច្នេះ ប្រសិនបើកាតព្វកិច្ចថ្មីមិនបានបង្កើតអានុភាព ដោយសារមូលហេតុណាមួយ គោលបំណងនៃនវកម្មមិនត្រូវរលត់ដែរ។ ករណីដែលនាំឲ្យមិនរលត់កាតព្វកិច្ចដើម៖

**<u>ករណីទី១</u>**. ដែលកាតព្វកិច្ចថ្មីមិនបានបង្កើតអនុភាព ដោយសារមូលហេតុមិនស្របច្បាប់ កាតព្វកិច្ចដើមមិនត្រូវរលត់ឡើយ។ មូលហេតុមិនច្បាប់ដែលលើកមកនេះ មិនត្រឹមតែភាពផ្ទុយនឹងបញ្ញត្តិនៃច្បាប់ប៉ុណ្ណោះទេ រួមមានករណីដែលកាតព្វកិច្ចមិនបានបង្កើតអនុភាពដោយសារការផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អផងដែរ។

**<u>ករណីទី២</u>**. ករណីដែលកាតព្វកិច្ចថ្មីមិនបានបង្កើតអានុភាព ដោយសារមូលហេតុដែលភាគីពាក់ព័ន្ធមិនអាចព្យាករបានក៏កាតព្វកិច្ចដើមមិនត្រូវរលត់ទេ។ ការអលទ្ធភាពតាំងពីដំបូង មិនធ្វើឲ្យកិច្ចសន្យាមោឃៈដោយស្វ័យប្រវត្តិទេ(មាត្រា ៣៥៥) តែក្នុងករណី ប្រសិនបើម្ចាស់បំណុល និងកូនបំណុលមានការភ័ន្តច្រឡំ កិច្ចសន្យានវកម្ម (កិច្ចសន្យារវាងម្ចាស់បំណុល និង កូនបំណុលដែលរំលត់ កាតព្វកិច្ចដើមហើយបង្កើតកាតព្វកិច្ចថ្មី ជំនួសកាតព្វកិច្ចដើម) អាចត្រូវបានលុបចោលបាន ហេតុដូច្នេះក្នុងករណីនេះ កាតព្វកិច្ចដើមមិនត្រូវរលត់ឡើយ។

### ខ. ការផ្ទេរប្រាតិភោគ

ប្រាតិភោគគឺជា

- ការធានាដល់ម្ចាស់បំណុលក្នុងការប្រមូលឥណទេយ្យរបស់ខ្លួនមកវិញ។
- មធ្យោបាយមួយដើម្បីធានាការសងកាតព្វកិច្ច។

ប្រាតិភោគដែលមានដូចជា សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែត ឬប្រាតិភោគផ្សេងទៀតដែលបានបង្កើតឡើងដើម្បីធានាកាតព្វកិច្ចដើម អាចផ្ទេរដើម្បីធានាកាតព្វកិច្ចថ្មី ក្នុងទំហំនៃកាតព្វកិច្ចដើម ដោយការព្រមព្រៀងគ្នារបស់គូភាគីនៃកិច្ចសន្យានវកម្មបាន។ ប៉ុន្តែ ប្រាតិភោគដែលត្រូវបានដាក់ដោយ តតិយជន មិនត្រូវផ្ទេរឡើយ លើកលែងតែមានការព្រមព្រៀងពីតតិយជននោះ។ ដែលមានន័យថា ប្រាតិភោគមិនត្រូវបន្តដើម្បីធានាកាតព្វកិច្ចដើមដោយស្វ័យប្រវត្តិឡើយ ដោយសារកាតព្វកិច្ចដើមត្រូវរលត់ដោយនវកម្ម ជាគោលការណ៍ ប្រាតិភោគដើម្បីធានាកាតព្វកិច្ចដើមនោះក៏ត្រូវរលត់ដូចគ្នាផងដែរ។ តែប្រសិនបើមានការព្រមព្រៀងរបស់ភាគីនៃកិច្ចសន្យានវកម្ម ប្រាតិភោគអាចបន្តជាប្រាតិភោគចំពោះកាតព្វកិច្ចថ្មីនេះបាន។

ក្នុងករណីដែលប្រាតិភោគត្រូវបានដាក់ដោយតតិយជន ឬ ករណីដែលតតិយជនជាអ្នកធានា វាជារឿងដែលមិនត្រឹមត្រូវទេ ក្នុងការផ្ទេរប្រាតិភោគ ឬការធានានោះទៅកាតព្វកិច្ចថ្មី ដោយការព្រមព្រៀងគ្នារបស់ម្ចាស់បំណុល និងកូនបំណុលតែប៉ុណ្ណោះ ដូច្នេះ ចាំបាច់ត្រូវមានការយល់ព្រមពីតតិយជននោះ។

ក្នុងឧបសន្យាខ្ចីបរិភោគវត្ថុ ត្រូវសន្មតថា មានការព្រមព្រៀងដែលបានកំណត់នៅចំណុច (ប្រាតិភោគដែលមានដូចជា សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែត ឬប្រាតិភោគផ្សេងទៀតដែលបានបង្កើតឡើងដើម្បីធានាកាតព្វកិច្ចដើម អាចផ្ទេរដើម្បីធានាកាតព្វកិច្ចថ្មី ក្នុងទំហំនៃកាតព្វកិច្ចដើម ដោយការព្រមព្រៀងគ្នារបស់គូភាគីនៃកិច្ចសន្យានវកម្មបាន)។ ដែល ឧបសន្យានៃការខ្ចីបរិភោគ គឺធ្វើឲ្យកាតព្វកិច្ចចំពោះថ្លៃ ជាអាទិ៍ ទៅជាកាតព្វកិច្ចតាមការខ្ចីប្រាតិភោគ។ ដែលមានន័យថា ក្នុងករណីនេះមានការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល លើការផ្ទេរប្រាតិភោគ ។ ដែលត្រូវបានបែងចែកដោយសារកាតព្វកិច្ចដើម និងកាតព្វកិច្ចថ្មី សុទ្ធតែជាកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ហើយវាជារឿងសមហេតុផល ក្នុងការផ្ទេរប្រាតិភោគទៅកតព្វកិច្ចថ្មី ប៉ុន្តែ ចំពោះប្រាតិភោគដែលដាក់ដោយតតិយជន ចាំបាច់ត្រូវមានការយល់ព្រមរបស់អ្នកដាក់ប្រាតិភោគ។

## កថាខណ្ឌទី៤. ព្យាកុលភាព

ព្យាកុលភាពគឺជាមូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងៗដែលនាំឲ្យកាតព្វកិច្ចរលត់។

ក្នុងករណីដែលម្ចាស់បំណុល និងកូនបំណុលជាបុគ្គលតែម្នាក់ គ្មានន័យអ្វីក្នុងការអនុញ្ញាតឲ្យសិទ្ធិលើបំណុល ឬ កាតព្វកិច្ចរបស់បុគ្គលតែម្នាក់ បន្តឲ្យមានអត្ថិភាពឡើយ ដូច្នេះវារឿងដ៏សមហេតុផលក្នុងការពិចារណាថាកាតព្វកិច្ចត្រូវរលត់ ដូចទៅក្នុងករណីដែលកាតព្វកិច្ចត្រូវបានសងដូច្នេះដែរ។ នេះគឺជាហេតុផលសមរម្យដែលយកព្យាកុលភាពធ្វើជាមូលហេតុនៃការរលត់កាតព្វកិច្ច។

ប៉ុន្តែក្នុងករណីដែលកាតព្វកិច្ចដែលត្រូវរលត់ដោយព្យាកុលភាព ជាកម្មវត្ថុនៃសិទ្ធិលើការបញ្ចាំរបស់តតិយជន ឬ កម្មវត្ថុនៃការរឹបអូសរបស់តតិយជន ឬ វាជាកម្មវត្ថុផ្សេងទៀតនៃតតិយជន ប្រសិនបើកាតព្វកិច្ចត្រូវរលត់ (ដោយព្យាកុលភាព) វានឹងមានប៉ះពាល់ដល់ផលប្រយោជន៍របស់តតិយជន ហេតុដូច្នេះ ចាំបាច់ត្រូវមានច្បាប់បញ្ញត្ត (មាត្រា៥៧៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី) ថា សិទ្ធិលើបំណុល ឬ កាតព្វកិច្ចមិនត្រូវរលត់ក្នុងករណីបែបនេះនោះឡើយ។

## ផ្នែកទី ៣. អាជ្ញាយុកាលនៃការរំលត់សិទ្ធលើបំណុល

### កថាខ័ណ្ឌ១. និយមន័យ និង អាជ្ញាយុកាលនៃសិទ្ធលើបំណុល

#### ១. និយមន័យ

**អាជ្ញាយុកាលនៃការរំលត់សិទ្ធលើបំណុល** សំដៅទៅលើការរំលត់សិទ្ធលើបំណុលដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តន៍សិទ្ធ ក្នុងកំឡុងពេលដែលត្រូវបានកំណត់ ។

#### ១.១. ល័ក្ខនៃអាជ្ញាយុកាលនៃសិទ្ធលើបំណុល

#### ក. ពេលចាប់ផ្តើមគិតអាជ្ញាយុកាលនៃសិទ្ធលើបំណុល

យោងតាមមាត្រា ៤៨១ នៃក្រមរដ្ឋប្បវេណី ជាទូទៅ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ពីពេល ដែលសិទ្ធិលើបំណុលនោះ អាចត្រូវបានអនុវត្តបាន ។

ពេលដែលអាចអនុវត្តសិទ្ធិលើបំណុល មានន័យថា ពេលដែលលែងមានឧបសគ្គតាមផ្លូវច្បាប់ ក្នុងការអនុវត្តសិទ្ធិលើបំណុលនោះ ។

សូមកត់សំគាល់ថា ជួនកាល ពេលដែលសិទ្ធិលើបំណុលកើតមានឡើង និង ពេលដែលអាចអនុវត្តសិទ្ធិលើ បំណុល គឺខុសគ្នា ។

**ឧទាហរណ៍៖** ប្រសិនបើមានកំណត់ពេលពិតប្រាកដ សំរាប់អនុវត្តកាតព្វកិច្ច ម្ចាស់បំណុល មិនអាចអនុវត្ត សិទ្ធិលើបំណុលរបស់ខ្លួន នៅមុនពេលកំណត់នោះបានទេ។ ហេតុដូច្នេះ អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិ លើបំណុល ត្រូវចាប់គិតពីពេលនោះមក ។

ប្រសិនបើមានកំណត់ពេលពិតប្រាកដសំរាប់អនុវត្តកាតព្វកិច្ច ម្ចាស់បំណុល មិនអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួន នៅមុនពេលកំណត់នោះបានឡើយ ។ ហេតុដូច្នេះ៖ អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើ បំណុល ត្រូវចាប់គិតពីពេល ដែលពេលកំណត់មិនពិតប្រាកដនោះបានមកដល់ ។

ប្រសិនបើ មិនបានកំណត់ពេលសំរាប់អនុវត្តកាតព្វកិច្ចទេ ម្ចាស់បំណុល អាចទាមទារឱ្យអនុវត្តកាតព្វកិច្ច នៅពេលណាក៏បានដែរ ហេតុដូច្នេះ អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវចាប់គិតពីពេលដែល សិទ្ធិលើបំណុលនោះ កើតមានឡើង។

ទោះបីជាមានឧបស័គ្គជាក់ស្តែងក្នុងការអនុវត្តសិទ្ធ ដូចជាក្នុងករណីដែលម្ចាស់បំណុលមិនបានដឹងថា ខ្លួនមានសិទ្ធក៏ដោយ ក៏កំឡុងពេលនៃអាជ្ញាយុកាលនៃការរលត់សិទ្ធលើបំណុលបន្តទៅមុខដែរ ។

**ឧទាហរណ៍៖** ក្នុងករណីដែលឪពុក ឬ ម្តាយ ពេលគាត់នៅរស់ បានឲ្យអ្នកផ្សេងបានខ្ចីប្រាក់ ហើយសន្យាថា និងសងក្នុងពេល ៦ខែ ក្រោយ ទោះបីជាកូនបានធ្វើសន្តតិកម្មនីវសិទ្ធលើបំណុលនោះមិនបានដឹងថា មានសិទ្ធលើបំណុលនោះក៏ដោយ ក៏ឲ្យពេលវេលា ៦ខែ បានកន្លងផុតទៅពីពេលដែលឲ្យខ្ចីប្រាក់នោះ នោះ

គឺជា ពេលដែលអនុវត្តសិទ្ធ មានន័យថាឧបស័គ្គក្នុងការអនុវត្តសិទ្ធបានរលត់ទៅហើយ ហេតុដូច្នេះពីពេលនោះ អាជ្ញាយុកាលនៃការរំលត់សិទ្ធលើបំណុលមានដំណើរការ ។

### ខ. រយៈពេលនៃអាជ្ញាយុកាលនៃសិទ្ធលើបំណុលទូទៅ និង រយៈពេលខ្លី

ជាគោលការណ៍ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមានរយៈពេល **៥ ឆ្នាំ** (មាត្រា ៤៨២) ។ ប៉ុន្តែ ទាក់ទងនឹងសិទ្ធិលើបំណុលថ្លៃទិញទំនិញ ឬ សេវា រវាងផលិតករ ឬ ពាណិជ្ជករលក់ទៅអោយអ្នកដែលមិនមែនជា ពាណិជ្ជករ គឺរយៈពេលនៃអាជ្ញាយុកាលមានត្រឹមតែ **២ ឆ្នាំ** ទេ ព្រោះសិទ្ធិលើបំណុលចំពោះអ្នកប្រើប្រាស់ក្នុងកិច្ច ប្រតិបត្តិការរបស់អ្នកប្រើប្រាស់ មានការពិបាកនឹងរក ព្រមទាំងរក្សាទុកនូវភស្តុតាងនៃការសង ហេតុនេះហើយ ទើបកំណត់ក្នុងរយៈពេលខ្លី (មាត្រា ៤៩៣) ចំពោះសិទ្ធលើបំណុលស្តីពីថ្លៃទំនិញដែលផលិតករ ឬ ពាណិជ្ជករបានលក់ទៅឲ្យអ្នកដែលមិនមែនជាពាណិជ្ជករ ព្រមទាំងថ្លៃសេវាដែលពាណិជ្ជករបានផ្តល់ទៅឲ្យអ្នកដែលមិនមែនជាពាណិជ្ជករ ។

**ឧទាហរណ៍៖** ក ទិញទំនិញនៅហាងរបស់ ខ នៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១១ អត់បានឲ្យលុយ ។ ដូច្នេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺមានរយៈពេលតែ ២ ឆ្នាំ គិតចាប់ ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១១ ។

### គ. អំឡុងពេលអាជ្ញាយុកាលនៃអាជ្ញាយុកាលនៃសិទ្ធលើបំណុលដែលចូលជាស្ថាពរ

ចំពោះសិទ្ធិលើបំណុល ដែលបានចូលជាស្ថាពរ ដោយអានុភាពសាលក្រម ឬ សាលដីកាស្ថាពរ ឬ ការផ្សះផ្សា តាមផ្លូវតុលាការ ឬ វិធីផ្សេងទៀតដែលមានអានុភាពដូចនឹងសាលក្រមស្ថាពរ រយៈពេលនៃអាជ្ញាយុកាល ត្រូវមាន អំឡុងពេល **៥ ឆ្នាំ** គិតចាប់ពីពេលដែលសិទ្ធិលើបំណុលដើមចូលជាស្ថាពរដែរ ។ អំឡុងពេលដែលអាជ្ញាយុកាលនៃការរំលត់សិទ្ធលើបំណុលគិតចាប់ផ្តើមជាថ្មីនេះ ត្រូវមានភាពស្មើគ្នានឹង អំឡុងពេលដែលអាជ្ញាយុកាលដែលបានកំណត់ពីដើមសម្រាប់សិទ្ធលើបំណុលនេះ ព្រោះដោយហេតុនៃការផ្អាកនៃការរំលត់សិទ្ធលើបំណុលផ្សេងៗ ។ ផ្ទុយមកវិញ បើនៅពេលដែលលិខិតទាំងនោះ ចូលជាស្ថាពរមុនពេលកំណត់ត្រូវអនុវត្តមិនទាន់ដល់ រយៈពេលនៃអាជ្ញាយុកាល គឺមាន រយៈពេល ៥ ឆ្នាំ ឬ ២ ឆ្នាំ គិតចាប់ពីពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចមកដល់ (មាត្រា ៤៨៤) ។

## កថាខ័ណ្ឌ២. ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការផ្អាកអាជ្ញាយុកាល គឺជាការបញ្ឈប់ដំណើរការនៃអជ្ញាយុកាល ដោយអំឡុងពេលដែលបានដំណើរការកន្លងមក ត្រូវទុកជាមោឃៈ។

### ២.១. ហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវបានផ្អាកក្នុងករណីដូចតទៅះ

**ក. ការទាមទារតាមផ្លូវតុលាការ** ការចូលរួមក្នុងនីតិវិធីធនក្ស័យ ឬ ការអនុវត្តសិទ្ធិដែលមាន លក្ខណៈប្រហាក់ប្រហែល។ ការទាមទារតាមផ្លូវតុលាការ គឺជាហេតុមួយដែលនាំឲ្យមានកាតផ្អាកអជ្ញាយុកាល ក៏ប៉ុន្តែក្នុងករណីប្រសិនបើបណ្តឹងត្រូវបានលើកចោល ឬត្រូវបានដកពាក្យបណ្តឹងវិញ នោះការការដាក់ពាក្យបណ្តឹងដែលបានធ្វើកន្លងមក មិនត្រូវបង្កើតអនុភាពនៃការផ្អាកអាជ្ញាយុកាលនោះទេ ។ ដែល ការលើកបណ្តឹងចោលនៅក្នុងករណីនេះ ដោយសារមូលហេតុខាងនីតិវិធី និងការច្រានចោលនៃបណ្តឹងដោយមូលហេតុសារធាតុផ្សេងៗផងដែរ។

**ខ. សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារ។**

ដែលហៅថាសកម្មភាពអនុវត្តដោយបង្ខំ គឺសម្តៅទៅលើសកម្មភាពដែលមានគោលបំណងដើម្បីរឹបអូសការអនុវត្តសិទ្ធិទាមទារផ្សេងទៀត ដូចជាការអនុវត្តសិទ្ធិទាមទារឲ្យប្រគល់វត្ថុជាដើម និងការអនុវត្តសិទ្ធិប្រាតិភោគ។ ចំណែកឯ សកម្មភាពចាត់ចែងការរក្សាការពារគឺសម្តៅទៅលើការរឹបអូសជាបណ្តោះអាសន្ន និងចាត់ចែងជាបណ្តោះអាសន្ន។ អ្វីដែលចង់បង្ហាញ គឺសកម្មភាពទាំងពីរនេះជាសកម្មភាពដែលបញ្ជាក់យ៉ាងច្បាស់លាស់នូវការអះអាងសិទ្ធិពីសំណាក់ម្ចាស់បំណុល ដែលហេតុដូច្នេះហើយទើបច្បាប់ (ក្រមរដ្ឋប្បវេណី) នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិចាត់ទុកថាជាហេតុនាំឲ្យផ្អាកអាជ្ញាយុកាល។ អាជ្ញាយុកាល ត្រូវផ្អាកនៅពេលដែលបានដាក់ពាក្យសុំអនុវត្តដោយបង្ខំ ឬ បានដាក់ពាក្យសុំចាត់ចែងការរក្សាការពារ ដោយមានមូលហេតុសមស្រប។ តែនៅក្នុងករណីដែលការចាត់ចែងអនុវត្តដោយបង្ខំ ឬ ចាត់ចែងការរក្សាការពារ ត្រូវបានលុបចិល តាមពាក្យសុំរបស់ភាគី ឬ ដោយសារការខ្វះខាតលក្ខខណ្ឌតាមផ្លូវច្បាប់ គឺចាត់ទុកថា មិនមានការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ។ហេតុដូច្នេះហើយ ប្រសិនបើម្ចាស់បំណុលបានដកពាក្យសុំរបស់ខ្លួន ឬក្នុងករណីដែលមានការលុបចោលដីកាសម្រេចរក្សាការពារ បន្ទាប់ពីមានការតវ៉ារបស់កូនបំណុល នោះការដាក់ពាក្យសុំអនុវត្តដោយបង្ខំ ឬ ការដាក់ពាក្យសុំឲ្យចេញដីការក្សាការពារដែលបានធ្វើកន្លងមកនោះមិនត្រូវបានចាត់ទុកថាមានអនុភាពនាំឲ្យមានការផ្អាកអាជ្ញាយុកាលឡើយ។ បើទោះបីជាមានបទបញ្ញត្តិចែងយ៉ាងដូច្នេះក៏ដោយ ក៏អនុភាពនៃការផ្អាកអាជ្ញាយុកាល នៅតែមានអនុភាពដដែរ នៅពេលដែលវិនិច្ឆ័យឃើញថា ការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលបានធ្វើឡើង ដោយត្រឹមត្រូវ ឬ ដោយមូលហេតុផ្សេងៗទៀត ដូចជាការដាក់ប្រាតិភោគ ការផ្ញើរប្រាក់រំដោះជាដើមរបស់ម្ចាស់បំណុល នោះការលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ឬ ការចាត់ចែងរក្សាការពារមិនអាចត្រូវបានកើតឡើងនោះទេ។

**ឧទាហរណ៍៖** លោក ចិត្រា បានខ្ចីប្រាក់ពី វឌ្ឍនៈ ចំនួន ២០លានរៀល ដោយកំណត់ថាសងវិញក្នុងរយៈពេល ៦ខែ។ តែក្រោយមក លោក ចិត្រា មិនបានបំពេញករណីកិច្ចរបស់គាត់នោះទេ អស់រយៈពេល ៨ឆ្នាំមកទើបលោក វិឌ្ឍនៈ បានដាក់ពាក្យសុំឲ្យចេញដីការសម្រេចរក្សាការពារ ដើម្បីរឹបអូសជា បណ្តោះអាសន្ន នូវត្រាក់ទ័រមួយគ្រឿងរបស់លោក ចិត្រា។ ប៉ុន្តែ បន្ទាប់មក លោក ចិត្រា បានផ្ញើរប្រាក់ចំនួន ២០លានរៀល នៅ

តុលាការ ហើយតុលាការបានលុបចោលការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន (តាមអត្ថន័យបញ្ញត្តិក្នុងមាត្រា ៤៦៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ដោយធ្វើរប្រាក់រំដោះពីការរឹបអូសបណ្ដោះអាសន្ន)។ ដែលករណីនេះ ត្រូវចាត់ទុកថា អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលមានរវាង លោក ចិត្រា និង លោក វឌ្ឍនៈ ត្រូវបានផ្អាកដោយសារការដាក់ពាក្យសុំឲ្យចេញដីការរក្សាការពារដែលបានធ្វើកន្លងមក ជាដដែរ។

គ. ការទទួលស្គាល់កាតព្វកិច្ច ដោយការសងមួយផ្នែក ការបង់ការប្រាក់ ការដាក់ប្រាតិភោគ ឬវិធីផ្សេង។

ប្រសិនបើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវបានកើតឡើងចំពោះកូនបំណុល ការផ្អាកអាជ្ញាយុកាលនឹងត្រូវមានអនុភាពដាច់ខាត ហើយក៏មានអនុភាពអនុភាពចំពោះអ្នកមានសិទ្ធិលើកឡើងដទៃទៀតដែរ។ តែប្រសិនបើការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះកើតឡើងក្រៅពីកូនបំណុល អានុភាពនៃការផ្អាកនោះមិនមែនជាអនុភាពដាច់ខាតនោះទេ។ ក្នុងករណីនៅពេលដែលកូនបំណុលបានទទួលអន្តិភាពនៃការតព្វកិច្ច ដោយបានធ្វើសកម្មភាពផ្សេងៗ នាំឲ្យម្ចាស់បំណុលមានជំនឿជឿជាក់ទៅលើកូនបំណុល ហើយមិនធ្វើការអនុវត្តសិទ្ធិរបស់ខ្លួននោះទេ។ ដោយយោងតាម(ក្រមរដ្ឋប្បវេណី) នៃព្រះរាជាណាចក្រកម្ពុជា បានចែងរៀបរាប់នូវសកម្មភាពផ្សេងៗរបស់កូនបំណុល ដែលចាត់ទុកថាជាការទទួលស្គាល់កាតព្វកិច្ច ពោលគឺ ការសងមួយផ្នែក ការបង់ការប្រាក់ ការដាក់ប្រាតិភោគ ជាដើម។

**ឧទាហរណ៍៖** លោក វ៉ាន់ថា បានឲ្យប្រាក់លោក ថុណា ខ្ចីចំនួន ៥ លានរៀល ដោយលោក ថុណា មានករណីយកិច្ចត្រូវបង់ការប្រាក់ចំនួន ៥ ម៉ឺនរៀល ក្នុងមួយខែ ក៏ប៉ុន្តែគូភាគី លោកវ៉ាន់ថា និង លោកថុណា មិនបានព្រមព្រៀងអំពីកាលកំណត់សងច្បាស់លាស់ណាមួយឡើយ។ ទោះជាយ៉ាងនេះក្ដី លោក ថុណា បាន បំពេញករណីកិច្ចបង់ការប្រាក់ជាទៀងទាត់ឱ្យទៅលោក វ៉ាន់ថា ជារៀងរាល់ខែ ក្នុងអំឡុងពេល ៤ ឆ្នាំ។ ដោយសារតែមូលហេតុនេះហើយ ទើបលោក វ៉ាន់ថា មិនដែលទាមទារឱ្យលោក ថុណា សងប្រាក់ដើមមកឱ្យរូបគាត់វិញនោះទេ។ក្នុងករណីបែបនេះ សកម្មភាពបង់ការប្រាក់ជារៀងរាល់ខែ គឺជាហេតុនៃការផ្អាកអាជ្ញាយុកាល ដូច្នេះហើយ ទោះបីជាលោក វ៉ាន់ថា មិនបានទាមទារប្រាក់ដើម ៥ លានរៀល ពីលោក ថុណា ក្នុងអំឡុងពេល ៤ ឆ្នាំ គិតចាប់ពីពេលធ្វើកិច្ចសន្យាខ្ចីបរិភោគមក ក៏ដោយ ក៏សិទ្ធិលើបំណុលនេះមិនរលត់ឡើយ។

### កថាខ័ណ្ឌទី ៣. ការបន្តខ់ការសម្រេចផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

នៅពេលដែលមានហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលដែលបានដំណើរការកន្លងមកត្រូវចាត់ទុកថាពុំមានអត្ថន័យតាមផ្លូវច្បាប់ឡើយ។ ដូចនេះ ត្រូវចាប់ផ្ដើមគិតអំឡុងពេលនៃអាជ្ញាយុកាលជាថ្មីម្ដងទៀត ក្រោយពី ហេតុនៃការផ្អាកបានចប់ (មាត្រា ៤៩៤ នៃក្រមរដ្ឋប្បវេណី)។ ជាក់ស្ដែង ចំពោះការទាមទារតាមផ្លូវតុលាការ ហេតុនៃការផ្អាកត្រូវចប់ នៅពេលដែល សេចក្ដីសម្រេចបានចូលជាស្ថាពរ ហើយហេតុនៃការផ្អាកក៏ត្រូវចប់ដែរ កាលបើនីតិ

វិធីនៃការអនុវត្តដោយបង្ខំ ឬការចាត់ចែងរក្សាការពារបានបញ្ចប់នោះ។ សម្រាប់ហេតុនៃការផ្អាកដែលជាការទទួលស្គាល់កាតព្វកិច្ចវិញ ហេតុនៃការផ្អាក បានចប់ ដំណាលគ្នានឹងពេលដែលអានុភាពនៃការផ្អាកបានកើតឡើង។

### ៣.១.ការបង្អង់ការសម្រេចផ្អាកអាជ្ញាយុកាលដោយការដាស់តឿននិងដោយការ ដាស់តឿនតាមផ្លូវតុលាការ

ការបង្អង់ការសម្រេចអាជ្ញាយុកាល គឺជាការបញ្ឈប់ដំណើរការអាជ្ញាយុកាល សម្រាប់តែអំឡុងពេលនៃការបង្អង់ប៉ុណ្ណោះ ដោយមិនធ្វើឱ្យអំឡុងពេលដែលបានដំណើរការកន្លងមក ត្រូវទុកជាអសារបង់នោះទេ។ និយាយបានម្យ៉ាងទៀតថា ការបង្អង់ការសម្រេចអាជ្ញាយុកាល គឺជាការបញ្ឈប់ដំណើរការអាជ្ញាយុកាលនៅដំណាក់កាលចុងក្រោយដែលជាពេលបញ្ចប់អំឡុងពេល អាជ្ញាយុកាល។ ដោយក្នុងន័យនេះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានជ្រើសរើសយករបបនៃការបង្អង់ការសម្រេចអាជ្ញាយុកាល បានសេចក្តីថា ប្រសិនបើមានហេតុនៃការបង្អង់បានកើតឡើង នៅពេលហៀបនឹងសម្រេចបាននូវអាជ្ញាយុកាល នោះនឹងត្រូវពន្យារពេលនៃការសម្រេច អាជ្ញាយុកាល។ របបនៃការបង្អង់ការសម្រេចអាជ្ញាយុកាល មានភាពខុសប្លែកពីការបង្អង់ដំណើរ ការនៃអាជ្ញាយុកាល ដែលអនុញ្ញាតឱ្យបញ្ឈប់ដំណើរការអាជ្ញាយុកាល ទោះបីជាមានហេតុនៃការ, បង្អង់នៅអំឡុងពេលណាក៏ដោយ។

ហេតុនៃការបង្អង់ការសម្រេចអាជ្ញាយុកាល មានបញ្ញត្តនៅមាត្រា ៤៩៥ រហូតដល់មាត្រា ៤៩៨ នៃក្រមរដ្ឋប្បវេណី រួមមានដូចតទៅ៖

#### ក-ការដាស់តឿន

យោងតាមមាត្រា ៤៩៥ នៃក្រមរដ្ឋប្បវេណីបានចែងថា ៖ ប្រសិនបើអ្នកមានសិទ្ធិបានដាស់តឿន នៅពេលណាមួយ ក្នុងអំឡុង ៦ ខែ មុនផុតអំឡុងពេលនៃអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល អាជ្ញា យុកាលរំលត់សិទ្ធិលើបំណុលនោះ មិនត្រូវបានសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ ខែបន្ទាប់ពី ការដាស់តឿនឡើយ។ ប៉ុន្តែទោះបីជាអ្នកមានសិទ្ធិដាស់តឿនម្តងទៀតក៏ដោយ ក៏មិនអាចពន្យាការសម្រេចអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល ដោយការដាស់តឿនម្តងទៀតនោះដែរ។ សូមធ្វើការកត់សម្គាល់ថា វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រាខាងលើនេះ មិនមែនចែងចំពោះករណី ដែលម្ចាស់បំណុលដាស់តឿនម្តងទៀត នៅក្នុងអំឡុងពេលនៃការរំលត់សិទ្ធិលើបំណុលដើមទេ ដូច្នេះបានសេចក្តីថា ឱ្យតែស្ថិតនៅក្នុងអំឡុងពេលនៃអាជ្ញាយុកាលដើម ម្ចាស់បំណុលអាចធ្វើការ ដាស់តឿនប៉ុន្មានដងក៏បានដែរ ហើយអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេច ក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីការដាស់តឿនចុងក្រោយ។

#### ខ-ការដាស់តឿនតាមផ្លូវតុលាការ

ត្រូវចាត់ទុកថាជាការដាស់តឿនតាមផ្លូវតុលាការ ចាប់ពីពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូនទៅភាគីម្ខាងទៀត រហូតដល់ពេលដែលបណ្តឹងត្រូវបានលើកចោល ឬ ដកវិញ នោះ។ ដូច្នេះ អាជ្ញាយុកាលមិនអាច

សម្រេចបានឡើយ ក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីការលើកបណ្ដឹងចោល ឬ ការដកពាក្យបណ្ដឹង។ ក្នុងន័យប្រហាក់ប្រហែលគ្នានេះដែរ ប្រសិនបើអ្នកមានសិទ្ធិ បានអះអាងពីសិទ្ធិរបស់ខ្លួន ក្នុងនាមជាចុងចម្លើយនៅក្នុងបណ្ដឹង ក៏ត្រូវចាត់ទុកថា អ្នកនោះបាន ដាស់តឿនជាបន្ត នៅក្នុងអំឡុងពេល បណ្ដឹងនេះតែម្ដង។ នៅក្នុងករណីនេះ អាជ្ញាយុកាលមិនត្រូវសម្រេចឡើយ ក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីសាលក្រម ឬសាលដីកានៃបណ្ដឹងនោះចូលជាស្ថាពរ។

### ៣.២.ការបង្អង់ការសម្រេចផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ចំពោះអនីតិជន ឬជននៅក្រោមអាណាបព្យាបាល

### ក.សិទ្ធិលើបំណុលចំពោះអនីតិជន ឬ អាណាព្យាបាលទូទៅ

មាត្រា ៤៩៦ នៃក្រមរដ្ឋប្បវេណីបានចែងថា ៖ ប្រសិនបើអនីតិជន ឬជននៅក្រោមអាណា ព្យាបាលទូទៅគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ នៅក្នុងអំឡុង 5 ខែ មុនផុតអំឡុងពេល អាជ្ញាយុកាលរំលត់សិទ្ធិលើបំណុលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះមិនត្រូវបាន សម្រេចឡើយ នៅក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីពេលដែលអ្នកនោះក្លាយជាសមត្ថជន ឬពេល ដែលអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបានជ្រើសតាំង។

### ខ.សិទ្ធិលើបំណុលរវាងប្ដីប្រពន្ធ

សិទ្ធិលើបំណុលដែលសហព័ទ្ធម្ខាង មានចំពោះសហព័ទ្ធម្ខាងទៀត មិនត្រូវសម្រេចឡើយ ក្នុងអំឡុងពេល ៦ ខែ ក្រោយពីការរលាយអាពាហ៍ពិពាហ៍ (មាត្រា ៤៩៧ នៃក្រមរដ្ឋប្បវេណី)។ ការរលាយអាពាហ៍ពិពាហ៍គឺក្រៅពីការរលាយដោយការលែងលះ រួមមានទាំងការរលាយដោយមរណភាពនៃសហព័ទ្ធ ដោយការប្រកាសអំពីការបាត់ខ្លួន និងដោយការលុបចោលអាពាហ៍ពិពាហ៍។

### គ.សិទ្ធិលើបំណុលដោយសារគ្រោះថ្នាក់មហន្តរាយធម្មជាតិ (ប្រធានសក្តិ)

នៅក្នុងករណីដែលមានគ្រោះមហន្តរាយធម្មជាតិ ដូចជាទឹកជំនន់ ការផ្ទុះភ្នំភ្លើង ជាអាទិ ឬ ករណីប្រធានសក្តិផ្សេងទៀត បានកើតឡើង នៅក្នុងពេលណាមួយ ក្នុងអំឡុង ៦ ខែ មុនពេលផុត អំឡុងពេលអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល នោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវសម្រេចឡើយ ក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីប្រធានសក្តិនោះបានកន្លងផុត (មាត្រា ៤៩៨ នៃក្រម រដ្ឋប្បវេណី)។

## កថាខណ្ឌ៣.អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ឬ កម្មសិទ្ធិមានអំឡុងពេល ១០ឆ្នាំ លើកលែងតែក្នុងករណីផ្សេងដែលចែងក្នុងក្រមនេះ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត។ ដែលដូចជា (មាត្រា ៤៨២ នៃក្រមរដ្ឋ

ប្បវេណី) បានចែងជាគោលការណ៍ អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មាន អំឡុងពេល ៥ឆ្នាំ ឬឯ កម្មសិទ្ធិវិញ មិនត្រូវរលត់ដោយអាជ្ញាយុកាលនៃការរំលត់សិទ្ធិទេ។

# ជំពូកទី ៣

# បញ្ហាប្រឈម

# និងដំណោះស្រាយ

# ជំពូកទី ៣. បញ្ហាប្រឈម និងដំណោះស្រាយ

## ផ្នែកទី ១. បញ្ហាប្រឈម

### កថាខ័ណ្ឌទី ១ បញ្ហាប្រឈមពាក់ព័ន្ធ ការខ្វះបទដ្ឋានគតិយុត្តិ

នៅក្នុងសកម្មភាពសព្វថ្ងៃនេះ បើទោះបីនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានបញ្ញត្តិស្តីពីការសង ការទូទាត់ ការលើកលែង ព្យាកុលភាព នវកម្ម យ៉ាងណាក៏ដោយ ក៏នៅតែមិនទាន់គ្រប់គ្រាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយនៅមានចំណុចចន្លោះខ្វះខាតជាច្រើន ដែលត្រូវកែតម្រូវ និងបំពេញបន្ថែមច្រើនទៀត ជាក់ស្តែងគឺបញ្ញត្តិនេះមានមាត្រាខ្លះចែងអំពីការរលត់កាតព្វកិច្ច មកតិចតួច មិនទាន់បានច្រើននៅឡើយទេ ដោយបទបញ្ញត្តិទាំងនេះមិនសូវមានភាពទូលំទូលាយនោះទេ ហើយក៏មិនសូវទទួលបានការប្រើប្រាស់ពីសំណាក់ប្រជាជននៅក្នុងសង្គមជាក់ស្តែងច្រើននោះទេ។ ហេតុនេះហើយនាំឲ្យវិសាលភាពនៃការអនុវត្តច្បាប់នៅក្នុងប្រទេសកម្ពុជា នៅមិនទាន់មានភាពល្អប្រសើរនៅឡើយ ទាំងការអនុវត្ត និងការយល់ដឹងផ្នែកច្បាប់របស់ប្រជាជនកម្ពុជាយើងនៅមានកម្រិត តាមការមើលឃើញភាគរយនៃប្រជាជនមានចំនួនតិចតួចណាស់ដែលបានយល់ដឹងពីច្បាប់ស្តីពីការរលត់កាតព្វកិច្ចនេះ ដែលវាជាសកម្មភាពមួយដែលតែងតែកើតមានឡើងជាប្រចាំស្ទើរតែរៀងរាល់ថ្ងៃនៅក្នុងសង្គម។

ការខ្វះខាតផ្នែកនៃបទបញ្ញត្តិមិនទាន់ទូលំទូលាយ ក៏ដូចជាការមិនសូវមានការប្រើប្រាស់នៅក្នុងសង្គមជាក់ស្តែង គឺជាបញ្ហាប្រឈមដ៏ធំនិងចាំបាច់ ដែលត្រូវស្វែករកដំណោះស្រាយមួយដ៏ល្អប្រសើរ ដើម្បីផ្សព្វផ្សាយ ឲ្យសាធារណជនយល់ដឹងកាត់តែច្បាស់ ដើម្បីបង្កជាភាពងាយស្រួលសម្រាប់ការអនុវត្តស្របទៅតាមច្បាប់បញ្ញត្តិមួយដែលតឹងរឹង មានប្រសិទ្ធភាព ក្នុងការការពារផលប្រយោជន៍នៃបុគ្គលដែលប៉ះពាល់។

### កថាខ័ណ្ឌទី ២. បញ្ហាប្រឈមពាក់ព័ន្ធ អាជ្ញាយុកាលនៃការរំលត់សិទ្ធលើបំណុល

រាល់ចំណងនៃកាតព្វកិច្ចតែងតែមានអាជ្ញាយុកាលរបស់វា ដូចជាសិទ្ធលើបំណុលនេះ គឺបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចែងយ៉ាងច្បាស់នៅក្នុងមាត្រា៤៨២ (អាជ្ញាយុកាលនៃរំលត់សិទ្ធិលើបំណុល) បញ្ញត្តិថា អាជ្ញានៃការរលត់សិទ្ធិលើបំណុល មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រម ឬ ច្បាប់ឬបទដ្ឋានគតិយុត្តផ្សេង។ ដែលវាជាបញ្ញត្តិមួយដែលក្រើនរំលឹកដល់ម្ចាស់សិទ្ធិលើបំណុលគ្រប់រូប គប្បីប្រុងប្រយ័ត្នឲ្យបានខ្ពស់ ក្នុងការទាមទារផលប្រយោជន៍(បំណុលជាប្រាក់ ឬវត្ថុផ្សេងៗ)របស់ខ្លួនមកវិញ។ ក្នុងករណីដែលផុតអាជ្ញាយុកាល ដែលមានន័យថា ថ្លោះសិទ្ធិក្នុងការប្តឹងទាមទារប្រាក់ ដែលច្បាប់បានកំណត់ហើយថាមានរយៈពេល ៥ (ប្រាំ) ឆ្នាំ កំណត់ម្ចាស់បំណុលក្នុងការអនុវត្តសិទ្ធិសង។

ជាក់ស្តែកមានករណីមួយបានកើតឡើង ដោយមានចំណងកាតព្វកិច្ច(ខ្ចីប្រាក់)មួយបានកើតឡើង ដោយកូនបំណុល មិនបានអនុវត្តន៍កាតព្វកិច្ចត្រឹមត្រូវក្នុងការសងលុយទៅម្ចាស់បំណុលវិញនោះទេ ។ក្រោយមក អស់រយៈពេល ៥ (ប្រាំ) ឆ្នាំជាងមក ម្ចាស់បំណុលមានចង់ អនុវត្តន៍សិទ្ធិការសងទៅលើកូនបំណុល ប៉ុន្តែវាផុតអាជ្ញាយុកាលទៅហើយដែលច្បាប់កំណត់ថាមាន រយៈពេលត្រឹមតែ ៥ (ប្រាំ) ឆ្នាំ ។ ដូច្នេះនាំឲ្យអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវបានផុតដែលជាហេតុនាំឲ្យម្ចាស់បំណុលមិនអាចទាមទារអនុវត្តន៍សិទ្ធិសងទៅលើបំណុលរបស់ខ្លួនទេ។

### កថាខ័ណ្ឌទី ៣. បញ្ហាប្រឈមពាក់ព័ន្ធនិង ការមិនអនុវត្ត ការសង

នៅក្នុងសង្គមសេដ្ឋកិច្ចទីផ្សារ បុគ្គលឯកជនម្នាក់ៗដែលជាសមាជិកសង្គមនោះ ចូលរួមក្នុងជីវភាពសេដ្ឋកិច្ច តាមរយៈការដោះដូរទំនិញ និង សេវា ដោយប្រើរូបិយវត្ថុជាចម្បង ។ ជាធម្មតា ការដោះដូរទំនិញ និងសេវាត្រូវបានធ្វើឡើងតាមរយៈកិច្ចសន្យា ឬ ការសន្យារវាងបុគ្គលម្នាក់ និង បុគ្គលម្នាក់ទៀត។ នៅក្នុងករណី ជាច្រើន បុគ្គលនានា ប្រតិបត្តិតាមកិច្ចសន្យា គោរពសិទ្ធិរបស់ភាគីម្ខាងទៀត ហើយអនុវត្តករណីយកិច្ចរបស់ខ្លួនដោយសេចក្ដីសុចរិត។ វាជាការធម្មតា ដែលប្រជាពលរដ្ឋរស់នៅក្នុងប្រទេសនីតិរដ្ឋ ត្រូវតែគោរពច្បាប់។ ក៏ដូចគ្នាផងដែរ បុគ្គលនានា តាំងចិត្តគោរពការសន្យារបស់ខ្លួន ដោយបុព្វហេតុនៃទំនុកចិត្តលើសង្គម ឬ ដោយ បុព្វហេតុសាសនា ។

**ឧទាហរណ៍៖** ជាក់ស្ដែងចំពោះបញ្ហាមួយដែលកើតមានឡើងរវាងភាគីដើមចោទឈ្មោះ **វិចិត្រ** ចាប់ពីពេលនេះហៅ □ និង ចុងចម្លើយឈ្មោះ **មានរិទ្ធ** ចាប់ពីពេលនេះហៅ □ ជារឿងក្ដីមួយដែល □ បានខ្ចីប្រាក់ចំនួន ១០ លានរៀលពី □ ដែលការខ្ចីនោះ កើតឡើងនៅថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ។ ក្នុងករណីនេះនៅពេលដល់កាលបរិច្ឆេទកំណត់ដែលត្រូវសង □ មិនបានសងប្រាក់ចំនួន ១០ លានរៀលនោះ មកវិញទេទើបធ្វើឲ្យមានទំនាស់កើតឡើងរហូត □ បានប្ដឹងទាមទារតាមផ្លូវតុលាការ ។ ជាទូទៅ □ នឹងសងប្រាក់កំចីនេះ ទៅឱ្យ □ វិញនៅកាលបរិច្ឆេទកំណត់ដែលត្រូវសង ហើយជាលទ្ធផល គឺពុំមានវិវាទអំពីប្រាក់កំចីរវាង ដើមចោទ និង ចុងចម្លើយ ឡើយអាស្រ័យហេតុនេះ អ្នកទាំងពីរនឹងបន្តជីវភាពសេដ្ឋកិច្ចទៅមុខទៀត ដោយភាពរលូន។ ក៏ប៉ុន្តែក្នុងបញ្ហានេះ ចុងចម្លើយមិនបានធ្វើការសងប្រាក់ដែលបានខ្ចីទៅឲ្យចុងដើមចោទវិញទេ ទើបចោទជាបញ្ហា ហើយក៏ដូចជាមានមានផលប៉ះពាល់ជាច្រើនទៅលើ បុគ្គលទាំងពីរដែលមានវិវាទនឹងគ្នាដូចជា ខាតបង់ពេលវេលាក្នុងការប្រកមមុខរបររកស៊ី ក៏ដូចជា ការមិនសងនូវប្រាក់ ការមិនទូទាត់នូវប្រាក់ ឬអត្រាត្រាការប្រាក់ ឬមិនអនុវត្តកាតព្វកិច្ចជាដើម ដែលមានក្នុងកិច្ចសន្យា ។

### ផ្នែកទី ២ ដំណោះស្រាយ

ជាគោលការណ៍ចំពោះដំណោះស្រាយគឺមានការដោះស្រាយតាមប្រព័ន្ធតុលាការ និង ក្រៅប្រព័ន្ធតុលាការ។ ច្បាប់គោរពនូវឆន្ទៈរបស់បុគ្គល ហើយអនុញ្ញាតឱ្យបុគ្គលអាចកំណត់នូវវិធានផ្ទាល់ខ្លួន ដោយផ្អែកលើឆន្ទៈសេរីរបស់ពួកគេ ចំពោះបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងជីវភាពសេដ្ឋកិច្ច ដែលរួមមាន ការដោះដូរទំនិញ និង សេវា (លក់ ជួល ជាដើម) ។ បុគ្គលឯកជនអាចធ្វើការសម្រេចចិត្ត ដោយផ្អែកតាម ឆន្ទៈរបស់ខ្លួនដូចជាការសម្រេចថា ទំនិញឬសេវាបែបណាដែលត្រូវទិញវត្ថុផ្សំបែបណាដែលត្រូវរក ផលិតផលបែបណាដែលត្រូវផលិត និង លក់ជាដើម។ លើសពីនេះទៅទៀត បុគ្គលឯកជនត្រូវបានចង តែដោយសេចក្ដីសម្រេចរបស់ខ្លួនតែប៉ុណ្ណោះ ហើយរដ្ឋមិនអាចជ្រៀតជ្រែក ឬ ដាក់កំហិតទៅលើសេចក្ដី សម្រេចរបស់បុគ្គលនោះបានឡើយ។ យន្តការច្បាប់បែបនេះ គឺឈរលើមនោគមវិជ្ជាសេរីនិយម និង បុគ្គលនិយម ដែលថា ការមិនជ្រៀតជ្រែកក្នុង

សកម្មភាពសេដ្ឋកិច្ច អាចជាចំណែកនៃអភិវឌ្ឍន៍សង្គម។ យន្តការដែលតាមរយៈនេះ បុគ្គលឯកជនអាចធ្វើការសម្រេចចិត្តដោយសេរី នៅក្នុងជីវភាពសេដ្ឋកិច្ចរបស់ខ្លួន គេហៅថា "គោលការណ៍ស្វ័យភាពរបស់ឯកជន។

**កថាខ័ណ្ឌទី ១.ដំណោះស្រាយពាក់ព័ន្ធ ការខ្វះបទដ្ឋានគតិយុត្តិ**

ចំពោះបញ្ហាដែលកើតមានឡើងជាច្រើននៅក្នុងសង្គមបច្ចុប្បន្ន ពាក់ព័ន្ធការខ្វះខាតបទដ្ឋាកគតិយុត្តគឺជាបញ្ហាមួយដែលចោទជាបញ្ហាខ្លាំងដែលកំពង់ជួបប្រទះ និង តម្រូវអោយមានការដោះស្រាយ ជាពិសេសតម្រូវអោយមានការពិនិត្យ និងបំពេញបន្ថែម នូវបញ្ញាត្តិ ឬ បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនិង ការរលត់កាតព្វកិច្ច ដែលក្នុងនោះបញ្ញាត្តិដែលស្តីពី ការសង ការទូទាត់ ការលើកលែង ព្យាកុលភាព នវកម្ម គឺមិនសូវមានភាពទូលំទូលាយនៅឡើង ហើយម្យ៉ាងវិញទៀតនោះ មិនសូវទទួលបានការប្រើប្រាស់ពីសំណាក់ប្រជាជននៅក្នុងសង្គមជាក់ស្តែងច្រើននោះទេ ។

ចំពោះបញ្ហានេះ គឺត្រូវស្វែងរកការដោះស្រាយមួយដ៏ល្អ ក៏ដូចជាមានប្រសិទ្ធភាពនោះ រាជរដ្ឋាភិបាលគួរតែបង្កើតនូវច្បាប់ដែលចែងច្បាស់លាស់ និងល្អិតល្អន់អំពីបញ្ហាអំពី ការរលត់កាតព្វកិច្ច ដើម្បីឲ្យស្ថាប័នដែលពាក់ព័ន្ធ អាចអនុវត្តប្រកបដោយប្រសិទ្ធភាព និងកាន់តែល្អប្រសើរជាងនេះ ក៏ដូចជាជួយលើកម្ពស់ការអភិវឌ្ឍន៍ច្បាប់នៅប្រទេសកម្ពុជាប្រកបដោវឌ្ឍភាព និងស្របទៅតាមច្បាប់បញ្ញាត្តិមួយដែលតឹងរឹង ដើម្បីការពារផលប្រយោជន៍នៃបុគ្គលដែលប៉ះពាល់ ។

**កថាខ័ណ្ឌទី ២ ដំណោះស្រាយ តាមប្រព័ន្ធតុលាការ**

រីឯចំពោះការដោះស្រាយ**តាមប្រព័ន្ធតុលាការ**វិញ វិវាទរវាងបុគ្គលឯកជន មិនអាចដោះស្រាយបាន តាមរយៈការប្រឹងប្រែង ដោយស្ម័គ្រចិត្ត និង ដោយឆន្ទានុសិទ្ធិរបស់ភាគីឡើយ ។ នៅក្នុងឧទាហរណ៍ខាងលើអាចនឹងមានករណី ដែលពុំអាចឈានទៅដល់ការផ្សះជា ឬ ការព្រមព្រៀងគ្នាថានឹងគោរពតាមសេចក្តីសម្រេចរបស់តតិយជន ( កិច្ចសន្យាមជ្ឈត្តកម្ម) ដោយហេតុថា ទាំងភាគី A និង ភាគី B ពុំបានធ្វើសម្បទានឱ្យគ្នាទៅវិញទៅមកឡើយ ។ ទៅក្នុងករណីបែបនេះ ទោរបីជាការអះអាងរបស់ A មានភាពត្រឹមត្រូវ ហើយ A មានសិទ្ធិទាមទារឱ្យ B សងប្រាក់ចំនួន ១០ លានរៀល មកខ្លួនក៏ដោយ ប្រសិនបើ A ត្រូវបានអនុញ្ញាតឱ្យធ្វើការប្រមូលប្រាក់ពី B ដោយខ្លួនឯងនោះ នឹងធ្វើឱ្យប៉ះពាល់ដល់សេចក្តីសុខសាន្តក្នុងសង្គម។ នៅក្នុងករណីដោយឡែកទៅវិញ បើទោះបីជាការអះអាងរបស់ B មានភាពត្រឹមត្រូវក៏ដោយ ក៏អាចមានករណីដែល A ប្រើប្រាស់កម្លាំង ដើម្បី ប្រមូលប្រាក់ ១០ លានរៀលនោះពី B ដោយយកលេសថាជាការអនុវត្តសិទ្ធិរបស់ខ្លួនដែរ ។ ហេតុដូច្នេះហើយ នៅក្នុងប្រទេសទំនើប ជាគោលការណ៍ ការសង្គ្រោះដោយខ្លួនឯង ដោយប្រើកម្លាំងបែបនេះ ត្រូវបានហាមឃាត់ (ការហាមឃាត់ការសង្គ្រោះដោយខ្លួនឯង)។ រដ្ឋត្រូវបង្កើតតុលាការ ហើយប្រសិនបើមាពាក្យបណ្តឹង ពីភាគីណាមួយ វិតុលាការត្រូវកោះហៅតួភាគីទាំងសងខាងដោយមិនគិតពីឆន្ទៈ នៃភាគីម្ខាងទៀត ត្រូវ ឱ្យភាគីធ្វើការអះអាង ត្រូវវិនិច្ឆ័យ (សម្រេចសេចក្តី) ទៅលើចំណុចថាតើអំណះអំណាងរបស់ភាគីមួយណា ដែលមានភាពត្រឹមត្រូវ និង ត្រូវបង្ខំឱ្យភាគីទាំងសងខាងអនុវត្តតាមសេចក្តីសម្រេចគោ។ ធ្វើបែបនេះ តើតុលាការតាំងចិត្តធ្វើការដោន

ស្រាយវិវាទរវាងភាគីទាំងពីរដោយបង្ខំ ។ នៅក្នុងឧទាហរណ៍ខាងលើ ប្រសិនបើ A ដាក់ពាក្យបណ្តឹងសុំឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យ B សងប្រាក់ ១០ លានរៀល មកខ្លួន ដោយ រនអាងថា ខ្លួនមានសិទ្ធិទាមទារឱ្យ B បង់ប្រាក់ទៅតុលាការត្រូវស្តាប់ការអះអាងរបស់ភាគីទាំងសងខាង ដោយមិនគិតពីឆន្ទៈរបស់ B ទេ ហើយចេញសាលក្រម ។ ប្រសិនបើតុលាការសម្រេចថា ការអះអាងរបស់ A មានភាពត្រឹមត្រូវ ហើយសម្រេចថា B ត្រូវសងប្រាក់ ១០លានរៀលទៅ A ហើយ B ត្រូវតែអនុវត្ត តាមសេក្តីសម្រេចទេ ។ ប្រព័ន្ធបែបនេះ គេហៅថា ប្រព័ន្ធរឿងក្តីរដ្ឋប្បវេណី ឬ ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ។

លើសពីនេះទៅទៀត រដ្ឋបានបង្កើតស្ថាប័នអនុវត្ត ដូចជាអាជ្ញាសាលា ដែលទទួលបន្ទុកក្នុងការសម្រេចសិទ្ធិដោយបង្ខំ ក្នុងគោលដៅការពារសិទ្ធិរបស់បុគ្គលឯកជន ។ ឧទាហរណ៍ នៅក្នុងករណីនៃសិទ្ធិទាមទារប្រាក់ ១០ លានរៀល ដែល A មានចំពោះ B ស្ថាប័នអនុវត្តនឹងធ្វើឱ្យសម្រេចនូវសិទ្ធិនេះ ដូចជាក្នុងស្ថានភាពដែល B ស្ម័គ្រចិត្តសងប្រាក់ដែលបានខ្ចីដែរ តាមរយៈការរឹបអូសចលនវត្ថុ អចលនវត្ថុ ឬ សិទ្ធិលើបំណុល ជាអាទិ៍ ដែល B ហើយប្តូរទ្រព្យសម្បត្តិទាំងនោនទៅជាប្រាក់ តាមវិធីផ្សេងៗដូចជាដាក់ដេញថ្លៃ ឬលក់ឡាយឡុង ឬ ទាមទារប្រមូលសិទ្ធិបំណុល ជាដើម ហើយបន្ទាប់មក ស្ថាប័នអនុវត្តនឹងដកប្រាក់ចំនួន ១០ លានរៀល ចេញពីប្រាក់ដែលប្រមូលបាននោះ ទៅឲ្យ A ។

ដូចនេះ បញ្ហាដែលកើតមានឡើងសព្វថ្ងៃដែលកើតមានឡើងជាគោលការណ៍ ច្បាប់គឺគោរពនូវឆន្ទៈរបស់បុគ្គល ហើយអនុញ្ញាតឱ្យបុគ្គលអាចកំណត់នូវវិធានផ្ទាល់ខ្លួន ដោយផ្អែកលើឆន្ទៈសេរីរបស់ពួកគេ ចំពោះបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងជីវភាពសេដ្ឋកិច្ច ហើយចំពោះដំណោះស្រាយវិញគឺគូភាគីទាំងសងខាងអាចជ្រើសយកតាមការដោះស្រាយតាម ប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ ។ ចំពោះការដោះស្រាយ ក្រៅប្រព័ន្ធតុលាការមាន ការសះជា មជ្ឈត្តកម្ម និង សន្ទានកម្ម អាចហៅបានថាជាវិធីដោះស្រាយវិវាទដោយ ស្ម័គ្រចិត្ត និង ដោយឆន្ទានុសិទ្ធិរបស់ភាគី ព្រោះថា ដំណោះស្រាយទាំងនោះត្រូវបានធ្វើឡើងដោយផ្អែកលើការ ព្រមព្រៀងរវាងភាគី និង ម្យ៉ាងវិញទៀតក៏នៅមានដំណោះស្រាយមួយនៅពេលដែលគូភាគីមិនអាចដោះស្រាយដោយសន្តិវិធី ឬ តាមការដោះស្រាយ តាមប្រព័ន្ធតុលាការ គឺគូភាគីសម្រេចយកតាមសេចក្តីសម្រេចរបស់តុលការ ។

### កថាខណ្ឌទី ៣. ដំណោះស្រាយ ក្រៅប្រព័ន្ធតុលាការ

រីឯចំពោះការដោះស្រាយ**តាមប្រព័ន្ធតុលាការ**វិញ វិវាទរវាងបុគ្គលឯកជន មិនអាចដោះស្រាយបាន តាមរយៈការប្រឹងប្រែង ដោយស្ម័គ្រចិត្ត និង ដោយឆន្ទានុសិទ្ធិរបស់ភាគីឡើយ ។ នៅក្នុងឧទាហរណ៍ខាងលើអាចនឹងមានករណី ដែលពុំអាចឈានទៅដល់ការផ្សះជា ឬ ការព្រមព្រៀងគ្នាថានឹងគោរពតាមសេចក្តីសម្រេចរបស់តតិយជន ( កិច្ចសន្យាមជ្ឈត្តកម្ម) ដោយហេតុថា ទាំងភាគី A និង ភាគី B ពុំបានធ្វើសម្បទានឱ្យគ្នាទៅវិញទៅមកឡើយ ។ ទៅក្នុងករណីបែបនេះ ទោរបីជាការអះអាងរបស់ A មានភាពត្រឹមត្រូវ ហើយ A មានសិទ្ធិទាមទារ

ឱ្យ B សងប្រាក់ចំនួន ១០ លានរៀល មកខ្លួនក៏ដោយ ប្រសិនបើ A ត្រូវបានអនុញ្ញាតឱ្យធ្វើការប្រមូលប្រាក់ពី B ដោយខ្លួនឯងនោះ នឹងធ្វើឱ្យប៉ះពាល់ដល់សេចក្តីសុខសាន្តក្នុងសង្គម។ នៅក្នុងករណីដោយឡែកទៅវិញ បើទោះបីជាការអះអាងរបស់ B មានភាពត្រឹមត្រូវក៏ដោយ ក៏អាចមានករណីដែល A ប្រើប្រាស់កម្លាំង ដើម្បី ប្រមូលប្រាក់ ១០ លានរៀលនោះពី B ដោយយកលេសថាជាការអនុវត្តសិទ្ធិរបស់ខ្លួនដែរ ។ ហេតុដូច្នេះហើយ នៅក្នុងប្រទេសទំនើប ជាគោលការណ៍ ការសង្គ្រោះដោយខ្លួនឯង ដោយប្រើកម្លាំងបែបនេះ ត្រូវបានហាមឃាត់ (ការហាមឃាត់ការសង្គ្រោះដោយខ្លួនឯង)។ រដ្ឋត្រូវបង្កើតតុលាការ ហើយប្រសិនបើមាពាក្យបណ្តឹង ពីភាគីណាមួយ វិតុលាការត្រូវកោះហៅគូភាគីទាំងសងខាងដោយមិនគិតពីឆន្ទៈ នៃភាគីម្ខាងទៀត ត្រូវ ឱ្យភាគីធ្វើការអះអាង ត្រូវវិនិច្ឆ័យ (សម្រេចសេចក្តី) ទៅលើចំណុចថាតើអំណះអំណាងរបស់ភាគីមួយណា ដែលមានភាពត្រឹមត្រូវ និង ត្រូវបង្ខំឱ្យភាគីទាំងសងខាងអនុវត្តតាមសេចក្តីសម្រេចគេ។ ធ្វើបែបនេះ តើតុលាការតាំងចិត្តធ្វើការដោះស្រាយវិវាទរវាងភាគីទាំងពីរដោយបង្ខំ ។ នៅក្នុងឧទាហរណ៍ខាងលើ ប្រសិនបើ A ដាក់ពាក្យបណ្តឹងសុំឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យ B សងប្រាក់ ១០ លានរៀល មកខ្លួន ដោយ រនអាងថា ខ្លួនមានសិទ្ធិទាមទារឱ្យ B បង់ប្រាក់ទៅតុលាការត្រូវស្តាប់ការអះអាងរបស់ភាគីទាំងសងខាង ដោយមិនគិតពីឆន្ទៈរបស់ B ទេ ហើយចេញសាលក្រម ។ ប្រសិនបើតុលាការសម្រេចថា ការអះអាងរបស់ A មានភាពត្រឹមត្រូវ ហើយសម្រេចថា B ត្រូវសងប្រាក់ ១០លានរៀលទៅ A ហើយ B ត្រូវតែអនុវត្ត តាមសេក្តីសម្រេចទេ ។ ប្រព័ន្ធបែបនេះ គេហៅថា ប្រព័ន្ធរឿងក្តីរដ្ឋប្បវេណី ឬ ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ។

លើសពីនេះទៅទៀត រដ្ឋបានបង្កើតស្ថាប័នអនុវត្ត ដូចជាអាជ្ញាសាលា ដែលទទួលបន្ទុកក្នុងការសម្រេចសិទ្ធិដោយបង្ខំ ក្នុងគោលដៅការពារសិទ្ធិរបស់បុគ្គលឯកជន ។ ឧទាហរណ៍ នៅក្នុងករណីនៃសិទ្ធិទាមទារប្រាក់ ១០ លានរៀល ដែល A មានចំពោះ B ស្ថាប័នអនុវត្តនឹងធ្វើឱ្យសម្រេចនូវសិទ្ធិនេះ ដូចជាក្នុងស្ថានភាពដែល B ស្ម័គ្រចិត្តសងប្រាក់ដែលបានខ្ចីដែរ តាមរយៈការរឹបអូសចលនវត្ថុ អចលនវត្ថុ ឬ សិទ្ធិលើបំណុល ជាអាទិ៍ ដែល B ហើយប្តូរទ្រព្យសម្បត្តិទាំងនោនទៅជាប្រាក់ តាមវិធីផ្សេងៗដូចជាដាក់ដេញថ្លៃ ឬលក់ឡាយឡុង ឬ ទាមទារប្រមូលសិទ្ធិបំណុល ជាដើម ហើយបន្ទាប់មក ស្ថាប័នអនុវត្តនឹងដកប្រាក់ចំនួន ១០ លានរៀល ចេញពីប្រាក់ដែលប្រមូលបាននោះ ទៅឲ្យ A ។

ដូចនេះ បញ្ហាដែលកើតមានឡើងសព្វថ្ងៃដែលកើតមានឡើងជាគោលការណ៍ ច្បាប់គឺគោរពនូវឆន្ទៈរបស់បុគ្គល ហើយអនុញ្ញាតឱ្យបុគ្គលអាចកំណត់នូវវិធានផ្ទាល់ខ្លួន ដោយផ្អែកលើឆន្ទៈសេរីរបស់ពួកគេ ចំពោះបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងជីវភាពសេដ្ឋកិច្ច ហើយចំពោះដំណោះស្រាយវិញគឺគូភាគីទាំងសងខាងអាចជ្រើសយកតាមការដោះស្រាយតាម ប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ ។ ចំពោះការដោះស្រាយ ក្រៅប្រព័ន្ធតុលាការមាន ការសះជា មជ្ឈត្តកម្ម និង សន្ធានកម្ម អាចហៅបានថាជាវិធីដោះស្រាយវិវាទដោយ ស្ម័គ្រចិត្ត និង ដោយឆន្ទានុសិទ្ធិរបស់ភាគី ព្រោះថា ដំណោះស្រាយទាំងនោះត្រូវបានធ្វើឡើងដោយផ្អែកលើការ ព្រមព្រៀងរវាងភាគី និង ម្យ៉ាងវិញទៀតក៏នៅមានដំណោះស្រាយមួយនៅពេលដែលគូភាគីមិនអាចដោះស្រាយ

ដោយសន្តិវិធី ឬ តាមការដោះស្រាយ តាមប្រព័ន្ធតុលាការ គឺគូភាគីសម្រេចយកតាមសេចក្តីសម្រេចរបស់តុលាការ ។

# សេចក្ដីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ “ការរំលត់កាតព្វកិច្ច” នេះ រួចមកខ្ញុំបាទអាចសន្និដ្ឋានបានថា សារៈសំខាន់ដែលកើតចេញពីការយល់ដឹងអំពីការរំលត់កាតព្វកិច្ច សម្រាប់សង្គម គឺជាកត្តាសំខាន់ក្នុងទំនាក់ទំនងប្រចាំថ្ងៃដោយបានការពារនូវប្រយោជន៍សាធារណៈ ក៏ដូចជាចំពោះគូភាគីនៃកិច្ចសន្យា។ ក្រៅអំពីផលប្រយោជន៍នេះផងដែរ ច្បាប់បានសម្របសម្រួល នូវទំនាក់ទំនងក្នុងសង្គម ដោយបង្កើននូវការជួយយកអាសាគ្នា ភាពយោគយល់ និងលើកលែងឲ្យ គ្នាទៅវិញទៅមក។ ម្យ៉ាងវិញទៀត ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នក៏មានការបញ្ញត្តិ ច្បាប់អំពីកាតព្វកិច្ចសម្រាប់អនុវត្តក្នុងទំនាក់ទំនងគតិយុត្តិរវាងម្ចាស់បំណុល និងកូនបំណុល ដោយ បង្ហាញយ៉ាងច្បាស់នូវសិទ្ធិ និងករណីកិច្ចចំពោះគូភាគី ហើយក៏រឹតបន្តឹងនូវការអនុវត្តដោយសុចរិត និងជៀសវាងការគេចវេះមិនព្រមអនុវត្តនូវកាតព្វកិច្ចនោះ។ បន្ថែមពីលើនេះ ការរលត់កាតព្វកិច្ចមាន ពីរប្រភេទដូចជា ការរលត់កាតព្វកិច្ចតាមគូភាគី និងការរលត់កាតព្វកិច្ចតាមច្បាប់កំណត់។

ចំពោះការរលត់កាតព្វកិច្ចតាមគូភាគី គឺជាការបង្ហាញនូវឆន្ទៈរបស់គូភាគីក្នុងការរំលត់នូវកាតព្វកិច្ចដោយភាពព្រមព្រៀង ក្នុងនោះផងដែរយើងឃើញថាវាជាដំណោះស្រាយមួយដែលមានភាពយោគ យល់ សន្ដោសប្រណីចំពោះគ្នាដើម្បីរក្សានូវទំនាក់ទំនងរបស់គូភាគី។ ដោយឡែកគូភាគីអាចធ្វើការ រំលត់នូវកាតព្វកិច្ចដោយ ការសង ការទូទាត់ ការលើកលែងរបស់ម្ចាស់បំណុល នវកម្ម ឬព្យាកុលភាព និងការទទួលបន្ទុកហានិភ័យ។

ចំណែកឯការរលត់កាតព្វកិច្ចតាមច្បាប់កំណត់នោះ គឺជាការរំលត់នូវកាតព្វកិច្ចដោយភាគីនៃកិច្ចសន្យា ឬភាគីណាម្ខាង បង្ហាញឆន្ទៈក្នុងការរំលត់នូវកាតព្វកិច្ចនោះ។ តាមរយៈកំហុសរបស់ភាគីម្ខាង នៃកិច្ចសន្យាមិនអនុវត្ត ឬអនុវត្តដោយបំពានទៅលើកិច្ចសន្យាធ្ងន់ធ្ងរបណ្ដាលឲ្យមិនអាចសម្រេច តាមគោលបំណងនៃកិច្ចសន្យា។ មួយផ្នែកទៀត ទាក់ទងនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ក៏បានកំណត់អំពីអាជ្ញាយុកាលកំណត់ផងដែរ សម្រាប់ការពារដល់ភាគីដែលអនុវត្តនូវកាតព្វកិច្ចនោះ ហើយវាបានបង្ហាញអោយភាគីដែលជាម្ចាស់បំណុល ត្រូវយកចិត្តទុកដាក់ទៅលើសិទ្ធិដែលខ្លួនមាន ជៀសវាងភាពធ្វេសប្រហែសបណ្ដាលឲ្យបាត់បង់សិទ្ធិនោះ។ កាតព្វកិច្ចនឹងត្រូវរលត់ក្នុងករណីដែល កិច្ចសន្យានោះបង្កើតឡើងដោយជនកម្រិតសមត្ថភាព ឬក្នុងករណីនៃការបង្ហាញឆន្ទៈក្នុងការបង្កើត កិច្ចសន្យាមានវិការៈ ភាគីណាម្ខាងដែលបានបង្ហាញថាភាគីម្ខាងទៀតបានបង្ហាញឆន្ទៈមានវិការៈនាំ ឲ្យភាគីនោះអាចរំលត់កាតព្វកិច្ចបាន។ កាតព្វកិច្ចដែលកំណត់ដោយច្បាប់រួមមាន ការរំលាយកិច្ច សន្យា ការផុតអាជ្ញាយុកាល និងការអនុវត្តសិទ្ធិលុបចោល។ ជារួម ច្បាប់ការពារដល់ផលប្រយោជន៍ គូភាគីដែលពាក់ព័ន្ធទៅនឹងកិច្ចសន្យា ហើយរក្សានូវភាពយុត្តិធម៌ចំពោះកូនបំណុល និងម្ចាស់បំណុល។

ក្នុងនោះផងដែរ គូភាគីនៃកិច្ចសន្យាអាចធ្វើការរំលត់កាតព្វកិច្ចដោយមានការព្រមព្រៀងគ្នា ដោយ ៖ អនុវត្តតាមវិធានមួយចំនួនខាងលើ ។

ស្របជាមួយគ្នានេះ ការអនុវត្តនូវការរំលត់កាតព្វកិច្ច ច្បាប់បានទុកនូវសិទ្ធិឲ្យភាគីធ្វើការ សម្រេចចិត្តក្នុងការជ្រើសរើសវិធានណាមួយដែលគ្មានការបង្ខំ និងស្របទៅតាមឆន្ទៈរបស់ភាគី។

តាមរយៈនេះផងដែរ អ្នកអនុវត្តច្បាប់មានការយកចិត្តទុកដាក់ក្នុងការសម្របសម្រួល និងទុកឱ កាសឲ្យភាគីបានសម្រេចចិត្តដោយខ្លួនឯង មុនពេលបញ្ចប់នូវកាតព្វកិច្ច និងមិនឲ្យភាគីណាមួយ បាត់បង់ផលប្រយោជន៍របស់ខ្លួន។

# អនុសាសន៍

# អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទរួចមក លទ្ធផលបានបង្ហាញឲ្យឃើញអំពីចំណុច ជាច្រើន ជាមូលហេតុនៃវិវាទ ទោះជាហេតុផលទាំងនោះផ្ដើមចេញពីឆន្ទៈ ឬក្រៅឆន្ទៈរបស់ភាគី។ ក្នុងការរួមចំណែកជម្រុញ និងលុបបំបាត់ភាពអសកម្មនានា ក្នុងជីវភាពគតិយុត្តទាក់ទងទៅនឹងបញ្ហា ខាងលើ ខ្ញុំបាទសូមអនុញ្ញាតធ្វើការលើកឡើងនូវអនុសាសន៍ដូចខាងក្រោម៖

គូភាគីចាំបាច់ត្រូវពិនិត្យឲ្យបានច្បាស់លាស់នូវកម្មវត្ថុនៃកិច្ចសន្យា ព្រមទាំងបង្ហាញអំពីមូល ហេតុជាក់លាក់ក្នុងការចុះកិច្ចសន្យា។ បន្ថែមពីលើនេះ ភាគីត្រូវយល់ដឹងពីផលប៉ះពាល់ដែលបណ្ដាល មកពីកម្មវត្ថុនៃកិច្ចសន្យា ដែលមិនត្រូវប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ក្នុងសង្គម។

គូភាគីចាំបាច់ត្រូវសម្ដែងនូវឆន្ទៈដោយពិតប្រាកដ និងសេរីភាព សុច្ចរិតទៀងត្រង់ ក្នុងអំឡុង ពេលចុះកិច្ចសន្យាជាមួយគ្នាដើម្បីជៀសវាងមានភាពមិនប្រក្រតីទាក់ទងនឹងការបង្ហាញឆន្ទៈនាំឲ្យ មានវិការៈកើតឡើង ដូចជា ការភាន់ច្រឡំ ការផ្ដល់ពត៌មានមិនពិត ការឆបោក និង ការកេងចំណេញ ហួសហេតុ។

គូភាគីត្រូវអនុវត្តកាតព្វកិច្ចដែលកើតចេញពីឆន្ទៈរបស់ខ្លួនដោយសុចរិត ស្មោះត្រង់រវាងគ្នា ទៅវិញទៅមក។ ក្នុងករណីដែលភាគីណាមួយមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួននោះ ភាគីត្រូវមាន ទំនួលខុសត្រូវចំពោះកំហុសរបស់ខ្លួន ហើយហ៊ានអះអាងដោយភាពពេញចិត្ត និងមិនស្ទើរស្ទាក់ក្នុង ការជួសជុលនូវសំណងការខូចខាតនោះ។ ក្នុងនោះផងដែរ ទាក់ទងនឹងការរំលត់កាតព្វកិច្ចដោយ ការលើកលែង វាបង្ហាញអំពីភាពអនុគ្រោះនៃភាគីគតិយុត្តិ និងជាកិច្ចដ៏ល្អប្រសើរនៅក្នុង ទំនាក់ទំនង សង្គម។ យ៉ាងណាមិញការអនុគ្រោះបែបនេះវានឹងមានកម្រិត ប្រសិនបើការយោគយល់ការសន្ដោស ប្រណី ការអនុគ្រោះនោះមិនបានកម្រិតវិញ វាអាចធ្វើឲ្យភាគីបាត់បង់ផលប្រយោជន៍ផងដែរ។

ចំពោះភាគីដែលជាម្ចាស់បំណុលទាក់ទងទៅនឹងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មិនត្រូវធ្វេសប្រហែស ប្រងើយកន្តើយ មិនយកទុកដាក់ទៅនឹងការទាមទាររបស់ខ្លួនដែលមានទំនាក់ ទំនងជាមួយកូនបំណុលឡើយ។ ប្រសិនបើម្ចាស់បំណុលមិនបានទាមទារសិទ្ធិលើបំណុលរបស់ ខ្លួនក្នុងអំឡុងពេលណាមួយដែលច្បាប់បានកំណត់ នោះមានន័យថា លះបង់សិទ្ធិលើបំណុលជា ប្រយោជន៍កូនបំណុល។

ខ្ញុំសង្ឃឹមថា ចំណងគតិយុត្តិដែលបានបង្កើតឡើងដោយភាគី និងប្រព្រឹត្តទៅដោយភាពរលូន ដោយគោរពតាមច្បាប់កំណត់ និង ដោយឆន្ទៈរបស់ភាគីពិតប្រាកដ ដើម្បីឈានទៅរកទំនាក់ទំនង ប្រកបដោយ

ប្រសិទ្ធភាពទទួលបានផ្លែផ្កា និងជៀសវាងភាពមិនប្រក្រតី កើតឡើង។ ចំពោះពលរដ្ឋទាំងអស់ត្រូវយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន និងសិក្សាយល់ដឹងពីបទដ្ឋានគតិយុត្តិនានា ដែលមានក្នុងសង្គម។

ការយល់ដឹងអំពីច្បាប់ក្នុងគតិយុត្តិរបស់សខ្លួននឹងនាំមកនូវភាពលុបបំបាត់វិវាទនាគ្មានវិវាទ មានការវិវឌ្ឍន៍ខាងសេដ្ឋកិច្ចគ្រួសារ និងសង្គម។

# ឯកសារយោង

## ឯកសារយោង

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣

២.ក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧

៣. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៦

៤. សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០១៣

៥. ក្រឹត្យច្បាប់ លេខ៣៨ ក្រ.ច, ២៨ តុលា ១៩៨៨

៦. ញឹករុទ្ធី, នីតិកាតព្វកិច្ច, ភាគ១,សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៧. រស់ស៊ីសុវណ្ណា, នីតិកាតព្វកិច្ច,ភាគ១, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៨. ជិនវណ្ណារ៉ា, នីតិកាតព្វកិច្ច, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# ឧបសម្ព័ន្ធទី១

## គន្ថីទី ៤
## កាតព្វកិច្ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១
### ប្រភពនៃកាតព្វកិច្ច និង និយមន័យនៃពាក្យផ្សេងៗ

**មាត្រា ៣០៨.–** និយមន័យនៃកាតព្វកិច្ច

១-កាតព្វកិច្ចគឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត ។

២-បុគ្គលដែលមានករណីយកិច្ចហៅថា កូនបំណុល រីឯបុគ្គលដែលទទួលផលប្រយោជន៍ពីករណីយកិច្ចនោះហៅថា ម្ចាស់បំណុល ។

៣-ម្ចាស់បំណុលមានសិទ្ធិត្រូវគ្នាទៅនឹងករណីយកិច្ចរបស់កូនបំណុល ។

**មាត្រា ៣០៩.–** ប្រភពនៃកាតព្វកិច្ច

១-កាតព្វកិច្ចកើតមានឡើងដោយកិច្ចសន្យា ដោយសកម្មភាពឯកតោភាគី ដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង ដោយបញ្ញត្តិនៃច្បាប់ ។

២-កាតព្វកិច្ចដែលកើតឡើងដោយកិច្ចសន្យា និង ដោយសកម្មភាពឯកតោភាគី គឺជាកាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី ។

៣-កាតព្វកិច្ចដែលកើតឡើងដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង ដោយបញ្ញត្តិនៃច្បាប់ គឺជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ។ បញ្ញត្តិពីជំពូកទី ៣ (ការអនុវត្តកិច្ចសន្យា) ដល់ជំពូកទី ៧ (ការរលត់កាតព្វកិច្ច) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកាតព្វកិច្ចដែលកំណត់



## ជំពូកទី ៧
## ការរលត់កាតព្វកិច្ច

**មាត្រា ៤៣៣.–** មូលហេតុនៃការរលត់កាតព្វកិច្ច

កាតព្វកិច្ចត្រូវរលត់ដោយហេតុដូចខាងក្រោមនេះ :

ក-ការសង ការទូទាត់ ការលើកលែង នវកម្ម ឬ ល្បាកុលភាព ដូចបានកំណត់ពីផ្នែកទី ១ (ការសង) ដល់ផ្នែកទី ៥ (ល្បាកុលភាព) នៃជំពូកទី ៧ នេះ ។

ខ-អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដោយគ្មានកំហុសរបស់កូនបំណុល ដូចបានកំណត់ក្នុងជំពូកទី ៥ (ការទទួលបន្ទុកហានិភ័យ) នៃគន្ថីនេះ ។

គ-ការបំពេញល័ក្ខខ័ណ្ឌនៃការរំលាយដូចបានកំណត់ក្នុងផ្នែកទី ៣ (ល័ក្ខខ័ណ្ឌកំណត់ពេល និង អំឡុងពេល) នៃជំពូកទី ១ ឬ ការរំលាយកិច្ចសន្យាដូចបានកំណត់ក្នុងផ្នែកទី ៤ (ការរំលាយកិច្ចសន្យា) នៃជំពូកទី ៤ នៃគន្ថីនេះ ។

ឃ-ការផុតអាជ្ញាយុកាលនៃការរលត់ដូចបានកំណត់ក្នុងជំពូកទី ៨ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល) នៃគន្ថីនេះ ។

ង-ការអនុវត្តសិទ្ធិលុបចោលតាមបញ្ញត្តិនៃផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ជំពូកទី ២ នៃគន្ថីនេះ។

### ផ្នែកទី ១
### ការសង

#### កថាភាគទី ១
#### គោលការណ៍ទូទៅស្តីពីការសង

**មាត្រា ៤៣៤.–** អ្នកសង

១-ការសងអាចធ្វើឡើងដោយកូនបំណុលក៏បាន ដោយតតិយជនក៏បាន ។

២-ក្នុងករណីដែលគោលបំណងនៃកាតព្វកិច្ចមិនអាចសម្រេចដោយការសងរបស់តតិយជនបានទេ តតិយជននោះមិនអាចសងបានឡើយ លើកលែងតែមានការយល់ព្រម



ពីម្ចាស់បំណុល ។

៣-ម្ចាស់បំណុល និង កូនបំណុលអាចព្រមព្រៀងគ្នាមិនទទួលស្គាល់ការសងដោយតតិយជនបាន ។

**មាត្រា ៤៣៥.–** សមត្ថភាពចាត់ចែងរបស់អ្នកសង ជាអាទិ៍

១-ប្រសិនបើអ្នកសងមិនមែនជាម្ចាស់កម្មសិទ្ធិ ឬ មិនមានសមត្ថភាពចាត់ចែងចំពោះវត្ថុដែលជាកម្មវត្ថុនៃការសងទេ ការសងរបស់អ្នកសងនោះមិនមានសុពលភាពឡើយ ។

២-ក្នុងករណីដែលអ្នកសងមិនមែនជាម្ចាស់កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការសងទេ អ្នកសងនោះមិនអាចយកវត្ថុនោះមកវិញបានឡើយ លើកលែងតែមានការសងម្តងទៀតដែលមានសុពលភាព ។ ប៉ុន្តែ អ្នកដែលមានកម្មសិទ្ធិលើវត្ថុនោះ អាចយកវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនពីអ្នកទទួលការសងមកវិញបាន ។

៣-ក្នុងករណីដែលអ្នកសងគ្មានសមត្ថភាពចាត់ចែងកម្មវត្ថុនៃការសងទេ អ្នកសងនោះអាចលុបចោលនូវអំពើសងដែលខ្លួនបានធ្វើ ។ ក្នុងករណីនេះ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការប្រគល់កម្មវត្ថុនៃការសងវិញ ។

**មាត្រា ៤៣៦.–** ការប្រើប្រាស់ ឬ អនុប្បទានរបស់ម្ចាស់បំណុល និង ការទទួលដោយសុចរិត

១-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៤៣៥ (សមត្ថភាពចាត់ចែងរបស់អ្នកសង ជាអាទិ៍) ខាងលើនេះ បើកម្មវត្ថុនៃការសងជាចលនវត្ថុ ហើយម្ចាស់បំណុលបានបរិភោគ ឬ ធ្វើអនុប្បទានដោយសុចរិត នូវវត្ថុដែលបានទទួលពីការសង ការសងនោះត្រូវចាត់ទុកថាមានសុពលភាព ហើយអ្នកសងមិនអាចទាមទារឱ្យប្រគល់កម្មវត្ថុនៃការសងនោះ មកវិញបានទេ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលមានកម្មសិទ្ធិលើកម្មវត្ថុនៃការសង អាចទាមទារនូវសំណងនៃការខូចខាតចំពោះកម្មវត្ថុនៃការសងនោះពីអ្នកទទួលការសងបាន លើកលែងតែអ្នកទទួលការសងនោះបានទទួលកម្មសិទ្ធិលើវត្ថុនៃ



ការសង ដោយស្របទៅតាមបញ្ញត្តិនៃមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ។ ប៉ុន្តែ ម្ចាស់បំណុលដែលបានសងការខូចខាតទៅម្ចាស់កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការសងនោះ អាចទាមទារឱ្យកូនបំណុលសងជាប្រាក់នូវតម្លៃដែលខ្លួនបានសងនោះវិញបាន ។

**មាត្រា ៤៣៧.–** សិទ្ធិទទួលការសង

១-ការសងនឹងមានសុពលភាព លុះត្រាតែធ្វើចំពោះម្ចាស់បំណុល ឬ អ្នកដទៃទៀតដែលមានសិទ្ធិទទួលការសង ។

២-បើកូនបំណុលបានសងដល់អ្នកដែលគ្មានសិទ្ធិទទួលការសង កូនបំណុលនោះត្រូវសងទៅម្ចាស់បំណុលជាថ្មីម្តងទៀត តាមការទាមទារពីម្ចាស់បំណុលនោះ ។ ក្នុងករណីនេះ អ្នកសងអាចទាមទារឱ្យអ្នកគ្មានសិទ្ធិដែលបានទទួលការសងនោះ ប្រគល់កម្មវត្ថុនៃការសងមកវិញបាន ។

**មាត្រា ៤៣៨.–** ការកម្រិតនូវសិទ្ធិទទួលការសងដោយការរឹបអូស

១-ក្នុងករណីដែលសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលត្រូវបានរឹបអូស ដោយដីកាសម្រេចរឹបអូសរបស់តុលាការ ម្ចាស់បំណុលនោះមិនមានសិទ្ធិទទួលការសងពីកូនបំណុលរបស់ខ្លួន ហើយកូនបំណុលនោះមិនអាចសងទៅម្ចាស់បំណុលនោះបានឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤៣៧ (សិទ្ធិទទួលការសង) ខាងលើនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនបំណុលដែលត្រូវបានហាមការសង បានសងទៅម្ចាស់បំណុលរបស់ខ្លួន ។

**មាត្រា ៤៣៩.–** ការសងដែលបានធ្វើចំពោះឧបភោគីនៃសិទ្ធិលើបំណុល

១-ចំពោះការសងដែលបានធ្វើទៅអ្នកដែលមិនមែនជាម្ចាស់បំណុល តែមើលទៅហាក់ដូចជាម្ចាស់បំណុល ក្នុងករណីដែលអ្នកសងបានជឿជាក់ថា ភាគីដែលខ្លួនបានសងនោះជាម្ចាស់បំណុលពិតប្រាកដ ការសងនោះត្រូវចាត់ទុកថាជាការសងមានសុពលភាព លើកលែងតែការជឿជាក់នោះកើតឡើងដោយសារកំហុសធ្ងន់ធ្ងរ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ម្ចាស់បំណុលពិតប្រាកដមិនអាចទាមទារឱ្យកូនបំណុលសងម្តងទៀតបានទេ ។ ប៉ុន្តែ ម្ចាស់បំណុលពិតប្រាកដអាចទាមទារឱ្យអ្នកដែលបានទទួលការសងពីកូនបំណុល ប្រគល់នូវវត្ថុដែលបានសងនោះឱ្យខ្លួនវិញបាន ។

**មាត្រា ៤៤០.-** វិធីសង

កូនបំណុលត្រូវសងតាមខ្លឹមសារនៃកាតព្វកិច្ច និង តាមគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

**មាត្រា ៤៤១.-** ការសងមួយភាគ

ម្ចាស់បំណុលមិនមានករណីយកិច្ចទទួលការសងមួយភាគនៃកាតព្វកិច្ចទេ ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលបានទទួល ដោយដឹងថាជាការសងមួយភាគ ការសងនោះមានសុពលភាពត្រឹមទំហំដែលបានសង ។

**មាត្រា ៤៤២.-** ការសងដោយយកវត្ថុជំនួស

១-ក្នុងករណីដែលកូនបំណុលផ្តល់តាវកាលិកផ្សេងពីតាវកាលិកដែលជាបន្ទុកដើមរបស់ខ្លួនជាជំនួសវិញ ដោយទទួលការយល់ព្រមពីម្ចាស់បំណុល តាវកាលិកនោះមានអានុភាពដូចគ្នានឹងការសងដែរ ។

២-ម្ចាស់បំណុល និង កូនបំណុលអាចធ្វើការព្រមព្រៀងគ្នាលើតាវកាលិកផ្សេងជំនួសតាវកាលិកដើមបាន ។ ក្នុងករណីនេះ កូនបំណុលអាចសងដោយជ្រើសរើសតាវកាលិកដើម ឬ តាវកាលិកដោយយកវត្ថុផ្សេងជាជំនួសបាន លើកលែងតែករណីម្ចាស់បំណុលមានសិទ្ធិជ្រើសរើស ។

**មាត្រា ៤៤៣.-** ពេលនៃការសង ការសងមុនពេលកំណត់

១-កូនបំណុលត្រូវសងនៅពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចដែលមានចែងនៅក្នុងចំណុចនីមួយៗនៃមាត្រា ៣៩១ (ការយឺតយ៉ាវក្នុងការអនុវត្ត) នៃក្រមនេះ ។

២-កូនបំណុលអាចសងមុនពេលកំណត់បាន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌ



ទី ២ មាត្រា ៣៣០ (ប្រយោជន៍នៃការកំណត់ពេល) នៃក្រមនេះ ។

**មាត្រា ៤៤៤.-** ម៉ោងសង

កូនបំណុលត្រូវសងនៅក្នុងម៉ោងធ្វើការធម្មតា តាមទំនៀមទម្លាប់ និង គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

**មាត្រា ៤៤៥.-** ទីកន្លែងដែលត្រូវសង

ប្រសិនបើគ្មានការព្រមព្រៀងគ្នាផ្សេងអំពីទីកន្លែងដែលត្រូវសងទេ ការប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ត្រូវធ្វើឡើង នៅទីកន្លែងដែលវត្ថុនោះបានស្ថិតនៅនាពេលសិទ្ធិលើបំណុលកើតឡើង ។ ចំពោះកាតព្វកិច្ចក្រៅពីនេះ ការសងត្រូវធ្វើឡើង នៅលំនៅឋានបច្ចុប្បន្នរបស់ម្ចាស់បំណុល ។

**មាត្រា ៤៤៦.-** សោហ៊ុយនៃការសង

ប្រសិនបើគ្មានការព្រមព្រៀងគ្នាផ្សេងអំពីសោហ៊ុយនៃការសងទេ កូនបំណុលត្រូវទទួលបន្ទុកនូវសោហ៊ុយនោះ ។ ប៉ុន្តែ ប្រសិនបើសោហ៊ុយនៃការសងកើនឡើងដោយសារការផ្លាស់ប្តូរលំនៅឋាន ឬ អំពើផ្សេងរបស់ម្ចាស់បំណុល ម្ចាស់បំណុលត្រូវទទួលបន្ទុកនូវចំនួនកំណើននៃសោហ៊ុយនោះ ។

**មាត្រា ៤៤៧.-** ការចេញលិខិតទទួល

អ្នកសងអាចទាមទារឱ្យអ្នកទទួលការសងចេញលិខិតបញ្ជាក់នូវការទទួលការសងនោះបាន ។

**មាត្រា ៤៤៨.-** ការប្រគល់មកវិញនូវលិខិតបញ្ជាក់សិទ្ធិលើបំណុល

ក្នុងករណីដែលមានលិខិតបញ្ជាក់សិទ្ធិលើបំណុល អ្នកសងអាចទាមទារឱ្យប្រគល់លិខិតនោះមកវិញបាន នៅពេលដែលខ្លួនបានសងចំពោះកាតព្វកិច្ចចប់សព្វគ្រប់ហើយ ។



## កថាភាគទី ២
## ការកាត់បំណុល

**មាត្រា ៤៤៩.-** ការកាត់បំណុលដោយការជ្រើសរើស

១-ក្នុងករណីដែលកូនបំណុលត្រូវទទួលបន្ទុកនូវកាតព្វកិច្ចច្រើនដែលមានគោលបំណងប្រភេទដូចគ្នា ចំពោះម្ចាស់បំណុលតែម្នាក់ ប្រសិនបើតាវកាលិកដែលត្រូវបានផ្តល់ជាការសង នៅមិនទាន់គ្រប់គ្រាន់ដើម្បីឱ្យកាតព្វកិច្ចទាំងអស់រលត់នៅឡើយទេ អ្នកសងអាចជ្រើសរើសយកកាតព្វកិច្ចណាដែលត្រូវកាត់ដោយការសងនោះ នៅពេលដែលខ្លួនផ្តល់តាវកាលិកបាន ។

២-ប្រសិនបើអ្នកសងមិនបានជ្រើសរើសដូចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះទេ អ្នកទទួលការសងអាចជ្រើសរើសយកកាតព្វកិច្ចណាដែលត្រូវកាត់ដោយការសងនោះ នៅពេលដែលខ្លួនទទួលការសងបាន ។ ប៉ុន្តែ ប្រសិនបើអ្នកសងបានតវ៉ានឹងការកាត់នោះភ្លាមៗ ការកាត់បំណុលត្រូវធ្វើតាមច្បាប់កំណត់ ។

៣-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ការកាត់បំណុលត្រូវធ្វើឡើង ដោយការជូនដំណឹងទៅភាគីម្ខាងទៀត ។

**មាត្រា ៤៥០.-** ការកាត់បំណុលតាមច្បាប់កំណត់

ក្នុងករណីដែលអ្នកសង និង អ្នកទទួលការសងមិនបានធ្វើការជ្រើសរើសដើម្បីកាត់បំណុលនោះទេ ការកាត់បំណុលនោះ ត្រូវធ្វើឡើងតាមបញ្ញត្តិដូចខាងក្រោមនេះ :

ក-ក្នុងចំណោមកាតព្វកិច្ចទាំងអស់ ប្រសិនបើមានកាតព្វកិច្ចណាដែលពេលកំណត់ត្រូវសងបានមកដល់ និង កាតព្វកិច្ចណាដែលពេលកំណត់ត្រូវសងមិនទាន់មកដល់ ត្រូវកាត់កាតព្វកិច្ចដែលដល់ពេលកំណត់ជាមុនសិន ។

ខ-ប្រសិនបើពេលកំណត់ដែលត្រូវសងចំពោះកាតព្វកិច្ចទាំងអស់បានមកដល់ហើយ ឬ មិនទាន់មកដល់នៅឡើយ ត្រូវកាត់កាតព្វកិច្ចដែលមានប្រយោជន៍ក្នុងការសងច្រើនជាងគេ សម្រាប់កូនបំណុល ។



គ-ប្រសិនបើផលប្រយោជន៍ក្នុងការសងមានភាពស្មើគ្នាចំពោះកូនបំណុល ត្រូវកាត់កាតព្វកិច្ចដែលពេលកំណត់ត្រូវសងបានមកដល់មុនគេ ឬ នឹងមកដល់មុនគេ ។

ឃ-ប្រសិនបើកាតព្វកិច្ចទាំងអស់ មានប្រយោជន៍ក្នុងការសងដូចគ្នាចំពោះកូនបំណុល និង មានពេលកំណត់ដែលត្រូវសងដូចគ្នា ត្រូវកាត់ដោយគិតជាសមាមាត្រតាមចំនួនទឹកប្រាក់នៃកាតព្វកិច្ចនីមួយៗ ។

**មាត្រា ៤៥១.-** លំដាប់នៃការកាត់បំណុល : សោហ៊ុយ ការប្រាក់ និង ប្រាក់ដើម

ក្នុងករណីដែលកូនបំណុលមានករណីយកិច្ចបង់សោហ៊ុយ ការប្រាក់ ព្រមទាំងប្រាក់ដើមចំពោះកាតព្វកិច្ចមួយ ឬ ច្រើន ហើយអ្នកសងផ្តល់តាវកាលិកមិនគ្រប់គ្រាន់ដើម្បីរំលត់កាតព្វកិច្ចទាំងអស់ទេ ត្រូវកាត់តាមលំដាប់ : សោហ៊ុយ ការប្រាក់ និង ប្រាក់ដើមជាចុងក្រោយ ។ ប៉ុន្តែ ប្រសិនបើមានកិច្ចសន្យាផ្សេងពីនេះរវាងម្ចាស់បំណុល និង កូនបំណុល ត្រូវអនុវត្តតាមកិច្ចសន្យានោះ ។

**មាត្រា ៤៥២.-** ការកាត់បំណុលក្នុងករណីដែលមានម្ចាស់បំណុលច្រើននាក់

បញ្ញត្តិនៃមាត្រា ៤៤៩ (ការកាត់បំណុលដោយការជ្រើសរើស) មាត្រា ៤៥០ (ការកាត់បំណុលតាមច្បាប់កំណត់) និង មាត្រា ៤៥១ (លំដាប់នៃការកាត់បំណុល : សោហ៊ុយ ការប្រាក់ និង ប្រាក់ដើម) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនបំណុលទទួលបន្ទុកកាតព្វកិច្ចច្រើនចំពោះម្ចាស់បំណុលច្រើននាក់ ហើយមិនច្បាស់លាស់អំពីកាតព្វកិច្ចណាដែលត្រូវកាត់ដោយការសងទេ ។

## កថាភាគទី ៣
## សំណើផ្តល់ការសង និង ការតម្កល់

**មាត្រា ៤៥៣.-** អត្ថន័យ និង អានុភាពជាមូលដ្ឋាននៃសំណើផ្តល់ការសង

១-សំណើផ្តល់ការសង សំដៅទៅលើការដែលកូនបំណុលបានរៀបចំចប់សព្វគ្រប់នូវតាវកាលិកសម្រាប់សង និង ទាមទារឱ្យម្ចាស់បំណុលទទួលការសងនោះ ។

២-ក្នុងករណីដែលកូនបំណុលធ្វើសំណើផ្ដល់ការសង តែម្ចាស់បំណុលមិនធ្វើអំពើចាំបាច់ដើម្បីទទួលការសងទេ កូនបំណុលមិនទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនេះឡើយ ។

៣-ក្នុងករណីដែលកូនបំណុលមានកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ និង ត្រូវបង់ទាំងការប្រាក់ ហើយបានស្នើផ្ដល់ការសង តែម្ចាស់បំណុលមិនទទួលការសងនោះទេ កូនបំណុលមិនចាំបាច់បង់ការប្រាក់សម្រាប់ពេលក្រោយពីពេលនោះទៀតឡើយ ។

**មាត្រា ៤៥៤.–** វិធីស្នើផ្ដល់ការសង

សំណើផ្ដល់ការសងត្រូវធ្វើឡើង ដោយស្នើផ្ដល់តាវកាលិកជាក់ស្ដែងតាមខ្លឹមសារនៃកាតព្វកិច្ច ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលបដិសេធជាមុនក្នុងការទទួលយកសំណើផ្ដល់ការសង ឬ ក្នុងករណីដែលម្ចាស់បំណុលចាំបាច់ត្រូវធ្វើអំពើសម្រាប់ការអនុវត្តកាតព្វកិច្ចរបស់កូនបំណុល នោះកូនបំណុលគ្រាន់តែជូនដំណឹងអំពីការបញ្ចប់នូវការរៀបចំការសង និង ដាស់តឿនឱ្យម្ចាស់បំណុលទទួលការសងនោះតែប៉ុណ្ណោះ ជាការគ្រប់គ្រាន់ហើយ ។

**មាត្រា ៤៥៥.–** អានុភាពនៃសំណើផ្ដល់ការសង

ក្នុងករណីដែលម្ចាស់បំណុលមិនទទួលនូវសំណើផ្ដល់ការសងទេ ក្រៅពីអានុភាពដែលបានកំណត់ក្នុងមាត្រា ៤៥៣ (អត្ថន័យ និង អានុភាពជាមូលដ្ឋាននៃសំណើផ្ដល់ការសង) នៃក្រមនេះ ត្រូវមានអានុភាពផ្សេងទៀតដូចតទៅ :

ក-ក្នុងករណីដែលកូនបំណុលទទួលបន្ទុកហានិភ័យនៅក្នុងកិច្ចសន្យាអញ្ញមញ្ញ ហានិភ័យនេះត្រូវផ្ទេរទៅម្ចាស់បំណុល ។

ខ-ក្នុងកិច្ចសន្យាអញ្ញមញ្ញ សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នាដែលម្ចាស់បំណុលមាន ត្រូវបាត់បង់ ។

គ-កូនបំណុលអាចរួចផុតពីកាតព្វកិច្ចបានដោយការតម្កល់ ។



**មាត្រា ៤៥៦.–** ការយឺតយ៉ាវក្នុងការទទួល

១-ក្នុងករណីដែលម្ចាស់បំណុលប្រកែកជាមុននូវការទទួលការសង ឬ ករណីដែលកូនបំណុលបានស្នើផ្ដល់ការសង តែម្ចាស់បំណុលមិនទទួលការសងនោះដោយមានកំហុស កូនបំណុលអាចទាមទារពីម្ចាស់បំណុលនូវសំណងនៃការខូចខាត ដែលបណ្ដាលមកពីការមិនទទួលនោះបាន ។

២-ក្នុងករណីដែលការមិនទទួលសំណើផ្ដល់ការសងរបស់ម្ចាស់បំណុល គឺជាការបំពានករណីយកិច្ចដ៏ធ្ងន់ធ្ងរពីម្ចាស់បំណុល នោះកូនបំណុលអាចរំលាយកិច្ចសន្យាបាន ។

**មាត្រា ៤៥៧.–** ការតម្កល់

១-កូនបំណុលអាចតម្កល់នូវកម្មវត្ថុនៃកាតព្វកិច្ចនៅកន្លែងតម្កល់ដើម្បីឱ្យរួចពីកាតព្វកិច្ចបាន ក្នុងករណីណាមួយដូចខាងក្រោមនេះ :

ក-អ្នកសងបានស្នើផ្ដល់ការសង តែម្ចាស់បំណុលបដិសេធមិនទទួល ឬ មិនអាចទទួលការសងនោះបាន ។

ខ-កូនបំណុលមិនអាចដឹងថា អ្នកណាជាម្ចាស់បំណុល ដោយមិនមែនជាកំហុសរបស់ខ្លួន ។

២-នៅពេលដែលម្ចាស់បំណុលមិនព្រមទទួលការតម្កល់ ឬ សាលក្រម ឬ សាលដីកាដែលប្រកាសថាការតម្កល់នោះ មានសុពលភាព មិនទាន់ចូលជាស្ថាពរទេ អ្នកសងអាចយកវត្ថុតម្កល់មកវិញបាន ។ ក្នុងករណីនេះ អ្នកសងត្រូវបានចាត់ទុកថា មិនបានធ្វើការតម្កល់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសិទ្ធិលើការបញ្ចាំ ឬ សិទ្ធិលើហ៊ីប៉ូតែក ត្រូវបានរលត់ដោយការតម្កល់នោះ ។

៣-សេចក្ដីលម្អិតស្ដីពីការតម្កល់ ត្រូវកំណត់ក្នុងច្បាប់ស្ដីពីការតម្កល់ ។

**មាត្រា ៤៥៨.–** សិទ្ធិលក់ដោយខ្លួនឯង

ប្រសិនបើវត្ថុដែលជាកម្មវត្ថុនៃការសងមិនសមស្របនឹងការតម្កល់ ឬ មានការបារម្ភខ្លាចមានការបាត់បង់ ឬ ខូចខាត តាមការអនុញ្ញាតពីតុលាការ អ្នកសងអាចលក់វត្ថុនោះដោយដេញថ្លៃ ហើយតម្កល់នូវប្រាក់លក់នោះបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្ត



ដែរ ចំពោះករណីដែលការរក្សាទុកវត្ថុនោះតម្រូវឱ្យចេញសោហ៊ុយច្រើនហួសហេតុ ។

## កថាភាគទី ៤
## ឧបាទេសកម្មដោយការសង

**មាត្រា ៤៥៩.–** ឧបាទេសកម្មដោយការសង

១-អ្នកដែលបានរួចផុតពីការទទួលខុសត្រូវ ដោយបានសង ឬ បានចេញចំណាយរបស់ខ្លួនផ្សេងទៀត ហើយបានទទួលសិទ្ធិទាមទារសំណងចំពោះកូនបំណុល អាចស្នងម្ចាស់បំណុលដោយឧបាទេសកម្មបាន ចំពោះសិទ្ធិលើបំណុល និង សិទ្ធិផ្សេងទៀតដែលម្ចាស់បំណុលនោះធ្លាប់មាន ។

២-បញ្ញត្តិនៃមាត្រា ៥០៣ (លក្ខខណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-ការជូនដំណឹងដែលបានកំណត់នៅក្នុងមាត្រា ៩១៣ (លក្ខខណ្ឌនៃការទាមទារសំណង) និង មាត្រា ៩៣៣ (ការជូនដំណឹងដែលជាលក្ខខណ្ឌដើម្បីទាមទារសំណង) នៃក្រមនេះ អាចយកជាជំនួសនឹងការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះបាន ។ ប៉ុន្តែ ក្នុងករណីដែលចាំបាច់មានលិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្ថាពរ តាមបញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា ដោយយោងទៅតាមកថាខណ្ឌទី ២ ខាងលើនេះ ការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌនេះ ក៏ត្រូវធ្វើដោយលិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្ថាពរដែរ ។

**មាត្រា ៤៦០.–** ទំហំនៃឧបាទេសកម្ម និង ទំនាក់ទំនងគ្នាទៅវិញទៅមករវាងឧបាទេសិក

១-ឧបាទេសិកនៃម្ចាស់បំណុលតាមបញ្ញត្តិនៃមាត្រា ៤៥៩ (ឧបាទេសកម្មដោយការសង) ខាងលើនេះ អាចប្រើសិទ្ធិទាំងឡាយដែលជាអានុភាព និង ប្រាតិភោគនៃសិទ្ធិលើបំណុលដែលម្ចាស់បំណុលធ្លាប់មាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិរបស់ម្ចាស់បំណុលដែលបានមកពីឋានៈក្នុងកិច្ចសន្យា ។



២-ឧបាទេសិកត្រូវធ្វើតាមបញ្ញត្តិនៃចំណុចដូចតទៅ :

ក-ប្រសិនបើអ្នកធានាដោយបុគ្គល ឬ អ្នកធានាដោយវត្ថុ មិនបានធ្វើការចុះបន្ថែមជាមុន នូវឧបាទេសកម្ម ក្នុងបញ្ជីចុះឯកសិទ្ធិ សិទ្ធិបញ្ចាំអចលនវត្ថុ ឬ ហ៊ីប៉ូតែកដែលយកទ្រព្យរបស់កូនបំណុលមកជាកម្មវត្ថុទេ អ្នកធានា ឬ អ្នកធានាដោយវត្ថុនោះ មិនត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ចំពោះតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុដែលជាកម្មវត្ថុនៃឯកសិទ្ធិ ឬ សិទ្ធិបញ្ចាំអចលនវត្ថុ ឬ ហ៊ីប៉ូតែកនោះទេ ។

ខ-តតិយជនដែលបានធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគពីកូនបំណុល មិនត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ចំពោះអ្នកធានាទេ ។

គ-តតិយជនម្នាក់ក្នុងចំណោមតតិយជនដែលបានធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគពីកូនបំណុល ត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ចំពោះតតិយជនផ្សេងទៀតដែលបានធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគពីកូនបំណុល តាមសមាមាត្រនៃតម្លៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគនីមួយៗ ។

ឃ-បញ្ញត្តិនៃចំណុច គ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទំនាក់ទំនងរវាងអ្នកធានាដោយវត្ថុ ដែលបានកំណត់នៅក្នុងមាត្រា ៧៦៦ (និយមន័យនៃអ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម) នៃក្រមនេះ ។

ង-រវាងអ្នកធានាដោយបុគ្គល និង អ្នកធានាដោយវត្ថុ ត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម ដោយគិតទៅតាមចំនួនអ្នកទាំងនោះ ។ ប៉ុន្តែ ប្រសិនបើអ្នកធានាដោយវត្ថុមានច្រើននាក់ ចំពោះប្រាក់សំណល់ ក្រៅពីភាគដែលជាបន្ទុកអ្នកធានា ត្រូវស្នងម្ចាស់បំណុលដោយឧបាទេសកម្ម តាមសមាមាត្រនៃតម្លៃវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគនីមួយៗ ។

**មាត្រា ៤៦១.–** ឧបាទេសកម្មមួយភាគ

១-ក្នុងករណីដែលមានការសងតែមួយភាគនៃសិទ្ធិលើបំណុលដោយឧបាទេសិក ឧបាទេសិកនោះអនុវត្តសិទ្ធិព្រមគ្នានឹងម្ចាស់បំណុល ទៅតាមចំនួនប្រាក់ដែលខ្លួនបានសង ។ ប៉ុន្តែ ពេលដែលឧបាទេសិកអនុវត្តសិទ្ធិរបស់ខ្លួន អ្នកនោះត្រូវទទួលការយល់ព្រមពីម្ចាស់

បំណុល ឬ បើម្ចាស់បំណុលទាមទារ អ្នកនោះត្រូវធ្វើអនុប្បទាននូវសិទ្ធិ ឬ អាទិភាពរបស់ខ្លួន ទៅឱ្យម្ចាស់បំណុល ត្រឹមកម្រិតនៃប្រាក់សំណល់នៃសិទ្ធិលើបំណុលនោះ ដោយមិនយកថ្លៃ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានតែម្ចាស់បំណុលទេ ដែលអាចរំលាយកិច្ចសន្យាបាន ដោយយកមូលហេតុថាមិនបានអនុវត្តកាតព្វកិច្ច ។ ប៉ុន្តែ ក្នុងករណីនេះ ម្ចាស់បំណុលត្រូវសងនូវប្រាក់ដែលឧបាទេសិកបានសងព្រមទាំងការប្រាក់ ទៅឧបាទេសិកនោះវិញ ។

**មាត្រា ៤៦២.-** ការសងជំនួស និង លិខិតបញ្ជាក់សិទ្ធិលើបំណុល ឬ វត្ថុប្រាតិភោគ

១-ម្ចាស់បំណុលដែលបានទទួលការសងទាំងអស់ពីឧបាទេសិក ត្រូវប្រគល់នូវលិខិតដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះ និង វត្ថុប្រាតិភោគដែលខ្លួនកាន់កាប់នោះ ទៅឱ្យឧបាទេសិក ។

២-ក្នុងករណីដែលមានការសងតែមួយភាគនៃសិទ្ធិលើបំណុលដោយឧបាទេសិក ម្ចាស់បំណុលត្រូវធ្វើកំណត់បន្ថែមអំពីឧបាទេសកម្មនេះ ក្នុងលិខិតបញ្ជាក់សិទ្ធិលើបំណុល ហើយឱ្យឧបាទេសិកធ្វើការត្រួតពិនិត្យនូវការរក្សាវត្ថុប្រាតិភោគដែលម្ចាស់បំណុលនោះកាន់កាប់ផងដែរ ។

**មាត្រា ៤៦៣.-** ករណីយកិច្ចរក្សាប្រាតិភោគសម្រាប់ឧបាទេសិក

ក្នុងករណីមានបុគ្គលដែលអាចធ្វើឧបាទេសកម្មតាមបញ្ញត្តិនៃមាត្រា ៤៥៩ (ឧបាទេសកម្មដោយការសង) នៃក្រមនេះ ប្រសិនបើម្ចាស់បំណុលបានធ្វើឱ្យបាត់បង់ ឬ បន្ថយនូវប្រាតិភោគ ដោយចេតនា ឬ ដោយមានកំហុស បុគ្គលដែលអាចស្នងម្ចាស់បំណុលដោយឧបាទេសកម្មនោះ អាចរួចផុតពីការទទួលខុសត្រូវ ឬ ទាមទារសំណងនៃការខូចខាតបាន ក្នុងកម្រិតដែលខ្លួនមិនអាចទទួលសំណង ដោយសារការបាត់បង់ ឬ ការបន្ថយនោះ ។



## ផ្នែកទី ២
## ការទូទាត់

**មាត្រា ៤៦៤.-** ល័ក្ខខ័ណ្ឌនៃការទូទាត់ដែលច្បាប់បានកំណត់ និង កិច្ចសន្យាទូទាត់

១-ក្នុងករណីដែលបុគ្គលពីរនាក់ទទួលបន្ទុកនូវកាតព្វកិច្ចដែលមានគោលបំណងប្រភេទដូចគ្នាចំពោះគ្នាទៅវិញទៅមក ប្រសិនបើកាតព្វកិច្ចទាំងពីរត្រូវដល់ពេលកំណត់សងហើយ ភាគីម្ខាងអាចរំលត់កាតព្វកិច្ចទៅវិញទៅមក ដោយយកចំនួនប្រាក់ស្មើគ្នា ដោយបង្ហាញឆន្ទៈឯកតោភាគី ។

២-គូភាគីអាចធ្វើកិច្ចសន្យាទូទាត់ដែលរំលត់កាតព្វកិច្ចទៅវិញទៅមកបាន ទោះបីជាកាតព្វកិច្ចទាំងពីរនោះគ្មានគោលបំណងប្រភេទដូចគ្នាទៅវិញទៅមកក៏ដោយ ។ ប៉ុន្តែ គូភាគីមិនអាចធ្វើឱ្យខូចផលប្រយោជន៍របស់តតិយជនបានឡើយ ។

**មាត្រា ៤៦៥.-** វិធីទូទាត់

១-ការទូទាត់ត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈទូទាត់ ពីភាគីម្ខាង ទៅភាគីម្ខាងទៀត ។

២-ការបង្ហាញឆន្ទៈទូទាត់ អាចដាក់ល័ក្ខខ័ណ្ឌបង្អង់បាន តែមិនអាចដាក់ល័ក្ខខ័ណ្ឌរំលាយ ឬ កំណត់ពេលបានឡើយ ។

**មាត្រា ៤៦៦.-** ពេលដែលបង្កើតអានុភាពនៃការទូទាត់

ក្នុងករណីដែលល័ក្ខខ័ណ្ឌនៃការទូទាត់ត្រូវបានបំពេញ ហើយនៅពេលឆន្ទៈទូទាត់ត្រូវបានបង្ហាញ អានុភាពដែលរំលត់កាតព្វកិច្ចដោយការទូទាត់ ត្រូវកើតឡើងដោយមានប្រតិសកម្ម តាំងពីពេលដែលកាតព្វកិច្ចទាំងពីរនោះសមស្របទៅនឹងការទូទាត់ ។

**មាត្រា ៤៦៧.-** ការកម្រិតចំពោះការទូទាត់

១-ក្នុងករណីដែលលក្ខណៈនៃកាតព្វកិច្ចណាមួយ ឬ ទាំងពីរ មិនអនុញ្ញាតឱ្យធ្វើការទូទាត់ទេ គូភាគីមិនអាចទូទាត់បានទេ ។



២-ក្នុងករណីដែលភាគីទាំងសងខាងធ្វើការសន្យាពិសេសមិនធ្វើការទូទាត់ កូនបំណុលនីមួយៗមិនអាចទូទាត់បានទេ ។ ប៉ុន្តែ ការសន្យាពិសេសមិនធ្វើការទូទាត់នេះ មិនអាចអះអាងចំពោះតតិយជនសុចរិតបានឡើយ ។

**មាត្រា ៤៦៨.-** ការទូទាត់ដោយយកសិទ្ធិលើបំណុលដែលភ្ជាប់នឹងសិទ្ធិតវ៉ា

១-បើសិទ្ធិលើបំណុលរបស់ភាគីដែលបង្ហាញឆន្ទៈទូទាត់ ភ្ជាប់នឹងសិទ្ធិតវ៉ារបស់ភាគីម្ខាងទៀត ភាគីនោះមិនអាចទូទាត់បានទេ ។

២-ប្រសិនបើសិទ្ធិលើបំណុលដែលផុតអាជ្ញាយុកាល ឬ ផុតអំឡុងពេលដើម្បីអនុវត្តសិទ្ធិ ធ្លាប់នៅសមស្របទៅនឹងការទូទាត់ជាមួយនឹងសិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀត នៅមុនពេលផុតអាជ្ញាយុកាល ឬ អំឡុងពេលនោះ ម្ចាស់បំណុលនោះ អាចទូទាត់បាន ។

**មាត្រា ៤៦៩.-** ការទូទាត់ជាមួយនឹងសិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀតដែលកើតឡើងដោយអំពើអនីត្យានុកូល

កូនបំណុលដែលទទួលបន្ទុកនូវកាតព្វកិច្ចដែលកើតឡើងដោយអំពើអនីត្យានុកូលចំពោះភាគីម្ខាងទៀត កូនបំណុលនោះ មិនអាចអះអាងនូវការរលត់កាតព្វកិច្ចនេះដោយការទូទាត់ឡើយ ។

**មាត្រា ៤៧០.-** សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស

ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានហាមឃាត់មិនឱ្យរឹបអូស កូនបំណុលមិនអាចអះអាងនូវការរលត់សិទ្ធិលើបំណុលនោះដោយការទូទាត់ឡើយ ។

**មាត្រា ៤៧១.-** សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស

១-ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវតតិយជនរឹបអូស កូនបំណុលអាចទូទាត់កាតព្វកិច្ចរបស់ខ្លួន ដោយយកសិទ្ធិលើបំណុលចំពោះភាគីម្ខាងទៀតដែលខ្លួនបានទទួលមុនពេលតតិយជនរឹបអូស នៅពេលដែលសិទ្ធិលើបំណុលនោះដល់កំណត់សង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលពេលកំណត់សងនៃសិទ្ធិលើបំណុលរបស់កូនបំណុលដែលអះអាងនូវការទូទាត់ចំពោះភាគីម្ខាងទៀត ត្រូវដល់ក្រោយ



ពេលកំណត់សងនៃសិទ្ធិលើបំណុលរបស់ភាគីម្ខាងទៀតនោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគូភាគីធ្វើការសន្យាពិសេសថា អាចទូទាត់គ្នានូវកាតព្វកិច្ចរៀងៗខ្លួនបានដោយមិនគិតអំពីពេលកំណត់មុន ឬ ក្រោយ ។

**មាត្រា ៤៧២.-** ការកាត់បំណុលដោយការទូទាត់

ក្នុងករណីដែលភាគីម្ខាង ឬ ទាំងសងខាងមានកាតព្វកិច្ចច្រើនដែលអាចទូទាត់បាន អ្នកសុំទូទាត់អាចជ្រើសរើសកាតព្វកិច្ចណាមួយរបស់ខ្លួន និង កាតព្វកិច្ចណាមួយរបស់ភាគីម្ខាងទៀតដើម្បីរំលត់ដោយការទូទាត់នោះបាន ។ បញ្ញត្តិស្ដីពីការកាត់បំណុលដោយការសង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទូទាត់ដែលគ្មានការជ្រើសរើស ដូចកំណត់ក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះ ។

## ផ្នែកទី ៣
## ការលើកលែង

**មាត្រា ៤៧៣.-** ការលើកលែងកាតព្វកិច្ច

ក្នុងករណីដែលម្ចាស់បំណុលបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចចំពោះកូនបំណុល កាតព្វកិច្ចនោះត្រូវរលត់ ។

**មាត្រា ៤៧៤.-** ការលើកលែងតែមួយផ្នែក

ម្ចាស់បំណុលអាចលើកលែងកាតព្វកិច្ចតែមួយផ្នែកបាន ។

**មាត្រា ៤៧៥.-** ករណីដែលកម្រិតការលើកលែង

ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានរឹបអូសដោយតតិយជន ឬ សិទ្ធិចាត់ចែងរបស់ម្ចាស់បំណុលត្រូវបានកម្រិត ដោយមូលហេតុផ្សេង ម្ចាស់បំណុលមិនអាចលើកលែងកាតព្វកិច្ចបានឡើយ ។

## ផ្នែកទី ៤
## នវកម្ម

**មាត្រា ៤៧៦.-** និយមន័យនៃនវកម្ម

១-នវកម្មសំដៅទៅលើកិច្ចសន្យារវាងម្ចាស់បំណុល និង កូនបំណុលដែលរំលត់កាតព្វកិច្ចដើម និង បង្កើតកាតព្វកិច្ចថ្មី ជំនួសកាតព្វកិច្ចដើមនោះ ។

២-នៅពេលកិច្ចសន្យានវកម្មដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បង្កើតអានុភាព នោះកាតព្វកិច្ចដើមត្រូវរលត់ ។

**មាត្រា ៤៧៧.-** ការមិនរលត់កាតព្វកិច្ចដើម

ប្រសិនបើកាតព្វកិច្ចថ្មីដែលត្រូវបានបង្កើតឡើងដោយនវកម្ម មិនបានបង្កើតអានុភាព ដោយសារមូលហេតុដែលកូនបំណុលនៃកាតព្វកិច្ចចាស់មិនអាចព្យាករបាន ឬ ប្រសិនបើកាតព្វកិច្ចថ្មីនោះជាអលទ្ធភាពក្នុងការអនុវត្តតាំងពីដើម នោះកាតព្វកិច្ចដើមមិនត្រូវរលត់ឡើយ ។

**មាត្រា ៤៧៨.-** ការផ្ទេរប្រាតិភោគ

១-សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក ឬ ប្រាតិភោគផ្សេងទៀតដែលបានបង្កើតឡើងដើម្បីធានាកាតព្វកិច្ចដើម អាចផ្ទេរដើម្បីធានាកាតព្វកិច្ចថ្មី ក្នុងទំហំនៃកាតព្វកិច្ចដើម ដោយការព្រមព្រៀងគ្នារបស់គូភាគីនៃកិច្ចសន្យានវកម្មបាន ។ ប៉ុន្តែ ប្រាតិភោគដែលត្រូវបានដាក់ដោយតតិយជន មិនត្រូវផ្ទេរឡើយ លើកលែងតែមានការយល់ព្រមពីតតិយជននោះ ។

២-ក្នុងឧបសន្យាឌ្បីបរិភោគវត្ថុ ត្រូវសន្មតថា មានការព្រមព្រៀងដែលបានកំណត់នៅវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ។



## ផ្នែកទី ៥
## ព្យាកុលភាព

**មាត្រា ៤៧៩.-** ព្យាកុលភាពរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ច

១-ក្នុងករណីដែលសិទ្ធិលើបំណុល និង កាតព្វកិច្ចធ្លាក់ទៅលើបុគ្គលតែម្នាក់ សិទ្ធិលើបំណុល និង កាតព្វកិច្ចនោះត្រូវរលត់ដោយព្យាកុលភាព ។

២-សិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន សិទ្ធិនោះមិនត្រូវរលត់ដោយព្យាកុលភាពឡើយ ។

## ជំពូកទី ៨
## អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

**មាត្រា ៤៨០.-** និយមន័យនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅទៅលើការរលត់សិទ្ធិលើបំណុល ដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ ។

**មាត្រា ៤៨១.-** ពេលចាប់ផ្តើមគិតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន ។

**មាត្រា ៤៨២.-** អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ឬបទដ្ឋានគតិយុត្តផ្សេង ។

**មាត្រា ៤៨៣.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលមានអំឡុងពេលខ្លី

ចំពោះសិទ្ធិលើបំណុលអំពីថ្លៃទំនិញដែលផលិតករ ឬ ពាណិជ្ជករលក់ទៅឱ្យអ្នក



ដែលមិនមែនជាពាណិជ្ជករ និង ថ្លៃសេវាដែលផលិតករ ឬ ពាណិជ្ជករផ្តល់ឱ្យអ្នកដែលមិនមែនជាពាណិជ្ជករ អាជ្ញាយុកាលនៃការរំលត់សិទ្ធិនេះ មានអំឡុងពេល ២ (ពីរ) ឆ្នាំ ។

**មាត្រា ៤៨៤.-** អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលចូលជាស្ថាពរ

១-ចំពោះសិទ្ធិលើបំណុលដែលចូលជាស្ថាពរ ដោយសាលក្រម ឬ សាលដីកាស្ថាពរ ឬ ដោយការផ្សះផ្សាតាមផ្លូវតុលាការ ឬ ដោយវិធីផ្សេងដែលមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ទោះបីជាមានបញ្ញត្តិដែលកំណត់អំឡុងពេលនៃអាជ្ញាយុកាលតិចជាង ៥ (ប្រាំ) ឆ្នាំក៏ដោយ ក៏អាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ត្រូវមានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិលើបំណុលនោះចូលស្ថាពរដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលពេលកំណត់ត្រូវអនុវត្តមិនទាន់ដល់ នៅពេលនៃការចូលជាស្ថាពរ ។

**មាត្រា ៤៨៥.-** អានុភាពប្រតិសកម្មនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមានអានុភាពប្រតិសកម្ម ចាប់តាំងពីថ្ងៃចាប់ផ្តើមគិតអាជ្ញាយុកាលនោះ ។

**មាត្រា ៤៨៦.-** ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

១-តុលាការមិនអាចសម្រេចសេចក្តីដោយយកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានឡើយ លើកលែងតែភាគីបានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ ។

២-ក្រៅពីកូនបំណុល មានតែកូនបំណុលដោយសាមគ្គីភាព អ្នកធានា អ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម ដែលបានកំណត់នៅក្នុងមាត្រា ៧៦៦ (និយមន័យនៃអ្នកធានាដោយវត្ថុ និង តតិយជនដែលបានធ្វើលទ្ធកម្ម) នៃក្រមនេះ និង បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ត្រឹមត្រូវតាមផ្លូវច្បាប់ ក្នុងការលើកឡើងនូវអាជ្ញាយុកាលទេ ដែលអាចលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបាន ។



៣-ប្រសិនបើកូនបំណុលលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល តតិយជនក៏នឹងទទួលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនេះដែរ ។ ប្រសិនបើអ្នកដែលមិនមែនជាកូនបំណុល តែមានសិទ្ធិលើកឡើងនូវអាជ្ញាយុកាល បានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះ អានុភាពនៃការលើកឡើងនេះ កើតឡើងតែរវាងម្ចាស់បំណុល និង អ្នកដែលលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិតែប៉ុណ្ណោះ ។

**មាត្រា ៤៨៧.-** ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មិនអាចបោះបង់ចោលជាមុនបានទេ ។ មានតែផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលបានសម្រេចហើយទេ ទើបអាចបោះបង់ចោលបាន ។

**មាត្រា ៤៨៨.-** វិសាលភាពនៃជនដែលទទួលអានុភាពនៃការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាល នៃការរំលត់សិទ្ធិលើបំណុល

ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអានុភាពតែរវាងម្ចាស់បំណុល និង អ្នកមានសិទ្ធិលើកឡើងដែលបានបោះបង់ចោលនូវផលប្រយោជន៍នោះតែប៉ុណ្ណោះ ។

**មាត្រា ៤៨៩.-** ហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវផ្អាកក្នុងករណីដូចតទៅ :

ក-ការទាមទារតាមផ្លូវតុលាការ ការចូលរួមក្នុងនីតិវិធីធនក្ស័យ ឬ ការអនុវត្តសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែល ។

ខ-សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារ ។

គ-ការទទួលស្គាល់កាតព្វកិច្ច ដោយការសងមួយផ្នែក ការបង់ការប្រាក់ ការដាក់ប្រាតិភោគ ឬវិធីផ្សេង ។

**មាត្រា ៤៩០.-** វិសាលភាពនៃជនដែលទទួលអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ប្រសិនបើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល កើតឡើងចំពោះកូនបំណុល អ្នកដទៃទៀតមិនអាចបដិសេធនូវអានុភាពនៃការផ្អាកនេះបានទេ ។ ប្រសិនបើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល កើតឡើងចំពោះអ្នកមានសិទ្ធិលើកឡើង ក្រៅពីកូនបំណុល អានុភាពនៃការផ្អាកនេះត្រូវកើតឡើង តែរវាងម្ចាស់បំណុល និង អ្នកមានសិទ្ធិលើកឡើងតែប៉ុណ្ណោះ ។

**មាត្រា ៤៩១.-** ការទាមទារតាមផ្លូវតុលាការ

ការទាមទារតាមផ្លូវតុលាការមិនត្រូវបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ក្នុងករណីដែលបណ្ដឹងត្រូវបានលើកចោល ឬ ត្រូវបានដកវិញ ។

**មាត្រា ៤៩២.-** ការលុបចោលនូវការចាត់ចែងអនុវត្តដោយបង្ខំ ឬ ការចាត់ចែងរក្សាការពារ

ក្នុងករណីដែលការចាត់ចែងអនុវត្តដោយបង្ខំ ឬ ការរក្សាការពារ ត្រូវបានលុបចោលតាមពាក្យសុំរបស់ភាគី ឬ ដោយការខ្វះល័ក្ខខ័ណ្ឌតាមផ្លូវច្បាប់ ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដោយសកម្មភាពអនុវត្តដោយបង្ខំ ឬ ដោយសកម្មភាពចាត់ចែងការរក្សាការពារនេះ ត្រូវចាត់ទុកថា មិនបានកើតឡើងឡើយ ។

**មាត្រា ៤៩៣.-** សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារដែលធ្វើឡើង ចំពោះបុគ្គល ក្រៅពីកូនបំណុល

សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារដែលធ្វើឡើងចំពោះបុគ្គលក្រៅពីកូនបំណុល ត្រូវបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល លុះត្រាតែសកម្មភាពនោះ ត្រូវបានជូនដំណឹងទៅកូនបំណុល ។



**មាត្រា ៤៩៤.-** ដំណើរការនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ក្រោយការផ្អាក

១-អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានផ្អាក នឹងចាប់ផ្ដើមគិតជាថ្មីម្ដងទៀត ក្រោយពីហេតុនៃការផ្អាកបានចប់ ។

២-អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានផ្អាកដោយការទាមទារតាមផ្លូវតុលាការ នឹងចាប់ផ្ដើមគិតជាថ្មីម្ដងទៀត បន្ទាប់ពីសេចក្ដីសម្រេចចូលជាស្ថាពរ ។

**មាត្រា ៤៩៥.-** ការបង្អង់ការសម្រេចអាជ្ញាយុកាលដោយការដាស់តឿន និង ដោយការដាស់តឿនតាមផ្លូវតុលាការ

១-ប្រសិនបើអ្នកមានសិទ្ធិបានដាស់តឿន នៅពេលណាមួយក្នុងអំឡុង៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលរំលត់សិទ្ធិលើបំណុលនោះមិនត្រូវបានសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការដាស់តឿនឡើយ ។ ប៉ុន្តែ ទោះបីជាអ្នកមានសិទ្ធិដាស់តឿនម្ដងទៀតក៏ដោយ ក៏មិនអាចពន្យឺតការសម្រេចអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល ដោយការដាស់តឿនម្ដងទៀតនោះដែរ ។

២-ទោះបីជាការទាមទារតាមផ្លូវតុលាការ មិនបង្កើតអានុភាពនៃការផ្អាកអាជ្ញា-យុកាល ដោយសារការលើកចោលបណ្ដឹង ឬ ការដកពាក្យបណ្ដឹងក៏ដោយ ក៏ត្រូវចាត់ទុកថា អ្នកប្ដឹងបានដាស់តឿនជាបន្ត ចាប់ពីពេលដែលពាក្យបណ្ដឹងត្រូវបានបញ្ជូន ទៅភាគីម្ខាងទៀត រហូតដល់ពេលដែលបណ្ដឹងនោះត្រូវបានលើកចោល ឬ ពេលដែលពាក្យបណ្ដឹងនោះត្រូវបានដកដែរ ។ ក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះមិនត្រូវបានសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការលើកចោលបណ្ដឹង ឬ ការដកពាក្យបណ្ដឹងឡើយ ។

៣-ប្រសិនបើអ្នកមានសិទ្ធិបានអះអាងសិទ្ធិរបស់ខ្លួន ក្នុងនាមជាចុងចម្លើយក្នុងបណ្ដឹងនោះ ត្រូវចាត់ទុកថា អ្នកនោះដាស់តឿនជាបន្ត ក្នុងពេលដែលបណ្ដឹងនោះកំពុងចាត់ការ ចាប់ពីពេលដែលអ្នកនោះ អះអាងសិទ្ធិរបស់ខ្លួន ។ ក្នុងករណីនេះ អាជ្ញាយុកាល



នៃការរំលត់សិទ្ធិលើបំណុលនោះមិនត្រូវសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីសាលក្រម ឬ សាលដីកានៃបណ្ដឹងនោះចូលជាស្ថាពរ ។

**មាត្រា ៤៩៦.-** ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលចំពោះអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ

ប្រសិនបើអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ គ្មានអ្នកតំណាងដែលច្បាប់បានកំណត់ នៅពេលណាមួយ ក្នុងអំឡុង ៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ មិនត្រូវបានសម្រេច ចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីពេលដែលអ្នកនោះក្លាយទៅជាសមត្ថជន ឬ ពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបានជ្រើសតាំងឡើយ ។

**មាត្រា ៤៩៧.-** ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរវាងប្ដីប្រពន្ធ

ចំពោះសិទ្ធិដែលសហព័ទ្ធម្ខាងមានលើសហព័ទ្ធម្ខាងទៀត អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ក្រោយពីការរលាយអាពាហ៍ពិពាហ៍ឡើយ ។

**មាត្រា ៤៩៨.-** ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសារមហន្តរាយធម្មជាតិ

ប្រសិនបើអ្នកមានសិទ្ធិមិនអាចផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសារការជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិ ឬ ប្រធានសក្ដិផ្សេង នៅពេលណាមួយក្នុង ៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះមិនត្រូវបានសម្រេច ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីប្រធានសក្ដិនោះ បានកន្លងផុតឡើយ ។



**មាត្រា ៤៩៩.-** តាវកាលិកដើម្បីបំពេញនូវសិទ្ធិលើបំណុលដែលផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ចំពោះតាវកាលិកដែលត្រូវបានផ្ដល់ ដើម្បីបំពេញនូវសិទ្ធិលើបំណុលដែលផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ទោះបីជាអ្នកនោះផ្ដល់តាវកាលិក ដោយមិនបានដឹងថា ផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក៏ដោយ ក៏អ្នកនោះមិនអាចទាមទារឱ្យសងតាវកាលិកនោះវិញឡើយ ។

**មាត្រា ៥០០.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិមានអំឡុងពេល ១០ (ដប់) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេង ។ បញ្ញត្តិស្ដីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ ។

# គន្លឹទី ៤ កាតព្វកិច្ច
# ជំពូកទី ១ បទប្បញ្ញត្តិទូទៅ

## ផ្នែកទី ១ ប្រភពនៃកាតព្វកិច្ច និង និយមន័យនៃពាក្យៈផ្សេងៗ

### ១.កាតព្វកិច្ច

#### ១.១. និយមន័យ

កាតព្វកិច្ច គឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីនាក់ ដោយឲ្យបុគ្គលម្នាក់ដែលបានកំណត់មាន ករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត (មាត្រា ៣០៨ នៃក្រមរដ្ឋប្បវេណី)។

**+ កាតព្វកិច្ច និង ករណីយកិច្ច**

កាតព្វកិច្ច គឺជាប្រភេទមួយនៃករណីយកិច្ច ប៉ុន្តែករណីយកិច្ចទាំងអស់ មិនមែនសុទ្ធតែជាកាតព្វកិច្ចទេ។ ពាក្យកាតព្វកិច្ច ត្រូវបានប្រើក្នុងករណីដែលឆ្លើយតបទៅនឹងសិទ្ធិលើបំណុល ដូចជា អ្នកទិញ មានកាតព្វកិច្ចបង់ប្រាក់ គឺ ឆ្លើយតបនឹងសិទ្ធិទាមទារឲ្យបង់ប្រាក់របស់អ្នកលក់។

ពាក្យករណីយកិច្ច ជូនកាលត្រូវបានប្រើក្នុងករណីមិនឆ្លើយតបចំពោះសិទ្ធិលើបំណុល (សិទ្ធិទាមទារ) ទេ។

ឧទាហរណ៍ អ្នកបើកបរឡាន ម៉ូតូ មានករណីយកិច្ចប្រុងប្រយ័ត្ន នៅពេលបើកបរតាមផ្លូវ មិនឲ្យមានគ្រោះថ្នាក់ដល់បុគ្គលផ្សេងទៀត។

បើយើងចងក្រងជាសំណុំ យើងនឹងឃើញថា សំណុំរបស់កាតព្វកិច្ច គឺនៅក្នុងសំណុំរបស់ករណីយកិច្ច។




**+ កាតព្វកិច្ច និង សិទ្ធិលើបំណុល**

ពុំមានមាត្រាណាចែងអំពីនិយមន័យនៃសិទ្ធិលើបំណុលទេ តែមានមាត្រាចែងអំពីនិយមន័យនៃកាតព្វកិច្ច តែតាមពិតទៅការឲ្យនិយមន័យកាតព្វកិច្ច ក៏ដូចជាការកំណត់ពីសិទ្ធិលើបំណុលដែរ ព្រោះកាតព្វកិច្ច និងសិទ្ធិលើបំណុល គឺមានទំនាក់ទំនងមុខពីរ (កាតព្វកិច្ចរបស់ភាគីម្ខាង ត្រូវគ្នានឹងសិទ្ធិរបស់ភាគីម្ខាងទៀត)។ បុគ្គលម្ខាងដែលទទួលផលប្រយោជន៍ ហៅថា ម្ចាស់បំណុល ឯបុគ្គលម្ខាងទៀត ដែលទទួលបន្ទុក ហៅថា កូនបំណុល (មាត្រា ៣០៨ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។ ម្ចាស់បំណុលមានសិទ្ធិទាមទារឲ្យកូនបំណុលធ្វើ ឬ មិនធ្វើសកម្មភាពអ្វីមួយមកឲ្យខ្លួន។ យើងលើកឧទាហរណ៍ពីកិច្ចសន្យាលក់ទិញដែលជាកិច្ចសន្យាអញ្ញមញ្ញមួយមកសិក្សា។

អ្នកលក់ A ———————————— B អ្នកទិញ

បើយើងជាភាគី A ឃើញថា យើងមានសិទ្ធិលើបំណុល ដោយឲ្យភាគី B បង់ប្រាក់ថ្លៃលក់ទិញមកឲ្យខ្លួន។ សិទ្ធិទាមទារនេះ ត្រូវគ្នានឹងករណីយកិច្ចបង់ប្រាក់របស់ភាគី B។ ក្នុងករណីនេះ A ជាម្ចាស់បំណុល រីឯ B វិញ គឺជាកូនបំណុល។

បើយើងជាភាគី B វិញ ឃើញថា យើងមានសិទ្ធិលើបំណុល ដោយឲ្យភាគី A ផ្ទេរកម្មសិទ្ធិ និង ផ្ទេរការកាន់កាប់វត្ថុមកឲ្យខ្លួន។ សិទ្ធិទាមទារនេះ ត្រូវគ្នានឹងករណីយកិច្ចផ្ទេរកម្មសិទ្ធិ និងផ្ទេរការកាន់កាប់របស់ភាគី A។ ក្នុងករណីនេះ B ជាម្ចាស់បំណុល រីឯ A វិញជាកូនបំណុល។

នៅក្នុងកិច្ចសន្យាលក់ទិញ អ្នកលក់ជាម្ចាស់បំណុលផង ជាកូនបំណុលផង ហើយអ្នកទិញក៏ជាម្ចាស់បំណុលផង និង ជាកូនបំណុលផងដែរ។

## ១.២. ភាពខុសគ្នារវាងសិទ្ធិលើបំណុល និង សិទ្ធិប្រត្យក្ស

ក្រមរដ្ឋប្បវេណី កំណត់ពីសិទ្ធិដែលយើងមានទៅលើវត្ថុ (សិទ្ធិប្រត្យក្ស) និងទៅលើបុគ្គល (សិទ្ធិលើបំណុល)។

| សិទ្ធិលើបំណុល | សិទ្ធិប្រត្យក្ស |
|---|---|
| • សិទ្ធិលើបំណុល ជាសិទ្ធិលើបុគ្គល ជាសិទ្ធិដែលអាចទាមទារឲ្យបុគ្គលណាមួយធ្វើសកម្មភាពអ្វីមួយ ឬ មិនធ្វើសកម្មភាពអ្វីមួយ។ អ្នកដែលមានសិទ្ធិលើបំណុល ហៅថាម្ចាស់បំណុល។<br>• សិទ្ធិលើបំណុលពុំមានភាពដាច់ខាត មិនផ្តាច់មុខ។<br>• ភាពមិនដាច់ខាតរបស់សិទ្ធិលើបំណុល៖ ម្ចាស់បំណុលអះអាងសិទ្ធិទាមទាររបស់ខ្លួនបានតែចំពោះបុគ្គលជាក់លាក់ (កូនបំណុល) តែប៉ុណ្ណោះ មិនអាចអះអាងដល់ជនដទៃឡើយ។ ចំណងចងភ្ជាប់តែរវាងម្ចាស់បំណុល និង កូនបំណុលតែប៉ុណ្ណោះ។ ឧទាហរណ៍ A ឲ្យ B ខ្ចីប្រាក់ (ខ្ចីបរិភោគ) A ពុំអាចទាមទារឲ្យបងប្អូន B សងជំនួសឡើយ។ មានការវិវឌ្ឍន៍ ដោយក្រមរដ្ឋប្បវេណីថ្មីដែលអនុញ្ញាតឲ្យមានការធ្វើអនុប្បទានសិទ្ធិលើបំណុល (មាត្រា ៥០១ នៃក្រមរដ្ឋប្បវេណី) និង ការទទួលកាតព្វកិច្ច (មាត្រា ៥០៧ នៃក្រមរដ្ឋប្បវេណី)។<br>• ភាពមិនផ្តាច់មុខនៃសិទ្ធិលើបំណុល៖ បុគ្គលតែមួយ អាចមានកាតព្វកិច្ចដូចគ្នាច្រើន។ A មានដីមួយកន្លែង តែ A បានលក់ដីនោះឲ្យទៅ B ផង ហើយលក់ទៅឲ្យ C ផង ដោយ B ពុំបានចុះបញ្ជី C បានចុះបញ្ជី។ កម្មសិទ្ធិត្រូវបានផ្ទេរឲ្យ C ប៉ុន្តែ A មានកាតព្វកិច្ចប្រគល់ដីឲ្យ B ផង និងប្រគល់ដីដដែលនោះឲ្យទៅ C | • សិទ្ធិប្រត្យក្ស គឺសំដៅទៅលើសិទ្ធិគ្រប់គ្រងវត្ថុដោយចំពោះ។ កម្មសិទ្ធិករលើវត្ថុណាមួយ អាចគ្រប់គ្រងដោយសេរីលើវត្ថុដែលជារបស់ខ្លួន ដោយមិនមានការជ្រៀតជ្រែកពីអ្នកដទៃ។ កម្មសិទ្ធិករ អាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនដោយសេរីក្នុងទំហំដែលច្បាប់បានកម្រិត (មាត្រា ១៣៨ នៃក្រមរដ្ឋប្បវេណី)។<br>• សិទ្ធិប្រត្យក្ស មានភាពដាច់ខាត ផ្តាច់មុខ។<br>• ភាពដាច់ខាតរបស់សិទ្ធិប្រត្យក្ស៖ កម្មសិទ្ធិករលើវត្ថុអ្វីមួយ អាចអះអាងពីសិទ្ធិរបស់ខ្លួនចំពោះបុគ្គលគ្រប់រូប ដូចជាអាចទាមទារឲ្យប្រគល់វិញ តាមមាត្រា ១៥៥ សិទ្ធិទាមទារឲ្យបញ្ឈប់ និង បង្ការការរាំងសិទ្ធិលើកម្មសិទ្ធិ តាមមាត្រា ១៥៩ នៃក្រមរដ្ឋប្បវេណី។<br>• ភាពផ្តាច់មុខរបស់សិទ្ធិប្រត្យក្ស៖ វត្ថុមួយមានសិទ្ធិតែមួយ ច្បាប់មិនអនុញ្ញាតឲ្យបង្កើតសិទ្ធិមួយទៀត ដែលមានខ្លឹមសារដូចគ្នាលើវត្ថុតែមួយបានទេ។ បើដីមួយកន្លែងជារបស់ A ដីដដែលនោះ មិនអាចជារបស់ B បានទេ។<br>• គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់ មាត្រា ១៣១ សិទ្ធិប្រត្យក្សអាចបង្កើតបានតាមក្រមរដ្ឋប្បវេណី និង ច្បាប់ពិសេស។ |

<table>
<tr>
<td>ផងៗ A អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចចំពោះ B ត្រូវទទួលខុសត្រូវសងការខូចខាត (មាត្រា ៣៩៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។<br><br><br>ចុះបញ្ជី<br>• សិទ្ធិលើបំណុលអាចបង្កើតឡើងដោយសេរីឲ្យតែមិនផ្ទុយទៅនឹងវិធាននៃច្បាប់ តាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន (មាត្រា ៣ នៃក្រមរដ្ឋប្បវេណី)។</td>
<td></td>
</tr>
</table>

## ២. ប្រភពនៃកាតព្វកិច្ច

កាតព្វកិច្ចកើតឡើងដោយកិច្ចសន្យា (មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី) ដោយសកម្មភាពឯកតោភាគី (មាត្រា ៣១២ នៃក្រមរដ្ឋប្បវេណី) ដោយការគ្រប់គ្រងដោយឈឺឆ្អាល (មាត្រា ៧២៩ នៃក្រមរដ្ឋប្បវេណី) ដោយសេចក្ដីចម្រើនដោយឥតហេតុ (មាត្រា ៧៣៦ នៃក្រមរដ្ឋប្បវេណី) ដោយអំពើអនីត្យានុកូល (មាត្រា ៧៤២ នៃក្រមរដ្ឋប្បវេណី) និងដោយបញ្ញត្តិច្បាប់។

- កាតព្វកិច្ចកើតឡើងពីកិច្ចសន្យា និង សកម្មភាពឯកតោភាគី គឺ កាតព្វកិច្ចកើតឡើងដោយឆន្ទៈរបស់ភាគី (មាត្រា ៣០៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។
- កាតព្វកិច្ចដែលកើតឡើងដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្ដីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង ដោយបញ្ញត្តិច្បាប់ គឺជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ដែលកើតឡើងដោយគ្មានការបង្ហាញឆន្ទៈរបស់ភាគី (មាត្រា ៣០៩ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី)។

## ៣. និយមន័យនៃការបង្ហាញឆន្ទៈ កិច្ចសន្យា សកម្មភាពឯកតោភាគី

**+ ការបង្ហាញឆន្ទៈ** ៖ ការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្ត ហៅថា ការបង្ហាញឆន្ទៈ (មាត្រា ៣១០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។ ឧទាហរណ៍ សំណើ និង ស្ទីការដើម្បីបង្កើតកិច្ចសន្យា ឬ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា គឺជាការបង្ហាញឆន្ទៈ។ ផ្ទុយមកវិញ ការពោលពាក្យពេចន៍ស្នេហាប្រាប់គូសង្សារ មិនមែនជាការបង្ហាញឆន្ទៈទេ ព្រោះវាមិនមានបំណងចង់បង្កើតឲ្យមានចំណងគតិយុត្តទេ។

ការបង្ហាញឆន្ទៈ ត្រូវមានអានុភាពចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈនោះបានទៅដល់ភាគីម្ខាងទៀត (មាត្រា ៣១០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែ មានការបង្ហាញឆន្ទៈខ្លះមិនអាចធ្វើឡើងចំពោះភាគីម្ខាងទៀតទេ ដូចជា អច្ច័យទាន។

- បើគូភាគីអង្គុយនិយាយតទល់មុខគ្នា ការបង្ហាញឆន្ទៈនេះមានអានុភាពភ្លាម ហើយការផ្ញើសារអេឡិចត្រូនិកទៅភាគីម្ខាងទៀត ក៏មានអានុភាពភ្លាមដែរ ព្រោះសារនៃការបង្ហាញឆន្ទៈ បានទៅដល់ភាគីនោះភ្លាមៗ។
- បើការបង្ហាញឆន្ទៈតាមរយៈសំបុត្រប្រៃសណីយ៍ អានុភាពនៃការបង្ហាញឆន្ទៈនោះកើតឡើងពេលសំបុត្របានដាក់ក្នុងប្រអប់សំបុត្ររបស់ភាគីម្ខាងទៀត ឬ នៅពេលដែលសមាជិកគ្រួសារដែលរស់នៅ ជាមួយភាគីម្ខាងទៀតនោះបានទទួលសំបុត្រ ទោះបីជាភាគីម្ខាងទៀតនោះដឹង ឬ មិនដឹងអំពីការទៅដល់នៃសំបុត្រក៏ដោយ។
- ការបង្ហាញឆន្ទៈតាមរយៈទូរស័ព្ទ ក៏មានអានុភាពភ្លាមដែរ។
- ការបង្ហាញឆន្ទៈចំពោះអនីតិជន ឬ ជនស្ថិតនៅក្រោមរបបអ្នកអាណាព្យាបាល ត្រូវធ្វើឡើងចំពោះអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាល។

  ** ក៏ប៉ុន្តែ បើមានវិវាទហេតុប្តឹងទៅតុលាការ ភាគីម្ខាងអះអាងថា ខ្លួនបានទទួលសំបុត្រមែន ឬ បានទទួលទូរស័ព្ទមែន តែពុំបាននិយាយពីការរំលាយកិច្ចសន្យាទេ នោះមាត្រា ៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីដែលចែងអំពីការជូនដំណឹងអំពីការបង្ហាញឆន្ទៈទៅអ្នកឆ្ងាយបានកំណត់អំពីវិធីបញ្ជាក់អំពីការបង្ហាញឆន្ទៈទៅអ្នកឆ្ងាយ។

**+ កិច្ចសន្យា**៖ កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់ មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច (មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណី)។




- បង្កើតកាតព្វកិច្ចតាមកិច្ចសន្យា ៖ A មានដី B ចង់ជួល ហើយ A និង B ព្រមព្រៀងបង្កើតកិច្ចសន្យាជួល ដោយ A មានកាតព្វកិច្ចប្រគល់ដី ហើយ B មានកាតព្វកិច្ចបង់ប្រាក់ដែលជាថ្លៃឈ្នួល។
- កែប្រែកាតព្វកិច្ចតាមកិច្ចសន្យា ៖ កែប្រែ សំដៅទៅលើការផ្លាស់ប្តូរ ដូចជាផ្លាស់ប្តូរអំឡុងពេលជួល ថ្លៃឈ្នួល ពេលវេលាបង់ថ្លៃឈ្នួល ជាដើម។
- រំលត់កាតព្វកិច្ចតាមកិច្ចសន្យា ៖ ពេលបង្កើត បានកំណត់អំឡុងពេលជួលរយៈពេល ១០ឆ្នាំ តែក្រោយមកភាគី A និង B បានព្រមព្រៀងរំលាយកិច្ចសន្យាមុនអាណត្តិ។

**+ សកម្មភាពឯកតោភាគី** ៖ សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់ (មាត្រា ៣១២ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)។

- កិច្ចសន្យា តម្រូវឲ្យមានការព្រមព្រៀងរវាងគូភាគី តែសកម្មភាពឯកតោភាគី មិនតម្រូវឲ្យមានការព្រមព្រៀងពីភាគីម្ខាងទៀតទេ។

- បង្កើតកាតព្វកិច្ចតាមសកម្មភាពឯកតោភាគី ៖ អច្ច័យទាន ជាសកម្មភាពឯកតោភាគីក្នុងការបង្កើតកាតព្វកិច្ច ប៉ុន្តែ កាតព្វកិច្ចត្រូវធ្លាក់ទៅលើសន្តតិជន។ ការទទួលស្គាល់កូន ក៏ជាសកម្មភាពឯកតោភាគីដែរ ពីព្រោះឪពុកមានកាតព្វកិច្ចចិញ្ចឹម និងថែរក្សាកូនដែលជាអនីតិជន ជាដើម។
- ការកែប្រែកាតព្វកិច្ចតាមសកម្មភាពឯកតោភាគី ៖ ការកែប្រែ សំដៅទៅលើការផ្លាស់ប្តូរ។ ឧទាហរណ៍ នៅក្នុងកិច្ចសន្យាលក់ទិញរថយន្ត អ្នកលក់បានសន្យាថានឹងយករថយន្តទៅឲ្យអ្នកទិញដល់ផ្ទះ។ នៅក្នុងកិច្ចសន្យា បានផ្តល់សិទ្ធិឲ្យអ្នកទិញអាចផ្លាស់ប្តូរទីកន្លែងនៃការប្រគល់ក្រៅពីក្រុងភ្នំពេញបាន ប្រសិនបើអ្នកទិញទាក់ទងមកអ្នកលក់នៅមុន ៣ថ្ងៃ។ ប្រសិនបើអ្នកទិញទាក់ទងទៅអ្នកលក់ ដោយសុំឲ្យផ្លាស់ប្តូរទីកន្លែងនៃការដឹកជញ្ជូនមកកន្លែងធ្វើការវិញនោះ នេះគឺជាការកែប្រែកាតព្វកិច្ចតាមសកម្មភាពឯកតោភាគី។
- រំលត់កាតព្វកិច្ចតាមសកម្មភាពឯកតោភាគី ៖ ការលុបចោលកិច្ចសន្យា(មាត្រា ៣៥៨ នៃក្រមរដ្ឋប្បវេណី) ការរំលាយកិច្ចសន្យា(មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី) គឺជាសកម្មភាពឯកតោភាគី។ ការលើកលែង (មាត្រា ៤៧៣ នៃក្រមរដ្ឋប្បវេណី) ក៏ជាសកម្មភាពឯកតោភាគី។

# ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

-លេខ ១៦៦១ "ព"

ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

-សំណុំរឿងរដ្ឋប្បវេណីលេខ ២២៣១

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ លើសំណុំរឿងរដ្ឋប្បវេណីលេខ២២៣១ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

-លោកស្រី [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**ខាងគូភាគី៖**

**ដើមចោទ៖** ឈ្មោះ សៀក ម៉េងហ៊ាង ភេទប្រុស អាយុ៣១ឆ្នាំ មុខរបរធនាគារ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១០៥០០៥៩៧ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ មានអាសយដ្ឋានផ្ទះលេខ៣៨២០ ផ្លូវ១១៣ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**ចុងចម្លើយ:** ឈ្មោះ ណាំ វណ្ណា ភេទប្រុស អាយុ៤១ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦០១៣៨៥២៨ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ មានអាសយដ្ឋាននៅភូមិដំណាក់ព្រៃ ឃុំមេជីកង ស្រុកកងមាស ខេត្តកំពង់ចាម។

**I.សេចក្ដីសង្ខេប និងចំណុចវិវាទ**

១.ប្រធានបទនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

១.១-បង្គាប់ឱ្យចុងចម្លើយសងប្រាក់ដើមចំនួន ២៥,០០០(ពីរម៉ឺនប្រាំពាន់)ដុល្លារអាមេរិកគត់

១.២-ទាមទារការប្រាក់តាមកំណត់ច្បាប់

១.៣-ទាមទារសំណងជម្ងឺចិត្តចំនួន ១០,០០០(មួយម៉ឺន)ដុល្លារអាមេរិក

១.៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

២.ការពន្យល់ស្រួលៗអំពីរឿងក្ដី

រឿងក្ដីនេះ គឺជារឿងក្ដីដែលដើមចោទអះអាងថា ចុងចម្លើយខ្ចីប្រាក់ពីដើមចោទចំនួន ០៤លើក តាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣, កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣, កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ និងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤ ដែលរាល់ទឹកប្រាក់ក៏ពីសរុបស្មើនឹង ២៥,០០០(ម្ភៃប្រាំពាន់)ដុល្លារអាមេរិក។ ក្រោយពីទទួលប្រាក់រួចចុងចម្លើយមិនធ្លាប់បានបង់ការប្រាក់ ឬសងប្រាក់ដើមមកដើមចោទឡើយ ទោះបីជាដើមចោទព្យាយាមទាក់ទងចុងចម្លើយយ៉ាងណាក៏ដោយ។ ដូច្នេះដើមចោទប្ដឹងទាមទារប្រាក់មកតុលាការ។

៣.អង្គហេតុដែលអះអាងដោយដើមចោទ

ដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយផ្អៀងផ្ទាត់ទៅលើអង្គហេតុ និងអង្គច្បាប់ថា៖

អំពីការទាមទារទី១: ដើមចោទបញ្ជាក់ថា ចុងចោទបានខ្ចីប្រាក់ពីខ្លួនចំនួន៤លើក គឺលើកទី១ចំនួន ១០,០០០ (មួយម៉ឺន)ដុល្លារអាមេរិក, លើកទី២ចំនួន ១០,០០០(មួយម៉ឺន)ដុល្លារអាមេរិក, លើកទី៣ចំនួន ៣០០០(បីពាន់)ដុល្លារអាមេរិក និងលើកទី៤ចំនួន ២០០០(ពីរពាន់)ដុល្លារអាមេរិក។ ក្នុងការខ្ចីប្រាក់នេះពួកខ្លួនមិនបានធ្វើលិខិតប្រគល់ទទួលប្រាក់ទេ ដោយប្រគល់-ទទួលប្រាក់នៅពេលចុះកិច្ចសន្យាតែម្តង។ ប្រាក់ដើមដែលខ្លួនប្រគល់ឲ្យទៅចុងចោទគឺនៅថ្ងៃចុះកិច្ចសន្យា និងពេលចំនួនដូចកំណត់ក្នុងកិច្ចសន្យានីមួយៗច្បាស់លាស់រួចហើយ។ តាំងពីប្រគល់ប្រាក់ឲ្យចុងចោទរួចមក ចុងចោទពុំដែលសងប្រាក់ដើមមកខ្លួនទេ គឺបង់តែការប្រាក់ដូចកំណត់ក្នុងកិច្ចសន្យានីមួយៗប៉ុណ្ណោះ។

<u>អំពីការទាមទារទី២:</u> ក្នុងរឿងនេះខ្លួនសុំទាមទារការប្រាក់តាមច្បាប់ ដោយមិនទាមទារការប្រាក់ដែលកំណត់ក្នុងកិច្ចសន្យាទេ ព្រោះចុងចោទអសមត្ថភាពក្នុងការបង់ការប្រាក់តាំងពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន។

<u>អំពីការទាមទារទី៣:</u> ចំពោះការទាមទារសំណងជំងឺចិត្ត គឺខ្លួនសុំដោយហេតុការខូចខាតកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចោទរយៈពេលជាច្រើនឆ្នាំមកនេះ ធ្វើឲ្យខ្លួនបាត់បង់ចំណូលបន្ថែមជាច្រើនផងដែរ។

<u>អំពីការទាមទារទី៤:</u> សុំឲ្យតុលាការសម្រេចតាមច្បាប់។

**៤.អង្គហេតុដែលអះអាងដោយចុងចោទ**

-ចុងចោទអវត្តមានគ្រប់ដំណាក់កាលនៃនីតិវិធី ទោះបីជាបានទទួលដីកាកោះហៅត្រឹមត្រូវអំពីកាលបរិច្ឆេទនៃនីតិវិធីក៏ដោយ ដូច្នេះគ្មានសេចក្តីថ្លែងការណ៍។

**៥.ចំណុចវិវាទ: គ្មាន។**

## II.ការពិនិត្យភស្តុតាង

**១.ភស្តុតាងជាឯកសាររបស់ដើមចោទ**

១.១.ឯកសារ $X_1$ ៖កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣(ថតចម្លង០១ច្បាប់)

១.២.ឯកសារ $X_2$ ៖កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣(ថតចម្លង០១ច្បាប់)

១.៣.ឯកសារ $X_3$ ៖កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣(ថតចម្លង០១ច្បាប់)

១.៤.ឯកសារ $X_4$ ៖កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤(ថតចម្លង០១ច្បាប់)។

**២.ភស្តុតាងជាឯកសាររបស់ចុងចោទ: (គ្មាន)**

**៣.ការសាកសួរសាក្សី:(គ្មាន)**

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

១.បានទទួលពាក្យបណ្តឹងចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ មានទម្រង់ត្រឹមត្រូវអាចឲ្យតុលាការលើកមកពិចារណា។

២.ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣, កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣, កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ និងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤ បញ្ជាក់ថា ចុងចោទពិតជាបានចុះកិច្ចសន្យាខ្ចីប្រាក់ដើមចោទនូវប្រាក់កំចីសរុបចំនួន ២៥,០០០ (ម្ភៃប្រាំពាន់) ដុល្លារអាមេរិក ប្រាកដមែន។

៣.ដើមចោទបានអះអាងចំពោះការទាមទាររបស់ខ្លួនថា ចុងចោទបានខ្ចីប្រាក់ពីខ្លួនចំនួន៤លើក គឺលើកទី១ចំនួន ១០,០០០(មួយម៉ឺន)ដុល្លារអាមេរិក, លើកទី២ចំនួន ១០,០០០(មួយម៉ឺន)ដុល្លារអាមេរិក, លើកទី៣ចំនួន ៣០០០(បីពាន់)ដុល្លារអាមេរិក និងលើកទី៤ចំនួន ២០០០(ពីរពាន់)ដុល្លារអាមេរិក។ ក្នុងការខ្ចីប្រាក់នេះពួកខ្លួនមិនបានធ្វើលិខិតប្រគល់ទទួល.

ប្រាក់ទេ ដោយប្រគល់-ទទួលប្រាក់នៅពេលធ្វើកិច្ចសន្យាតែម្តង។ ប្រាក់ដើមដែលខ្លួនប្រគល់ឱ្យទៅចុងចម្លើយគឺនៅថ្ងៃធ្វើកិច្ចសន្យា និងពេលចំនួនម្ភៃកំណត់ក្នុងកិច្ចសន្យានីមួយៗទាំងអស់រួចហើយ។ តាំងពីប្រគល់ប្រាក់ឱ្យចុងចម្លើយរួចមក ចុងចម្លើយពុំដែលសងប្រាក់ដើមមកខ្លួនទេ គឺបង់តែការប្រាក់ដូចកំណត់ក្នុងកិច្ចសន្យានីមួយៗប៉ុណ្ណោះ។

៥.ចុងចម្លើយបានទទួលដំណឹងពីដីកាកោះហៅ និងកំណត់ហេតុប្រជុំនីតិវិធី ប៉ុន្តែពុំបានជំទាស់ ឬតវ៉ា នឹងសេចក្តីថ្លែងការណ៍របស់ដើមចោទឡើយ ដូច្នេះតុលាការចាត់ទុកថា ចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទទាក់ទងនឹងអង្គហេតុ គប្បីតុលាការពិចារណាតាមបញ្ញត្តិមាត្រា២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៦.ចំពោះការកំណត់អត្រាការប្រាក់ ក្នុងកិច្ចសន្យាគូភាគីបានកំណត់ការប្រាក់ក្នុងអត្រា ៣% ទៅ ៣,៥% ក្នុង១ខែ ប៉ុន្តែនៅក្នុងដីកាសំណើនៃការទាមទារ ដើមចោទទាមទារការប្រាក់តាមកំណត់ច្បាប់ មានន័យថា ៥% ក្នុង ១ ឆ្នាំ លើប្រាក់ដើមមិនទាន់ទូទាត់ ដោយសំអាងថាចុងចម្លើយពុំមានលទ្ធភាពបង់ប្រាក់ឱ្យខ្លួនឡើយ។ ដូច្នេះតុលាការពិនិត្យឃើញថា ជាការទាមទារដែលសមរម្យ និងបានជាប្រយោជន៍ដល់ភាគីចុងចម្លើយ គប្បីតុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទ។

៧.ដោយឡែករយៈពេលដែលត្រូវគិតការប្រាក់ ដើមចោទអះអាងថា ចំពោះកិច្ចសន្យាទាំងបួនលើកខាងលើ ចុងចម្លើយខកខានមិនបង់ការប្រាក់ឱ្យខ្លួនចាប់តាំងពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៥ ដូច្នេះខ្លួនទាមទារឱ្យចុងចម្លើយសងការប្រាក់ដោយគិតចាប់ពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៥ រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន គប្បីតុលាការពិចារណា។

៨.ដើមចោទបានទាមទារសំណងការខូចខាត ដំណើរចិត្ត និងថ្លៃសេវាកម្មច្បាប់សរុបចំនួន ១០,០០០$ (មួយម៉ឺនដុល្លារអាមេរិក) ដោយអះអាងថា ខ្លួនសំដៅលើការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយរយៈពេលជាច្រើនឆ្នាំមកនេះ ធ្វើឱ្យខ្លួនបាត់បង់ចំណូលបន្ថែមជាច្រើនផងដែរ។ តុលាការពិនិត្យឃើញថា ការទាមទាររបស់ដើមចោទកើតឡើងពីការខូចខាតជាទ្រព្យសម្បត្តិ មានន័យថាបើការខូចខាតលើទ្រព្យសម្បត្តិទាំងនោះត្រូវបានធ្វើបដិទានហើយ ការឈឺចាប់ផ្លូវចិត្តក៏ត្រូវបានធ្វើបដិទានឡើងវិញរួចរាល់ដែរ។ ដូច្នេះគប្បី តុលាការច្រានចោលការទាមទាររបស់ដើមចោទដោយមូលហេតុគ្មានភាពនៃការទាមទារ។

៩.ដើមចោទទាមទារសុំប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នលើសេចក្តីសម្រេចទាំងមូលនៃសាលក្រម តុលាការពិចារណាឃើញថា មានមូលហេតុត្រឹមត្រូវតាមបញ្ញត្តិមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីតុលាការលើកមកពិចារណា។

១០.ការទាមទាររបស់ដើមចោទ មានមូលហេតុត្រឹមត្រូវតាមច្បាប់ ហេតុដូច្នេះសម្រេចទទួលស្គាល់ការទាមទាររបស់ដើមចោទ រីឯប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមបញ្ញត្តិមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១.បង្គាប់ឱ្យចុងចម្លើយសងប្រាក់ទៅឱ្យដើមចោទដូចខាងក្រោម៖

១.១-ប្រាក់ដើមសរុបចំនួន ២៥,០០០(ម្ភៃប្រាំពាន់) ដុល្លារអាមេរិក

១.២-ការប្រាក់ចំនួន ៥% ក្នុង ០១ ឆ្នាំ លើប្រាក់ដើម ២៥,០០០ (ម្ភៃប្រាំពាន់) ដុល្លារអាមេរិក។

២.ច្រានចោលការទាមទាររបស់ដើមចោទត្រង់ចំណុច ១-៣ (ការទាមទារសំណងជំងឺចិត្ត)។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ[1]។

[1] មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី.

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទីនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

គូភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។៚

**ចៅក្រម**

ហត្ថលេខា និងត្រា:

---

"ដោយចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ៦កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ពស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រម**

សូមអរគុណ